# ភាសាខ្មែរ

## ការល្បងពិនិត្យដោយរកហេតុផល

▽

# LA LANGUE CAMBODGIENNE

( UN ESSAI D'ETUDE RAISONNÉE )

PAR

**IÊU - KŒUS**

**អៀវ - កើស**

អ្នករៀបរៀង

---

កុង្សីយ៍សេនាបតីបានអនុញ្ញាតហើយ

CETTE PUBLICATION A REÇU L'APPROBATION

DU CONSEIL DES MINISTRES

CA 25



លោក អៀវ កើស

(១៩០៥ - ១៩៥០)

# សេចក្ដីជូនដំណឹងដល់អ្នកអាន

យើងខ្ញុំជាញាតិមិត្តសពលោក អៀវ កើស បានប្រគល់សិទ្ធិសៀវភៅនេះ ជូនបណ្ណាគារមូលមិត្ត និងមិត្តសេរី បោះពុម្ពលក់ផ្សាយចំនួនមួយពាន់ក្បាល ដោយគ្មានយកកម្រៃអ្វីពីបណ្ណាគារទេ ។ ក្រៅពីចំនួនមួយពាន់ក្បាលលើកដំបូងនេះ យើងខ្ញុំសូមដំកល់សិទ្ធិជូនអង្គការរាជការមានសមត្ថកិច្ចទុកបោះពុម្ពជាប្រយោជន៍និងកម្រៃដល់ជាតិ ដើម្បីជាកុសលដល់វិញ្ញាណក្ខន្ធ លោក អៀវ កើស ។

សៀវភៅនេះ រោងពុម្ពព្រះរាជទ្រព្យ បានបោះពុម្ព ៣.០០០ ក្បាល នៅចុងឆ្នាំ ១៩៦៧ បានតែចំពោះភាគទី ១ ប៉ុណ្ណោះ ។ សេចក្ដីនៃលេខយោងក្នុងសៀវភៅភាគទី ១ នោះ ត្រង់ទំព័រ ៨០ ពុំបានយកមកបោះពុម្ពនៅទំព័រ ១០៨ នៃសៀវភៅថ្មីនេះទេ ។ ក្រៅពីលេខយោងនេះ យើងដំកល់

ទុកតាមច្បាប់ដើមរបស់លោក អៀវ កើស ទាំងអស់ ៗ ៦ ចំណែកភាគទី ២ ក៏បានរៀបរៀងចប់ស្រេចតាំងពីជំនាន់នោះដែរ តែមិនទាន់បានបោះពុម្ពផ្សាយនៅឡើយ ៗ ឥឡូវនេះ យើងប្រមូលយកមកបោះពុម្ពតាំងពីក្បាលរួមគ្នាតែមួយសៀវភៅវិញ ដើម្បីឲ្យបានស្រួលដល់អ្នកដែលត្រូវការអាន ៗ

គំពីទំព័រដើរប្រវត្តិខាងមុខនេះ គឺជាសេចក្ដីដែលលោក អៀវ កើស បានរៀបរៀងផ្ទាល់ខ្លួនទាំងអស់ ៖

* * *

# ជីវប្រវត្តិ របស់លោក អៀវ កើស

លោក អៀវ កើស កើតក្នុងឆ្នាំ ១៩០៥ នៅឃុំសង្កែ ខេត្តបាត់ដំបង ជាកូនតែមួយ របស់លោក អៀវ ហេង និងអ្នកស្រី ទឹក ។

លោកបានរៀន នៅវត្តកណ្ដាល និងសាលាបឋមសិក្សា ខេត្តបាត់ដំបង នៅអនុវិទ្យាល័យព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ និងសាលាពាណិជ្ជកម្ម ក្រុងហាណូយ រហូតដល់បានប្រឡងជាប់លេខ ១ ក្នុងឆ្នាំ ១៩២៧ ។

គ្រឹះស្ថានដឺនីហ្វ្រេរនៅភ្នំពេញ និង ចំការកៅស៊ូមេមត់ បានទទួលលោកជានិយោជិក ដល់ដើមឆ្នាំ ១៩២៨ មុននឹងលោកបានផ្ដើមប្រកបការដ៏រកម្មជាសហគ្រិនស្ថាបនា នៅមេមត់ ទៅទល់នឹងឆ្នាំ ១៩៣២ ។

នៅតុលាការកំពង់ចាម ក្នុងឆ្នាំ ១៩២៨ លោកបានប្ដឹង

ឈ្មោះក៏ល្បីតាមហ្វានចំការកៅស៊ូ តាឡាន សញ្ជាតិបារាំង ដែលបានប្រើអំណាចប្រមាថរូបលោក ។ នៅឆ្នាំ ១៩២៩ លោកបានរៀបអាពាហ៍ពិពាហ៍ជាមួយ អ្នកគ្រូ គិម-ស៊ីរី ហៅ ពាញ ។ លោកមានកូនប្រុសពីរ ។

ទោះបីលោកកំពុងប្រកបអាជីវកម្ម ព្រមទាំងមានគ្រួសារហើយក្តី លោកបានខំឆ្លៀតរៀន ទាល់តែប្រឡងជាប់ ក្នុងការប្រជែងយកអាហារូបករណ៍ នៅឆ្នាំ ១៩៣២ ដើម្បីទៅបន្តវិជ្ជានៅវិជ្ជាស្ថានគីមី ឯក្រុងបរដូ នាប្រទេសបារាំង ។ ប៉ុន្តែរដ្ឋាភិបាលបារាំងនៅឥណ្ឌូចិន មិនបានឲ្យលោកចេញទៅរៀនទេ ។

ពីឆ្នាំ ១៩៣២ ទៅ ១៩៤១ លោកបានធ្វើជាសហគ្រិនភាជារណការ នៅបាត់ដំបង ។ ក្នុងពេលនោះ លោកបានចូលជាសមាជិកសភាតំណាងរាស្ត្រខ្មែរ រួចជាសមាជិករង នៅគណៈកម្មការចម្រុះ នៃក្រុមមហាប្រឹក្សាសម្រាប់ការពារផល

ប្រយោជន៍ខាងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅប្រទេសឥណ្ឌូចិន និងបានធ្វើជាសមាជិក នៃគណៈកម្មការចម្រុះនៅអមរដ្ឋាភិបាលខ្មែរ ។

នៅឆ្នាំ ១៩៤១/៤៥ លោកបានប្រកបមុខរបរលក់ថ្នាំពេទ្យ និងបានធ្វើឧស្សាហកម្មសាប៊ូនៅបាត់ដំបង ។ ក្នុងឆ្នាំ១៩៤៥ លោកបានមកភ្នំពេញកាន់តំណែងឧបរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ។ ឆ្នាំក្រោយមកលោកបានចូលរួមបង្កើតគណៈបក្សប្រជាធិបតេយ្យ និងបានធ្វើជាប្រធានរដ្ឋសភាព្រាងរដ្ឋធម្មនុញ្ញ ។ នៅឆ្នាំ១៩៤៧ លោកបានធ្វើប្រធានរដ្ឋសភាម្ដងទៀតរហូតដល់ឆ្នាំ ១៩៤៩ ។

លោកបានចូលជាសមាជិក សមាគមសិស្សចាស់ និងមិត្តអនុវិទ្យាល័យនិងវិទ្យាល័យព្រះស៊ីសុវត្ថិ, សមាគមគិលានសង្គ្រោះចំពោះព្រះសង្ឃ និងគណៈកម្មការវប្បធម៌ ព្រមទាំងបានធ្វើជាទីប្រឹក្សាសមាគមមិត្តសាលាបាលី ។

លោកបានរៀបចំក្បួនជវលេខ និងអង្គុលីលេខខ្មែរ ៗ ជាមួយនឹងគណៈកម្មការវប្បធម៌ លោកបានកែសម្រួលអក្សរខ្មែរសម្រាប់អង្គុលីលេខ ៗ លោកជាអ្នកស្រាវជ្រាវភាសាខ្មែរ, ជាគរុ, ជាអ្នកនិពន្ធសារពត៌មានខ្មែរ-បារាំង និងជាអ្នករៀបរៀងសៀវភៅ "ភាសាខ្មែរ" នេះ ៗ

ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម-សីហនុ ទ្រង់សព្វព្រះរាជហឫទ័យ បានព្រះរាជទាន គ្រឿងឥស្សរិយយស មេដាយមាសព្រះករុណាទ្រង់រាជ្យ និងមេដាយវរសេនា អាណាចក្រកម្ពុជា ៗ

នៅចុងឆ្នាំ ១៩៤៩ លោកបានដាវ៉ៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទៅប្រទេសបារាំង ៗ លុះបានធ្វៀតព្យាបាលរោគរួចត្រឡប់មកប្រទេសយើងវិញមិនបានប៉ុន្មានថ្ងៃផង ស្រាប់តែគ្រាប់បែកដៃមួយបានផ្ទុះឡើងប្រហារជីវិតលោក ក្រោយពេលដែលលោកទើបនឹងបានបិទសម័យប្រជុំ គណៈកម្មការនាយក

នៃគណៈបក្សប្រជាធិបតេយ្យ នៅថ្ងៃ១៤ មករា ១៩៥០ វេលាម៉ោង ៦ ល្ងាច ។ ពាក្យបណ្តាំមុនផុតដង្ហើមរបស់លោក ជាពាក្យជ្រាបដោយធម៌អហិង្សា ។

សពលោកបានបូជានៅវត្តបទុមវតីរាជវរារាម ។ ធាតុលោកបានបញ្ចុះនៅវត្តកែវព្រះភ្លើង ក្រុងភ្នំពេញ ។

រៀបរៀងដោយ

ញាតិមិត្តនៃសពលោកអៀវ កើស

# ភាសាខ្មែរ

(ការល្បងពិនិត្យដោយរកហេតុផល)

ក្បាលទី ១

# LA LANGUE CAMBODGIENNE

(Un essai d'étude raisonnée)

**Tome I**

អៀវ - កើស

អ្នករៀបរៀង

---

បោះពុម្ពផ្សាយ

ដោយបណ្ណាគារ មិត្តសេរី

ព. ស. ២៥០៩ គ. ស. ១៩៦៥

**បោះពុម្ពឡើងវិញ**

ដោយ **អមតា**

**ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩២**

សូមឧទ្ទិសដល់អ្នកមាតាជាទីស្រឡាញ់
ដែលបានទទួលអនិច្ចកម្មទៅ កាលខ្ញុំនៅ
ក្មេងពុំបានសងគុណគាត់ ។

# សេចក្ដីជំរាបជាមុន

សៀវភៅនេះ មិនមែនជារឿងនិទានសំរាប់អានលេងកំសាន្តចិត្ត ។ ដូច្នេះមិនមែនជាសៀវភៅសំរាប់សាមញ្ញជនទេ ។

មិនថាជាសៀវភៅវេយ្យាករណ៍ សំរាប់រៀនក្នុងសាលាក៏ទេដែរ ។ ដូច្នេះមិនមែនជាសៀវភៅសំរាប់កូនសិស្សទេ ។

គឺជាសៀវភៅសំរាប់ជួយអ្នកចេះខ្មែរហើយ ឲ្យចេះលើសបន្តិចទៅទៀត ហើយ ចាប់ស្នើយោបល់របស់អ្នកសរសេរជូនលោកអ្នកប្រាជ្ញខាងអក្សរសាស្ត្រខ្មែរ ដែលមានបំណងខំរៀបចំវេយ្យាករណ៍នៅថ្ងៃក្រោយ ។

សេចក្ដីប្រាថ្នារបស់អ្នកសរសេរ គឺថាល្បងពិនិត្យភាសាខ្មែរឲ្យចប់សព្វគ្រប់ តែពិនិត្យបានតែសូរសាស្ត្រនិងនិយណ្ណសាស្ត្រ នៅសល់រូបសាស្ត្រទៀត ក៏រកពេលទំនេរនឹងសរសេរតទៅពុំបាន ។

សូរសាស្ត្រដែលមានអធិប្បាយក្នុងសៀវភៅនេះសរសេររួចតាំងពីខែមេសា (អាព្រិល) គ.ស. ១៩៤៦ ។ ឯនិយណ្ណ-

សាស្ត្រសេរីរួចពីខែមិថុនា (យូកុំង) គ.ស. ១៩៤៦ ។ កុងសម័យនោះត្រូវបានអនុញ្ញាតពីរាជការ ទើបបោះពុម្ពផ្សាយបាន ។ សំរាប់សៀវភៅនេះ ទំរាំសុំអនុញ្ញាតបាន អស់វេលាជាងពីរខែ ។ នេះរាប់បានថារហ័សណាស់ហើយ ។ ដល់បានអនុញ្ញាតហើយ រកជួលគេបោះពុម្ពមិនបានទៀត ព្រោះគ្មានអក្សរពុម្ពខ្មែរគ្រប់គ្រាន់នឹងការ ។ ពាល់តែទៅពឹងសមាគមសុធារស ទើបរកពុម្ពព្រះរាជទ្រព្យព្រមបោះឲ្យ ។ ការបោះពុម្ពនេះចាប់ធ្វើពីដើមឆ្នាំដល់មកខែតុលា (ទិកតូប) នេះ គ្រាន់តែជិតរួច ។

ផលដែលកើតឡើងអំពីការពិបាកនេះ មាន ៣ ប្រការ ៈ

១.— ធ្វើឲ្យឃើញថាហេតុនេះហើយ បានជាអក្សរសាស្ត្រយើង និងវឌ្ឍនធម៌យើងពុំបានដើរលឿនឲ្យទាន់សម័យនឹងគេ ។

២.— ធ្វើឲ្យចេញសៀវភៅក្បាលទី ២ ព្រមពេលគ្នានឹងសៀវភៅនេះពុំបាន ។ សៀវភៅក្បាលទី ២ ដែលនិយាយ

អំពីដើមកំណើតរបស់ពាក្យខ្មែរ អាចជាទីពាក់ចិត្តចង់ចេះ ចង់ស្គាល់របស់អ្នកអានជានសៀវភៅនេះ ។ កាលបើចេញសៀវភៅក្បាលទីមួយតែប៉ុណ្ណោះ អ្នកអានអាចចូលចិត្តខុសថាមិនមែនជារឿងគួរចង់ដឹងប៉ុន្មានទេ ។

៣.- ធ្វើឲ្យសៀវភៅទាំងពីរក្បាល ចាស់ផុតសម័យបន្តិចទេ ព្រោះតាំងពីកាលសរសេរចប់មកដល់វេលានេះ ភាសាយើងបានលូតលាស់យ៉ាងរួសរាន់ ដោយសារសេចក្ដីព្យាយាមនៃគណៈកម្មការវប្បធម៌ ដែលបានបង្កើតពាក្យថ្មីជាច្រើនម៉ាត់ ។ ខ្ញុំបានយកពាក្យ អក្ខរាវិរុទ្ធ មកបញ្ចូលប្រើក្នុងសៀវភៅនេះខ្លះ ក្នុងពេលដែលរៀបពុម្ព ។

ថ្ងៃ ១០ ខែតុលា គ.ស. ១៩៤៧

អៀវ-កើស

# សញ្ញាសំគាល់

| | | |
|---|---|---|
| > | អានថា | ទៅជា |
| < | ” | មកពី |
| + | ” | ថែម ឬ នឹង |
| = | ” | គឺ |
| ឧ. | ” | ឧទាហរណ៍ |
| សំ. | ” | សំស្ក្រឹត |
| បា. | ” | បាលី |

# បញ្ជីរឿង

ទំព័រ

ពាក្យសំគាល់ . . . . . . . . . ១

## ពាក្យផ្ដើម

អ្វីដែលហៅថាភាសាខ្មែរ? . . . . . . ៧
លក្ខណៈនៃភាសា . . . . . . . . ២០
អំបូរភាសា . . . . . . . . . ២២

## ភាគទី ១

## សូរសាស្ត្រ

### ផ្នែកទី១– អំពីអក្សរ

ស្រៈ . . . . . . . . . . ៣០
ព្យញ្ជនៈ . . . . . . . . . ៣៧
វណ្ណយុត្តិ . . . . . . . . . ៤៣
វណ្ណសញ្ញា . . . . . . . . . ៤៧
ប្រវត្តិនៃអក្សរ . . . . . . . . ៧៤

### ផ្នែកទី២–វិធីអាន

សំឡេងស្រៈ . . . . . . . . . ៩៧
សំឡេងព្យញ្ជនៈ . . . . . . . . ១០១
សំឡេងអក្សរកាលសរសេរបញ្ចូលគ្នា . . . . . ១០៤
វិធីអានពាក្យត្រង់សំឡេងវេវៈទី . . . . . ១១៦

ទំព័រ


វិធីអានពាក្យត្រង់សំឡេងគ្រលួចឬគ្រលរ . . . . . ១២៧

វិធីអានពាក្យមកពីបាលី-សំស្ក្រឹតខ្លះដែលមិនទាន់បានអធិប្បាយ. ១៣៤


## ផ្នែកទី ៣— ច្បាប់ស្វរសាស្ត្រខ្លះ


កែសំឡេងព្យញ្ជនៈរឹងជាទន់ . . . . . . ១៤១

កែសំឡេងព្យញ្ជនៈតឹងជាធូរ . . . . . . ១៤៣

កែសំឡេងស្រៈ . . . . . . . ១៤៥

កែពាក្យព្យាង្គច្រើនជាពាក្យព្យាង្គតិច . . . . . ១៥០

កែពាក្យព្យាង្គតិចជាពាក្យព្យាង្គច្រើន . . . . . ១៥៤

ការប្រែប្រួលអក្សរ រ . . . . . . ១៥៥

ការប្រែប្រួលសព្វេងផ្សេង ៗ ទៀត (សំឡេងវាយះង). . ១៥៧


## ភាគទី ២

# និឃណ្ដុសាស្ត្រ

## ផ្នែកទី ១


ពាក្យដែលគុបតែងបង្កើតឡើង . . . . . ១៦៦

អំបូរពាក្យ . . . . . . . ១៦៦

ក— ពាក្យផ្សំខ្មែរ . . . . . ១៦៧

— រូបរបស់ពាក្យផ្សំ . . . . . ១៦៨

១— បុព្វបទ . . . . . . ១៧១

ក— អព្យាង្គបុព្វបទ . . . . ១៧២

ខ— ព្យាង្គបុព្វបទ . . . . . ១៧៤

ទំព័រ


២– បទស្រែក . . . . . . ១៧៧

— អត្ថៈរបស់បទភ្ជាប់ . . . . ១៨២

១– ន័យជា « ធ្វើឱ្យ » . . . . ១៨២

២– ន័យជា « ទៅវិញទៅមក » . . . ១៨៤

៣– ន័យជា សេចក្ដីបង្គាប់ . . . ១៨៤

៤– ន័យជា គ្រឿងឧបករណ៍ . . . ១៨៦

៥– ន័យជា អ្នកធ្វើ . . . . ១៨៧

៦– ន័យជា របស់ដែលគេត្រូវធ្វើ . . ១៨៨

៧– ន័យជា « ញឹកញយ » . . . . ១៨៩

— ការផ្លាស់ប្រភេទរបស់មូលសព្ទដោយបទភ្ជាប់ ១៨៩

១– ទៅជាកិរិយាសព្ទ . . . . ១៩០

២– ទៅជានាមនាម . . . . ១៩៥

៣– ទៅជាគុណនាម . . . . ១៩៨

ក– ពាក្យខ្ចីបាលី-សំស្ក្រឹត . . . . ១៩៩

១– បុព្វបទ . . . . . ២០០

២– បច្ច័យ . . . . . ២០៨

ខ– ពាក្យគន្លាស់កាត់ . . . . . ២១១

គ– ពាក្យគួប . . . . . . ២១៨

ឃ– ពាក្យសមាស . . . . . ២១៩

សន្ធិ . . . . . . . . . ២២០

ឃ– ពាក្យទ្វ . . . . . . ២២៣

## ផ្នែកទី ២

ពាក្យដែលខ្ចីពីភាសាក្រៅ . . . . . . . ២៣០
ក— ភាសាសំស្ក្រឹត និង ភាសាបាលី . . ២៣០
ខ— ភាសាសំស្ក្រឹត-បាលី និងភាសាខ្មែរ . . ២៣៨
គ— ភាសាខ្មែរនិងភាសាសៀម . . . ២៤៥

## ផ្នែកទី ៣

គុណប្រយោជន៍នៃច្បាប់សូរសាស្ត្រនិងច្បាប់និយណ្ឌសាស្ត្រ . ២៦៧
ក— សេចក្ដីសំគាល់តាមនិរុត្តិសាស្ត្រ . . . . ២៧៨
១— ពាក្យផ្សំខ្មែរ . . . . . . ២៧៨
២— ពាក្យគន្លាស់កាត់ . . . . ២៨៦
៣— ពាក្យគូ . . . . . . ២៩១
៤— ពាក្យបាលី-សំស្ក្រឹត . . . ២៩៥
ខ— ការសម្រេចអក្ខរាវិរុទ្ធនៃពាក្យ (ការសម្រេចរូបពាក្យ) ៣០២
១— ពាក្យខ្មែរសុទ្ធ . . . . ៣០៧
២— ពាក្យមកពីបាលី-សំស្ក្រឹត . . . ៣២១
គ— ការបង្កើតពាក្យថ្មី . . . . . ៣២៧
— គន្លងនៃការបង្កើតពាក្យ . . . . ៣៣៤
— វិធីបង្កើតពាក្យ . . . . . ៣៣៨
— ការល្បងបង្កើតពាក្យថ្មី . . . . ៣៤៣
— គួរមានពាក្យឲ្យជំសំរាប់ប្រើ . . . ៣៦៤

# ពាក្យលំនាំ

យើងជនជាតិខ្មែរទាំងឡាយ រមែងយកចិត្តទុកដាក់នឹងភាសាខ្មែរជាធម្មតា, រមែងចង់ឲ្យភាសាយើងទទួលសេចក្តីកប់កានរបស់ប្រជាជនទាំងពួងក្នុងកម្ពុជរដ្ឋ, រមែងចង់ឲ្យមានការប្រើភាសាខ្មែរក្នុងកិច្ចការគ្រប់យ៉ាង មានកិច្ចការរាជការជាដើម; ព្រោះថាកាលណាភាសាយើងមានប្រើការច្រើនឡើង ក៏នឹងត្រូវរៀនសូត្រភាសាយើងច្រើនឡើងដែរ ។ កាលបើរៀនច្រើនឡើង ក៏នឹងមានមនុស្សចេះភាសាយើងកាន់តែច្រើនគ្នាឡើង កាន់តែជ្រាលជ្រៅទៅ ។ អ្នកដែលស្វែងចំណេះបានមកពីភាសាក្រៅ មានភាសាបារាំងជាដើម កាលបើចេះភាសាខ្មែរជ្រាលជ្រៅហើយ ក៏នឹងអាចនាំយកវិជ្ជាដែលខ្លួនស្វែងបានមកនោះ មករៀបរៀងសរសេរជាភាសាខ្មែរ ចែកចាយផ្សាយដល់បងប្អូនរួមជាតិទាំងឡាយ ឲ្យបានចេះដឹងដោយសារផង ។ ប្រជានិករខ្មែរក៏នឹងបានចំរើន

វិទ្យាឋានៈ(១) ខ្ពស់ឡើងដូចក្នុងប្រទេសដទៃ ។

ក្នុងវេលានេះ ប្រទេសបារាំងបានបន្ធូរបន្ថយឲ្យយើងចាត់ចែងកិច្ចការរាជការក្នុងស្រុកយើងខ្លួនឯង ហើយព្រះករុណាជាអម្ចាស់ជីវិតលើត្បូងក៏ទ្រង់ព្រះចិន្តាថានឹងព្រះរាជទានរដ្ឋធម្មនុញ្ញឲ្យប្រជារាស្ត្ររបស់ព្រះអង្គ ដោយព្រះអង្គទ្រង់ព្រះមេត្តាប្រោសចង់ឲ្យប្រជាជាតិខ្មែរដើរលឿនទាន់សម័យទំនងគេ ។

ភាសាខ្មែរនឹងត្រូវប្រើការច្រើនឡើង សមនឹងបំណងយើងទាំងអស់គ្នា ។ ប្រជាជននឹងយកចិត្តទុកដាក់ចំពោះដឹងភាសាខ្មែរកាន់តែច្រើនជាលំដាប់; សេចក្ដីត្រូវការពាក្យថ្មីក៏នឹងបង្កើតមានឡើង នាំឲ្យឆ្អិតឆ្អល់កង្វល់ចិត្តដល់យើងទាំងឡាយមិនតិចឡើយ ។

---

១– អានវិទ្យៈឋានៈ វិទ្យៈគឺ វិជ្ជា ចំណេះ; ឋានៈគឺ ឋាន កន្លែង ទីតាំង ថ្នាក់ ជាន់ ។ វិទ្យាឋានៈ=ជាន់ ថ្នាក់ខ្ពស់ទាបរបស់ចំណេះ (**niveau d'éducation, d'instruction**) ។

ភាសាខ្មែរយើងនេះ ខ្ញុំបានឆ្លៀតរៀនតែឯងមកខ្លះហើយ ដោយខ្វាក់ល្ងិត តែផលនៃការរៀនរបស់ខ្ញុំនៅតូចស្តួចស្តើង ឆ្ងាយណាស់ពីកំរិត ដែលល្មមជាទីងប្រើការបានដោយពេញលេញ ៗ ក្នុងសៀវភៅនេះ ខ្ញុំប្រមូលកំណត់ដែលខ្ញុំបានកត់ទុករៀងៗមក កាលរៀននៅបានប្រទះ ហើយខ្ញុំយកមករៀបរៀងពង្រីកសេចក្តី ប្រយោជន៍ដើម្បីបញ្ចៀសសេចក្តីលំបាកស្រវារីមវាមក្នុងងងឹត កុំឲ្យមានច្រើនពេកដល់បងប្អូនរួមជាតិដែលនឹងត្រូវការសូត្ររៀនតែឯងដូចខ្ញុំនៅថ្ងៃក្រោយ ៗ នោះបើសៀវភៅនេះ នាំឲ្យអ្នកអានបានភ្លឺក្នុងភាសាខ្មែរ សូម្បីតែបន្តិចបន្តួច ឬនាំអ្នករកពាក្យថ្មីឲ្យអាចបង្កើតពាក្យ សូម្បីតែមួយម៉ាត់ក៏ដោយ នោះក៏ទុកជាបានពេញសេចក្តីប្រាថ្នាខ្ញុំហើយ ។

ការពិនិត្យភាសាខ្មែរ ដោយរកហេតុផលនេះ ញ៉ាំងឲ្យមានគំនិតថ្មីៗ អំពីខ្ញុំជាច្រើនអន្លើ ៗ គំនិតទាំងនោះធ្វើទៅដោយបរិសុទ្ធចិត្តឥតមានប្រទូស្តដល់នរណាឡើយ, ធ្វើទៅ

ដោយប្រាថ្នាឲ្យមានការប្រែប្រួលវិធីសរសេររបស់យើងឲ្យបាន ស្រួលឡើងទៀត ដើម្បីឲ្យវិធីសម្រេចរូបរបស់ពាក្យចំពូកខ្លះសមហេតុសមផលល្អឡើង ហើយដើម្បីឲ្យកែប្រែអត្ថៈរបស់ពាក្យខ្លះដែលខ្ញុំយល់ថាដូចជាមានសេចក្ដីកាន់ច្រឡំ ។ ហេតុនេះខ្ញុំសូមទុកជាមុន នូវសេចក្ដីខមាទោសដល់លោកអ្នកប្រាជ្ញទាំងឡាយដែលបានរៀបរៀងវចនានុក្រមខ្មែរ ។

ក្នុងការរៀបរៀងសៀវភៅនេះ ខ្ញុំបានប្រសព្វនឹងឧបសគ្គជាច្រើនដែលបណ្ដាលឡើងអំពីសេចក្ដីខ្វះពាក្យប្រើ ។ សេចក្ដីខ្វះនេះមកពីខ្ញុំមិនថ្នឹកក្នុងភាសាខ្មែរផង ហើយមកពីយានគឺភាសាខ្មែរមិនទាន់ធ្លាប់ទទួលផ្ទុកនូវកស្ដុការបែបថ្មី គឺវិជ្ជាសម័យបច្ចុប្បន្ននេះផង ។ ពាក្យថ្មីដែលត្រូវប្រើនោះ ខ្ញុំបានរកដាក់ទៅខ្លះជាការបណ្ដោះអាសន្នព្រោះខានពុំបាន គង់មានធ្គាំធ្គងមិនល្អឡើយ; ពាក្យខ្លះនឹងមានជីវិតរស់យូរទៅ ឯពាក្យខ្លះទៀតគង់រលុបរលាយបាត់បង់ទៅឯង ។ អ្នកអានមុខជានឹងចាស់ក្អែក ចាស់ត្រចៀកនឹងពាក្យចំពូកនេះ ហើយ

និងរបៀបរៀងពាក្យដែលមិនធ្លាប់ប្រទះនោះជាមិនខាន ។ ត្រង់នេះខ្ញុំក៏សូមខមាទោសជាមុន ដោយសង្ឃឹមថាគង់នឹងស៊ាំភ្នែក ស៊ាំត្រចៀក នឹងភាសាសរសេររបស់ខ្មែរបែបថ្មីនេះទៅថ្ងៃក្រោយ ។

មួយវិញទៀត ខ្ញុំដែលពុំបានទទួលការសិក្សាដោយចំត្រង់អក្សរសាស្ត្រ មករៀបរៀងសរសេរពីភាសាខ្មែរដូច្នេះ អាចនាំការណ៍ចំឡែកប្លែកបាតដល់អ្នកផងទាំងពួង ។ គួរតែទុកការៈនេះជូនលោកអ្នកប្រាជ្ញខាងអក្សរសាស្ត្រ ដែលល្មមនឹងសរសេររឿងនេះបានដោយត្រឹមត្រូវច្បាស់លាស់ជាងខ្លួនខ្ញុំ ។ សេចក្តីពិត ខ្ញុំចាំមើលមកយូរហើយ, ឃើញមានបោះពុម្ពតែសៀវភៅវេយ្យាករណ៍តូចមួយក្បាល ដោយក្រមវិទ្យាសាស្ត្រ(!) ។ ខ្ញុំបានឮថា លោកអ្នកប្រាជ្ញឯទៀតបំរុងនឹងបោះពុម្ពវេយ្យាករណ៍ជាច្រើនគ្នា តែមិនចេះឃើញសៀវភៅនោះចេញមកសោះ ។ ទើបខ្ញុំកាត់ចិត្តសរសេរសៀវភៅនេះតាមល្ងង់ទៅ សង្ឃឹមថាកាលលោកអ្នកប្រាជ្ញ

ដែលពោលមកហើយ បានឃើញសេចក្តីខុសៗ សំខាន់ច្រឡំក្នុង
សៀវភៅនេះ គង់លោកអ្នកនឹងបោះពុម្ពសៀវភៅលោកឯង
ដើម្បីកែតម្រូវសេចក្តីទៀត ៗ យើងទាំងអស់គ្នាក៏នឹងបានគឺ
ដោយសារ ៗ

# ពាក្យផ្ដើម

## អ្វីដែលហៅថាភាសាខ្មែរ?

ដើមឡើយភាសាជាអ្វី? តាមសេចក្ដីធំទូលាយរបស់ពាក្យ ភាសាជាការសំដែងចិត្តគំនិតគ្រប់យ៉ាង ៗ មាន់ឈ្មោលកាលបើកកាយសប្បាយចិត្ត ករងាវ; មាន់ញីកាលក៏ឈឺពង ក៏អត, កាលក៏ពងរួច ក៏ខ្ពត ក្ដែបកកន្ទុយដើម្បីសំដែងសេចក្ដីគោរព ៗលៗ តាំងនេះជាភាសាមួយយ៉ាង៖ លោកហៅថាភាសាសត្វ ៗ មនុស្សគ ឬមនុស្សដែលភាសាផ្សេងគ្នាស្ដាប់គ្នាពុំបាន យកដៃទះពោះ ហើយបង្អុលមាត់ ដើម្បីសំដែងសេចក្ដីស្រេកឃ្លាន ឬលាតបាតដៃដាក់កែបទៅនឹងត្រចៀក ហើយផ្អៀងក្បាលទៅលើដៃនោះ ដើម្បីសំដែងសេចក្ដីចង់ដេក តាំងនេះក៏រាប់ថាជាភាសាបានដែរ៖ ហៅថាភាសាគ។

ប៉ុន្តែតាមសេចក្ដីរួមតូចមក ភាសាត្រឹមតែជាការសំដែងចិត្តគំនិតដោយពាក្យសំដី ៗ ដែលយើងនឹងអធិប្បាយអំពីភាសាខ្មែរនេះ គឺសំដៅយកសេចក្ដីរួមតូចរបស់ពាក្យភាសា ៗ

ភាសាខ្មែរ តាមដែលនិយាយក្នុងដំបន់ផ្សេង ៗ មិនដូចគ្នាទាំងអស់ទេ ល្បៀងពីគ្នាទៅដោយសំឡេង ទៅដោយពាក្យដែលប្រើនៅទីនេះ មិនប្រើនៅទីនោះ ឬល្បៀងគ្នាដោយសេចក្ដីរបស់ពាក្យដែលប្រែជាដូច្នេះនៅទីនេះ ប្រែតាមន័យមួយទៀតនៅទីនោះ ។

អ្នកសៀមរាបនិយាយទ្រង់ជើនមួយគល់ អ្នកសូរិននិយាយផ្សេងពីអ្នកសៀមរាបបន្តិចទៅទៀត ខុសគ្នាច្រើនពីបែបនិយាយរបស់អ្នកបាសាក់ព្រះត្រពាំង ។ បែបនិយាយរបស់អ្នកកំពេញ ក៏មានខុសគ្នាខ្លះពីបែបនិយាយរបស់អ្នកបាត់ដំបង អ្នកតាកែវឬអ្នកក្រចេះ ។ បែបនិយាយដែលឃ្លៀងឃ្លាតពីគ្នាទៅតាមទីដំបន់នេះ លោកហៅថា គ្រាម-ភាសា(១) ។ គ្រាមភាសាទាំងនេះមិនមែនខុសគ្នាដល់ថាអ្នកនិយាយស្ដាប់គ្នាមិនបាន តោងរកអ្នកបកប្រែទេ; សុទ្ធសឹងតែជាគ្រាមភាសាខ្មែរទាំងអស់ ។

---

១– អានថា គ្រាមៈភាសា ពីគ្រាម ប្រែថាប្រជុំភូមិ, ស្រុក ។

ម្ល៉ោះហើយ កើតជាបញ្ហាថា គ្រាមភាសាណាដែលជាភាសាខ្មែរដោយចំ ។ កាលពីដើម ខ្ញុំប្រកាន់ថា ភាសាដែលគេនិយាយក្នុងទីកំណើតរបស់ខ្ញុំ គឺទីរួមខេត្តបាត់ដំបង ជាភាសាខ្មែរដែលត្រឹមត្រូវបំផុត; កាលណាខ្ញុំប្រទះពាក្យដែលល្មៀនពីទំលាប់ប្រើរបស់ខ្ញុំ ដោយសំនៀងក្តី ដោយអត្ថៈក្តី ខ្ញុំចុះពាក្យនោះជាខុស ៗ មានសម័យមួយ ខ្ញុំទៅស្រុកស្វាយ-ចេក ៗ ខ្ញុំឮអ្នកស្រុកនោះនិយាយខុសទំលាប់របស់ខ្ញុំ - ជាអនេកប្រការ ៗ ស្តាប់ទៅហើយរមែងចាស់ត្រចៀកពល់ផង ៗ ខ្ញុំក៏នឹកក្នុងចិត្តថា ខ្មែរពួកនេះនិយាយខុសច្រើនណាស់ ៗ រួចក៏ស្រាប់តែគំនិតមួយទៀតបង្កើតឡើងក្នុងចិត្តខ្ញុំថា៖ នេះខ្ញុំកើតនៅទីរួមខេត្តបាត់ដំបង ខ្ញុំគិតថាអ្នកស្វាយចេកនិយាយខុស, ចុះប្រសិនជាខ្ញុំកើតនៅស្វាយចេកវិញ ខ្ញុំមិនគិតថាអ្នកបាត់ដំបង អ្នកក៏ពេញនិយាយខុសទៅៈហើយ?

តាមធម្មតា គ្រាមភាសារបស់ទីក្រុងធំរមែងចំជាភាសារបស់ជាតិ ជាងគ្រាមភាសាឯទៀត ដ្បិតគ្រាមភាសាទីក្រុង

រមែងពង្រីកផ្សាយចេញទៅព្រមទាំងអំណាចរាជការទូទៅក្នុងរាជាណាចក្រ ៗ ក្នុងសម័យបុរាណ គ្រាមភាសាអាត់ទិក (Attique) ក្នុងដែនដែលជាទីតាំងរាជធានីអាថែន (Athènes) បានផ្សាយទៅជាភាសាកណ្ដាលសំរាប់ជាតិក្រិកពីដើម; ភាសាឡាតាំងដែលជាភាសាកណ្ដាលរបស់ជាតិរ៉ូម ក៏មានកំណើតនៅក្រុងរ៉ូមដែលជារាជធានី ៗ គ្រាមភាសារបស់ក្រុងប៉ារីសរបស់ក្រុងឡុនដន បានក្លាយទៅជាភាសាកណ្ដាលរបស់ជាតិបារាំង របស់ជាតិអង់គ្លេស ព្រោះក្រុងទាំងពីរនេះជារាជធានីយូរអង្វែងដល់ពាន់ឆ្នាំមកហើយ ៗ ឯរាជធានីយើង ទើបមកតាំងនៅភ្នំពេញរវាង ៨០ ឆ្នាំ ៗ គ្រាមភាសាដែលនិយាយនៅភ្នំពេញ ចំជាភាសាខ្មែរជាងគ្រាមភាសាខេត្តក្រៅពិតមែនតែក៏មិនមែនជាភាសាខ្មែរដោយចំពេញទីទេ ៗ សំឡេងដូចជាសំឡេងព្យញ្ជនៈ រ ទិងសំឡេងស្រៈ អ៊ិ អ្នកភ្នំពេញបាញ្ចេញមិនត្រូវ; ឯអ្នកដាយដែនច្រើនជាត្រូវ ៗ ត្រង់ស្រៈ អ៊ី តាមសំឡេងអ្នកខាងលិច មិនអាចប្រឡំនឹងស្រៈ អៀ បាន

ដូចតាមសំនៀងអ្នកនៅកាត់កណ្ដាល ។ ប៉ុន្តែអ្នកបាត់ដំបងថាសំនៀង អិ អ៊ែ មិនត្រូវ; គ្រប់ និង គ្រុប ធំ និង ធុំ មែង និង ម៉ែង អ្នកខេត្តនោះមិនអាចធ្វើសំនៀងឲ្យខុសគ្នាបានឡើយ ។ សំរាប់ខ្យល់ ៗ អ្នកខេត្តតាកែវថាត្រឹមត្រូវជាងគេ; ក្នុងគ្រាមភាសាខ្មែរឯទៀត ច្រើនតែគ្មានបញ្ចេញសំនៀងខ្យល់ ៗ សំរាប់ខ្យល់ដទៃទៀតមាន ក ជាដើម ខ្មែរក្នុងអាណាចក្រកម្ពុជា ថាមិនត្រូវចំ ឧ. កាក់ បាក់ ប្រាក់ ច្រើនតែថា កៈ បៈ ប្រៈ ; មានតែខ្មែរកូស័ងស៊ីនបានថាត្រូវចំដល់ខ្យល់ ក ប៉ុន្តែដូចជាសង្កត់ខ្លាំងហួសបន្តិច ។ ការណ៍(១) ដែលខ្ញុំនាំមក

---

១— ដើម្បីកុំឲ្យងឿងឆ្ងល់ត្រង់ពាក្យការណ៍ ការ ករណី ករណីយ៍ ខ្ញុំសូមកំដាប់សេចក្ដីរបស់ពាក្យទាំងនេះ ដើម្បីឲ្យបងប្អូនទាំងឡាយយល់ចិត្តបានច្បាស់ហើយប្រើទៅតាមទំនងមួយច្បាស់ ។ សេចក្ដីដែលនឹងកំដាប់នោះ គឺសេចក្ដីនៃពាក្យទាំងនេះ កាលមកជាពាក្យខ្មែរទៅហើយ មិនមែនកាលនៅជាពាក្យបាលីសំស្ក្រឹតទេ ។

ការ ដូចក្នុង "ខ្ញុំធ្វើការ" ប្រែថាអំពើដែលយើងធ្វើ ត្រង់គ្នានឹងពាក្យបារាំង travail ។

(មាន)...

ពោលជាឧទាហរណ៍ទាំងអម្បាលនេះ គ្រាន់តែខាងសំនៀង ហើយមិនបានត្រង់បន្ទង់ ។ ក្រៅពីខាងសំនៀងនៅមានខាងពាក្យនិងសេចក្ដីរបស់ពាក្យដែលខុសគ្នា, ដូចមានពោលបន្តិចមកហើយ រាំងគ្រាមភាសាមួយ ទៅគ្រាមភាសាមួយទៀតៗ

ហេតុដូច្នេះ ភាសាខ្មែរមិនមែនជាគ្រាមភាសាខ្មែរណាមួយតែយ៉ាងបំពោះទេ ព្រោះយើងបានឃើញមកហើយថា គ្រាមភាសាទាំងនេះសុទ្ធសឹងតែមានខុសខ្លះ មិនដូចដោយស្មោះ

---

ញ ដូចក្នុង «ការដឹកនាំ, ការរៀបចំ, ការលំពាក» ជាបុព្វបទ (prétixe) សំរាប់ធ្វើឲ្យពាក្យប្រភេទដទៃ ប្រែសភាពជាឆាប់ងាយ ។

ការណ៍ ក្នុងវចនានុក្រមលោកប្រែថាហេតុ, ដំណើរ ។ បើនឹងស្រដីឲ្យច្បាស់ទៅ គឺថារបស់ដែលកើតមានឡើងហើយ, ដែលធ្វើរួចមកហើយ, ត្រង់នឹងពាក្យបារាំង fait, un fait, des faits, (Les faits que j'ai cités comme exemples) ។

ករណី ប្រែថារឿង, ហេតុភេទ, ឧ. ករណីវិភេទ = រឿងវិភេទ ។ ត្រង់នឹងពាក្យបារាំង Cas, ស្រេចតែករណី = selon le cas ។

ករណីយ៍ ប្រែថារបស់ដែលត្រូវធ្វើ, ត្រង់នឹងពាក្យបារាំងថា devoir ។ បើឲ្យល្អ devoir (au sens moral) គួរប្រែថាករណីយកិច្ច (អាន ករៈ-ណីយៈកិច្ច) ។

ទឹងភាសាដែលហៅថាភាសាខ្មែរ ។

បញ្ហាទើបនៅដដែល ៖ អ្វីដែលហៅថាភាសាខ្មែរ ? ភាសាខ្មែរជាភាសារបស់ជនជាតិខ្មែរទាំងអស់គ្នា ។ បើខ្ញុំឆ្លើយដូច្នោះ ក៏បានមួយយ៉ាងដែរ, ប៉ុន្តែសូមឲ្យពិនិត្យការណ៍ត្រង់នេះបន្តិចមើល ។ អ្នកក៏និយាយខ្មែរ ខ្ញុំក៏និយាយខ្មែរ យើងស្ដាប់គ្នាបានដោយពេញទី ។ តែបើសង្កេតដោយល្អិតទៅ បែបនិយាយរបស់អ្នក គង់មានខុសគ្នាពីបែបនិយាយរបស់ខ្ញុំខ្លះ ។ តាមន័យនេះ ក្មេងសម័យក្រោយនិយាយមិនដូចជីតារបស់វាទេ ។ បើនឹងស្រដីមួយយ៉ាងទៀត ភាសាក្មេងជាន់ក្រោយ ,មានល្អៀងពីភាសាមនុស្សដែលបានចូលទៅកាន់វ័យជរាហើយ, ភាសាកូនចិនល្អៀងពីភាសាជនជាតិខ្មែរសុទ្ធ, ភាសាគ្រហាវាសល្អៀងពីភាសាបព្វជិត ។ ឯភាសាអារក្សអ្នកតាវៀងពីនោះទៅទៀត ដូចជាពាក្យភាការ-សាហារ (=ស្រា) ពង់តាប (អ្នកដែលលុះខាងចក្រា), ១ កំប៉ាំង (=១ រៀល) . . . ។

ដូច្នេះភាសាខ្មែរ មិនមែនជាភាសារបស់ក្រុងណាខេត្តណា ទីជំចន់ណាដោយចំពោះទេ, ទឹងជាជាភាសាដែលអ្នកនិយាយ ឬខ្ញុំនិយាយ ឬជនណានិយាយដោយស្មោះក៏ទៅដែរៗ

សេចក្ដីសន្និដ្ឋាន គឺជាភាសាខ្មែរ តាមន័យដែលយើងចង់ស្រដីនេះ ជាភាសាកណ្ដាលសំរាប់ជនជាតិខ្មែរទាំងពួង ដោយឥតគិតដល់ទីជំចន់ ឬឋានៈនៃអ្នកប្រើភាសានោះឡើយៗ

ពាក្យថា " សំរាប់ជនជាតិខ្មែរ ," គេនឹងយកសេចក្ដីឲ្យធំទូលាយប្រែថា មនុស្សដែលនៅក្នុងស្រុកខ្មែរទាំងអស់គ្នា ៗ គួយ សៀង ពួង មិនមែនមានជ័រជាតិ ឬឈាមជ័រ (Race) ជាខ្មែរទេ មានភាសាផ្សេងពីភាសាខ្មែរ ៗ ភាសាទាំងនេះប្រើសំរាប់តែជនដោយចំពួក គ្រាន់និយាយប្រស្រ័យគ្នាទៅវិញទៅមកក្នុងគណៈរបស់ខ្លួន ៗ កាលបើពួងចង់និយាយនឹងសៀងឬគួយ ឬចង់និយាយនឹងខ្មែរ គេនឹងប្រើភាសាខ្មែរជាភាសាកណ្ដាលទើបស្ដាប់គ្នាបាន ៗ ភាសាគួចៗបែបភាសា

ក្លួយ ស្បៀង ពួង នេះហៅថាទេសភាសា (១) ។ ក្នុងស្រុកចិនមានទេសភាសាជាច្រើន ដូចជាទេសភាសា តៀជីវ ហុក-គៀន តាំងតាំងជាដើម, នៅស្រុកបារាំងក៏មានទេសភាសាក្រែលដែរ ដូចជាទេសភាសា ព្រើតុង បាស្គ អាល្សាស ... ។

ភាសាតាម កាលពីដើមជាភាសាកណ្ដាលក្នុងប្រទេសតាម្យ៉ា ។ ប្រទេសតាម្យ៉ាលែងរលាយទៅយូរហើយ ។ ភាសាតាមក៏ក្លាយទៅជាទេសភាសាមួយក្នុងស្រុកខ្មែរ ។ លក្ខណៈសំខាន់បំផុតរបស់ទេសភាសា គឺជាប្រើបានតែនឹងជនដែលនៅក្នុងពួកគណៈជាមួយគ្នា កាលណាជនពួកនេះនិយាយនឹងជនជាតិក្រៅ គេនឹងប្រើភាសាកណ្ដាល ។ សូមឲ្យជនជាតិខ្មែរទាំងឡាយ ចំប្រឹងប្រែងកុំឲ្យលក្ខណៈនេះមានដល់ភាសាយើងឡើយ; ជាករណីយកិច្ចរបស់យើងទាំងអស់គ្នាត្រូវរក្សាខេមរភាសា ឲ្យគង់នៅជាភាសាកណ្ដាលក្នុងស្រុកយើងជាប់រៀងទៅ ។

---

១— អានថា ទេសៈភាសា ពីទេសៈ ប្រែថា ប្រទេស, ភូមិ ។

ភាសាគណ្ដាលបើស្រដីឲ្យចំទៅ មិនមែនជាភាសាយើងនិយាយទេ គឺជាភាសាសរសេរ ។ កាលបើខ្ញុំថាភាសាសរសេរផ្សេងពីភាសានិយាយដូច្នេះអ្នកអានគាបធ្ងល់ ព្រោះធ្លាប់ស្ដាប់ជាដូចគ្នា ។ សេចក្ដីពិត ភាសានិយាយនិងភាសាសរសេរខុសគ្នាច្រើនប្រការ ។ ពាក្យខ្លះគេនិយាយ តែគេមិនសរសេរ ឧ. អញ្ចឹងហើយ អញ្ចាំងៗ ម្ញឹងៗ ... ។ របៀបរៀនពាក្យនិយាយ និងរៀនពាក្យសរសេរប្លែកពីគ្នាច្រើន ឧ. ភាសានិយាយ ៖ «យប់មិញសត្វនេះសត្វហ្មើយ ។ យើ! ឋាវាមកពាសពេញតែម្ដង. សរសេរអ្វីក៏មិនបាន»; ភាសាសរសេរ ៖ "យប់មិញ សត្វមមាចមកច្រើនពាសពេញលើតុ ខ្ញុំរកសរសេរអ្វីពុំបានសោះ» ។

ភាសាដែលគេលែងប្រើទៅហើយក្នុងការនិយាយ ហៅថាភាសាស្លាប់ បានដល់ភាសាសំស្ក្រឹត បាឡី ឡាតាំង...។

ភាសាស្លាប់ទាំងនេះដែលគេបានរៀបចំទុករួចមកហើយ ។ នៅនឹងដែលឥតប្រែប្រួលព្រោះឥតជីវិត ។ ភាសាដែលនៅប្រើក្នុងការនិយាយ ហៅថាភាសារស់ ។ ឯភាសារស់តែងប្រែប្រួលទៅមិនឈប់ឈរដូចរុក្ខជាតិ ឬសត្វទាំងឡាយដែលមានជីវិត ។ ក្នុងការប្រែប្រួលនេះ ភាសានិយាយមានដំណើរលឿនជាងភាសាសរសេរ ។ ហេតុនេះបានជាមានពាក្យខ្លះគេនិយាយកល់គ្នាជារត់មាត់ តែពុំទាន់បញ្ចូលក្នុងពពួកពាក្យសរសេរនៅឡើយ, ពាក្យខ្លះចាស់យូរមកហើយលែងមានប្រើក្នុងភាសានិយាយទៅហើយ តែនៅមានប្រើក្នុងភាសាសរសេរ ។

ភាសាសរសេរដែលប្រែប្រួលដោយយឺតយូរ មកពីលោកបានរៀបចំកំដាប់ទុកក្នុងសាស្ត្រា សៀវភៅ តំក ។ ការរៀបចំភាសាខ្មែរដោយមួនមាំបំផុត ទើបនឹងមានឡើងក្នុងពេលថ្មីៗនេះទេ បើនិយាយឲ្យចំទៅគឺតាំងពីកាលបង្កើតវចនានុក្រម ។

វចនានុក្រម ជាច្បាប់ដែលយើងត្រូវប្រតិបត្តិតាម គឺសរសេរឲ្យត្រូវតាមទាំងអស់គ្នា ។ ការណ៍ដែលត្រូវសរសេរតាមវចនានុក្រមនេះ យើងទាំងអស់គ្នាត្រូវតែធ្វើទៅដោយគោរពដល់វិន័យ (discipline) ។ វិន័យត្រង់នេះមានសារៈសំខាន់ដល់ជាតិជាច្រើន ព្រោះថាបើយើងនៅតែសរសេររូបពាក្យតាមចិត្តរៀងខ្លួន ផ្សេងគ្នាទៅតាមវត្ត តាមសាលាដូចពីដើម ភាសាយើងនឹងរាប់ថាជាភាសាសំរាប់ជាតិមួយពុំបាន ; ជាតិយើងក៏នឹងរាប់ថាជាប្រជាជាតិ (nation) មួយពុំសម ។ ហេតុនេះសូមឲ្យបងប្អូនរួមជាតិទាំងឡាយ ព្យាយាមសរសេរពាក្យតាមរូបដែលមានក្នុងវចនានុក្រម ឲ្យបានជារបៀបដូចគ្នាទាំងអស់ ហើយសូមឲ្យមានសេចក្តីខ្មាសអៀនក្នុងចិត្ត កាលណាបើសរសេរក្លាត់ក្លាតខុសពីរូបពាក្យក្នុងវចនានុក្រម ដ្បិតសរសេរខុសដូច្នេះជាហេតុបំផែងឲ្យឃើញថា យើងខ្វះសេចក្តីសិក្សា ។ ខ្ញុំសង្ឃឹមថាមុខជាបងប្អូនទាំងឡាយគង់ទុកការសរសេររូបពាក្យដោយត្រឹមត្រូវតាមវចនានុក្រមនេះ ជា

កិត្តិយសមួយដ៏ខ្ពង់ខ្ពស់ ។

អ្នកខ្លះអាចសួរមកខ្ញុំវិញថា ៖ បើកាលណាយើងយល់ជាក់ថារូបពាក្យ (១) ដែលមានក្នុងវចនានុក្រមនោះខុសស្រឡះហោះ តើយើងនៅតែត្រូវសរសេរតាមដែរឬអី ? ខ្ញុំយល់ថាយើងត្រូវតែសរសេរតាមដែរដើម្បីរក្សាវិន័យ ។ ការសរសេរតាមនេះឯង ត្រូវបង្កើតនូវសិទ្ធិ (droit) សំរាប់យើងក្នុងការតវ៉ាសូមឲ្យកែតំរូវឡើង ។ ប៉ុន្តែដរាបណា ពាក្យនោះមិនទាន់បានកែប្រែតាមផ្លូវការទេ ដរាបនោះ យើងត្រូវតែសរសេរតាមបែបដដែល ។

នៅស្រុកបារាំង មានទីប្រជុំអ្នកប្រាជ្ញខាងអក្សរសាស្ត្រមួយសំរាប់ពិចារណាអារកាត់អំពីរឿងអក្សរសាស្ត្រ ដូចសាលាតុលាការជំនុំជំរះពីរឿងក្តីផ្សេង ៗ ។ ទីប្រជុំនេះបានបង្កើតឡើងនាកាលគេរៀបចំកំដាប់ភាសា បារាំងក្នុងភាគដំបូង

១— រូបពាក្យដែលពោលក្នុងទីនេះ បារាំងហៅថា orthographe, គណៈកម្មការវប្បធម៌បានសំរេចឲ្យហៅថាអក្ខរាវិរុទ្ធ (អាន អក្ខៈរ៉ា. . .) ។

នៃសតវត្សទី ១៧ រាង ៣០០ ឆ្នាំមកហើយ ។ ទីប្រជុំនេះហៅថាអាការដេមីបារាំងសែស ។ នៅស្រុកសៀម មានទីប្រជុំអ្នកប្រាជ្ញបែបនេះដែរ គេហៅថារាជបណ្ឌិតស្ថាន ។ ទីប្រជុំបែបនេះអាចនាំនូវប្រយោជន៍ជាច្រើនមកកាន់ប្រទេសជាតិជាទីស្រឡាញ់របស់យើង ដោយចំពោះក្នុងវេលានេះ ដែលយើងកំពុងរៀបចំកំជាប់ភាសារបស់យើង ។

## លក្ខណៈនៃភាសា

ពាក្យទាំងឡាយក្នុងភាសាមួយ ៗ យើងអាចយកមកពិនិត្យទៅតាមផ្លូវ ៣ ៖

១– យើងអាចពិនិត្យខាងសំឡេង ។ វិជ្ជាបែបនេះបារាំងហៅថា ឡាហ្វូណេទិក (la phonétique) ។

ខ្ញុំសូមសន្មតឈ្មោះថាសូរសាស្ត្រ (អានសូរៈសាៈស) ។ ពាក្យនេះមិនមែនពាក្យសំស្ក្រឹតទេ គឺជាពាក្យខ្មែរយកមកពីសំស្ក្រឹត (១) ។

១– ក្នុងសូរសាស្ត្រមានអធិប្បាយពីវិធីអានផង ។

២– យើងអាចពិនិត្យខាងរូបរបស់ពាក្យដែលប្រែប្រួលទៅតាម លិង្គ វចនៈ បុរិសៈ កាល និងមុខងាររបស់ពាក្យក្នុងប្រយោគ ។, ការប្រែប្រួលបែបនេះមានច្រើនក្នុងភាសាអំបូរ ឥណ្ឌូ-អឺរ៉ុប ដូចជាសំស្ក្រឹតបាលីនិងភាសាក្នុងទ្វីបអឺរ៉ុប ។ ក្នុងភាសាយើងមិនសូវមានទេ ។ វិជ្ជាខាងរូបរបស់ពាក្យនេះបារាំងហៅថា ឡាម៉រហ្វូឡូស៊ី (la morphologie), ខ្ញុំសូមសន្មតហៅថារូបសាស្ត្រ (អាន រូប៉ៈ សាស)(១) ។

៣– យើងអាចពិនិត្យខាងអត្ថៈរបស់ពាក្យ ព្រមទាំងប្រវត្តិរបស់ពាក្យ ។ បារាំងហៅវិជ្ជាផ្នែកនេះថា ឡាសេម៉ង់ទិក (la sémantique) ខ្ញុំសូមសន្មតហៅថានិឃណ្ដសាស្ត្រ (២) (អាននិឃាន់-ដៈសាស) ។

របស់ទាំង ៣ យ៉ាងនេះជាបុគ្គលិកលក្ខណៈ (៣) នៃ

---

១– ក្នុងភាសាបារាំងនិងភាសាអំបូរឥណ្ឌូ-អឺរ៉ុបឯទៀត រូបសាស្ត្រជារបស់ដែលសិក្សាដោយចំពោះក្នុងវេយ្យាករណ៍ ។ ២–បណ្ដាពាក្យទាំងអស់ក្នុងភាសាបារាំងហៅថា (vocabulaire) សំស្ក្រឹតហៅថានិឃណ្ដុៈ ។

៣– Caractères individuels, Caractéristiques : អាន បុគ-គៈ-លិ-កៈ លក្ខៈណៈ ។

ភាសានីមួយ ៗ

## អំបូរភាសា (១)

**ភាសា**ដែលប្រហាក់ប្រហែលគ្នាខាងផ្លូវសូរសាស្ត្រ លោក**ចាត់ជា**ភាសាអំបូរជាមួយគ្នា ៗ ដោយអាស្រ័យគោល**ការនេះ** ភាសាសំស្ក្រឹត បាលី និងភាសាក្នុងប្រទេសឥណ្ឌា មានភាសាហិណ្ឌូស្ថានីជាដើម, ភាសាពែរ្ស អារ្មេនី ក្រិក ឡាតាំង និងភាសាជាច្រើន ដែលប្រើក្នុងទ្វីបអឺរ៉ុបមានភាសាបារាំង រុស្ស៊ី អាល្លឺម៉ង់ជាដើម, ភាសាទាំងនេះនៅក្នុងអំបូរធំមួយ ហៅថាអំបូរឥណ្ឌូ-អឺរ៉ុប ។ អ្នកប្រាជ្ញខាងភាសាសាស្ត្រ យល់ព្រមគ្នាថាក្នុងសម័យបុរាណព្រេងនាយ មានភាសាមួយហៅថាភាសាឥណ្ឌូ-អឺរ៉ុប ។ ភាសាឥណ្ឌូ-អឺរ៉ុបដែលគេប្រើក្នុងវេលា**ព្រេងនាយនោះ** គឺប្រើនៅលើដំរួល**ខ្ពស់មួយដែលបារាំងហៅថា**ប៉ាល់មៀរ (Palmyr) ។ តាមភូមិ-សាស្ត្រដំរួលប៉ាល់មៀរនេះជាទួលខ្ពស់បំផុតក្នុងលោក នេ

១— ហៅថាត្រកូលភាសា ពូជភាសា ឬវង្សភាសាក៏បាន ។

ទុកដូចជាដំបូលលោក ។ តាមយោបល់អ្នកប្រាជ្ញខ្លះ ទួលប៉ាល់មៀរមិនជាអ្វីក្រៅពីភ្នំមេរុនោះទេ ។ ភ្នំមេរុមាន ៣ ចំណែកតាមសេចក្តីជឿរបស់មនុស្សក្នុងជម្ពូទ្វីបបុរាណ ។ ចំណែកខាងលើជាទីអាស្រ័យរបស់ទេវតា ហៅថាសុមេរុ ឬតាមភាសាខ្មែរថាព្រះសុមេរុ; ចំណែកបន្ទាប់ចុះមកហៅថាឧបមេរុ ជាទីអាស្រ័យរបស់មនុស្សសត្វទាំងឡាយ; ចំណែកខាងក្រោមហៅថាកុមេរុ ជាឋាននរក ។ ពាក្យ ឧបមេរុ មាន ៤ ព្យាង្គ។ ក្រោយគមកព្យាង្គខាងមុខ(ឧ)និងព្យាង្គខាងក្រោយ (រុ) បាត់បង់ទៅ, នៅសល់តែព្យាង្គពីរកណ្តាល ប៉ះម៉េរ ។ ក្នុងទីបំផុត ប៉ះម៉េរ ក៏ក្លាយទៅជា ប៉ាល់មៀរ (Pamer > Palmyr) ។ តាមសេចក្តីជឿស្មានរបស់បុរាណរៀងមកថាអំពីឧបមេរុនេះ មនុស្សក្នុងសម័យព្រេងនាយបានបែកគ្នា ទៅនៅឯទីឋានផ្សេង ៗ មកក្នុងប្រទេសឥណ្ឌាខ្លះ ទៅឯប្រទេសបែរ្សនិងទ្វីបអឺរ៉ុបខ្លះ នាំយកទាំងភាសាដើមឥណ្ឌូ-អឺរ៉ុបនោះ

ទៅផង ៗ ភាសាឥណ្ឌូ-អឺរ៉ុប កាលដែលផ្សាយទៅតាមទិសទីផ្សេងគ្នាដូច្នេះ ក៏ប្រែប្រួលល្អៀងទៅតាមទំនងផ្សេងៗគ្នា ៗ ភាសាដើមឥណ្ឌូ-អឺរ៉ុបនេះ គ្មានសល់ដំណាលមកដល់យើងសព្វថ្ងៃនេះទេ, នៅសល់តែភាសាស្លាប់ដែលយារតមក គឺសំស្ក្រឹតនិងបាលី នៅប្រទេសឥណ្ឌា, ភាសាសេន្ទ (zend) នៅប្រទេសពែរ្ស, ភាសាក្រិកឡាតាំង នៅទ្វីបអឺរ៉ុប ៗ

អំបូរភាសាមានច្រើន ៗ ខ្ញុំនាំយកខ្លះមកពោលក្នុងទីនេះ ៗ គឺអំបូរភាសា សេមីទិក (sémitique) ដែលមានភាសាអារ៉ាប់ ជ្វីហ្វ (juif) អាស៊ីរីយ៉ាំង អាប៊ីស៊ីនី ជាដើម ៗ អំបូរធំមួយទៀត គឺអំបូរម៉ាឡាយូប៉ូលីណេស៊ី (malayo-polynésienne) ៗ ក្នុងអំបូរនេះ មានភាសាចាម ភាសាម៉ាឡាយូ និងភាសាកោះម៉ាដាកាស្កា សុម៉ាត្រា ជ្វា បរណេអូ ហ្វីលីពីន . . ៗ ..

ដែលខ្ញុំអធិប្បាយអំពីអំបូរភាសាក្នុងទីនេះ គឺដើម្បីមិនឲ្យអ្នកអានណាដែលមិនទាន់បានឮនិយាយអំពីអំបូរភាសា ទើរ

គំនិតមិនយល់ច្បាស់នូវអត្ថៈនៃពាក្យនេះ នោះប្រការមួយ, ប្រការមួយទៀត ដើម្បីតាំងទីឋានរបស់ភាសាខ្មែរ នៅក្នុងចំណោមអំបូរភាសាទាំងឡាយ ។

ភាសាខ្មែរ មានពាក្យសំស្ក្រឹតនិងបាលីណាយបញ្ចូលផងជាច្រើនក្រៃលែង ប៉ុន្តែភាសាយើងមិនមែននៅក្នុងអំបូរឥណ្ឌូ-អឺរ៉ុបទេ ព្រោះរបស់ដែលយើងមានដូចខ្លះនឹងភាសាក្នុងត្រកូលនេះ គ្រាន់តែជានិយណ្ឌសាស្ត្រ ( sémantique ) គឺខាងសេចក្ដីរបស់ពាក្យ ( vocabulaire ) តែខុសគ្នាខាងសូរ-សាស្ត្រ ( phonétique ) គឺខាងវិធីបញ្ចេញសំឡេង វិធីអាន ហើយខុសគ្នាខាងរូបសាស្ត្រ (morphologie) គឺវិធីប្រើពាក្យសំរេចរូបពាក្យ គឺខាងវេយ្យាករណ៍ (grammaire) ដូចនឹងអធិប្បាយក្នុងសង្កាត់តទៅនៃសៀវភៅនេះ ។

ភាសាសៀមនិងភាសាខ្មែរស្រដៀងគ្នាជាច្រើន ដោយហេតុ ៣ ប្រការ ៖ ១)– ព្រោះសៀមខ្ចីពាក្យពីយើងទៅប្រើច្រើនក្រៃពេកណាស់ ខ្ចីពាក្យខ្មែរសុទ្ធក៏មាន ខ្ចីពាក្យខ្មែរ

ដែលមកពីសំស្ក្រឹតក៏មាន; ២)– ព្រោះសៀមនិងខ្មែរខ្ចីពាក្យពីបាឡីមកប្រើដូចគ្នា ដៀតកាន់សាសនាជាមួយគ្នា, ៣)– ព្រោះតាំងពីកាលសៀមមកវាយកំទេចយើងបង្ហើយដៃ នៅលង្វែកក្នុងចុងសតវត្សរ៍ទី ១៦ (១) តមកនោះ សៀមមានសងពាក្យមកឲ្យខ្មែរវិញខ្លះ ៗ ភាសាសៀមស្រដៀងគ្នានឹងភាសាខ្មែរខាងនិយណ្ឌសាស្ត្រ និងរូបសាស្ត្រ តែខុសគ្នាខាងសូរៈសាស្ត្រ ៗ វិធីអានសៀមផ្សេងគ្នាពីវិធីអានខ្មែរដូចនឹងមានអធិប្បាយក្នុងវិធីអានខាងក្រោយនេះ, រួចសំឡេងក្នុងភាសាសៀមមានខ្ពស់មានទាប ឯសំឡេងក្នុងភាសាខ្មែរជាសំឡេងស្មើ ៗ ហេតុនេះ ទើបកប់ជាអំបូរជាមួយគ្នាពុំបាន ៗ ភាសាសៀមនៅក្នុងអំបូរភាសាថៃដែលមានភាសាលាវ និងភាសាថៃតូចៗ ឯទៀតដូចជា លឺ ងៀវ ឈៀង ធាន ដែលមានប្រើនៅដែនតុងកឹងខាងលើ នៅជាយដែនចិនខាង

---

១)– សករាជនិងសតវត្សរ៍ដែលប្រើក្នុងសៀវភៅនេះ ប្រើតាមគ្រិស្តសករាជទាំងអស់ ។

ត្បូង និងខេត្តកូមាខាងត្បៀសាន ។

ភាសាខ្មែរនៅក្នុងអំបូរភាសាមួយហៅថាអំបូរមន-ខ្មែរ ។ ក្នុងអំបូរនេះមានខ្មែរ មន ហើយនិងជាតិព្រៃ ដូចជា ប៉ាំទ្បូង នៅជាប់នឹងមន រៀង និង វ៉ា នៅត្រើយខាងកើតទន្លេសាល្វិន ខាងជើងប្រទេសសៀម, ជិង នៅប្រទេសសៀមភាគខាងជើង, ឃ្មុំ ម្លាឃ្មុំ នៅខាងលួងព្រះបាងនិងវៀងចន្ទន៍ ហើយនិង ព័រ ជង ក្លួយ ស្ទៀង ព្នង . . . នៅក្នុងប្រទេសខ្មែរ ។

ភាសាទាំងនេះស្រដៀងគ្នាដោយលក្ខណៈទាំង ៣ គឺ ទាំងសូរសាស្ត្រ រូបសាស្ត្រ និងនិឃណ្ឌុសាស្ត្រ ។ ក្នុងអំបូរ មន-ខ្មែរ មានតែមននិងខ្មែរពីរជាតិនេះទេ ដែលមានអក្សរប្រើ ។ រួចក្នុងបណ្ដាជាតិទាំងពីរនេះ នៅគង់ជាប្រជាជាតិ (nation) តែខ្មែរមួយទេ ។ ឯមនលាយជាតិបាត់ទៅ តាំងពីចុងសតវត្សរ៍ទី ១៣ ដោយការបៀតបៀន

របស់កូមាទិនសៀម ។

*

* *

## ភាគទី ១

### ស្វរសាស្ត្រ

មនុស្សយើងនិយាយគ្នា ដោយអាស្រ័យសំឡេង ។ វិជ្ជាខាងបែបសំឡេង ដែលប្រើក្នុងភាសានោះ បារាំងហៅថាហ្វូណេទិក (la phonétique) ។ តាមអក្សរយើង គួរប្រែថា សព្ទសាស្ត្រ (អានសាប់ទៈ-សាស) ព្រោះ សព្ទ ប្រែថាសំឡេង សាស្ត្រ ប្រែថាវិជ្ជា ឬការសិក្សា; ប៉ុន្តែ តាមសេចក្ដីអធិប្បាយក្នុងវចនានុក្រមសំស្ក្រឹត · បារាំង អត្ថៈ នៃពាក្យ សព្ទសាស្ត្រ ធំទូលាយដល់ស៊ីសេចក្ដីថា វេយ្យា-ករណ៍ទាំងមូល ។ ដូច្នេះ ដើម្បីកុំឲ្យមានសេចក្ដីភាន់ច្រឡំ នៅបាន ខ្ញុំសូមយកពាក្យ ស្វរសាស្ត្រ (អានសូរៈសាស)

មកសន្មតឲ្យឈ្មោះវិជ្ជានេះ ។ ស្វរៈ មកពីសំស្ក្រឹត ស្វរ ប្រែថា សូរ សំឡេង ។

សំឡេងដែលយើងប្រើក្នុងការនិយាយប្រស្រ័យគ្នា យើងកត់ទុកដោយអាស្រ័យសញ្ញាផ្សេងៗ ។ សញ្ញានោះមានឈ្មោះថា អក្សរ ។ ហេតុនេះក្នុងលំដាប់តទៅ យើងនឹងនាំមកពិនិត្យនូវអក្សរទាំងពួង ដែលប្រើក្នុងភាសាខ្មែរ ។

*

* *

## ផ្នែកទី ១ -

### អំពីអក្សរ

អក្សរ ជាពាក្យក្លាយពីសព្ទ(១)សំស្ក្រឹត ត្រង់គ្នានឹង

---

១— ពាក្យសព្ទគឺពាក្យបាឡីឬសំស្ក្រឹត ដែលមិនទាន់ផ្សំនឹងវិភត្តិ (បារាំងហៅថា thème) ឧ. ជន ជាពាក្យសព្ទ ។ កាលបើផ្សំនឹងវិភត្តិ (flexion) ទៅជាជនោ (forme sujet =nominatif sing.) ជនា (nominatif plur.) ជនំ (forme compl. dir. accusatif sing.) ។ល។ លោកហៅថាបទ ។

ពាក្យសព្ទបាឡី អក្ខរៈ ។ ខ្មែរយើងប្រើពាក្យទាំងពីរនេះជួសគ្នាបាន ។ យើងមានអក្សរៈ ៥៤ អង្គ គឺស្រៈ ២១ អង្គ និងព្យញ្ជនៈ ៣៣ អង្គ ។

ក)- ស្រៈ

ពាក្យខ្មែរ ស្រៈ មកពីពាក្យសព្ទបាឡី សរ (អាន សៈរៈ) ។ ពាក្យសព្ទបាឡី សរ ត្រង់នឹងពាក្យសព្ទសំស្ក្រឹត ស្វរ (អាន ស្វៈរៈ) ។ ពាក្យសព្ទសំស្ក្រឹតនេះបានក្លាយមកជាពាក្យសព្ទបាឡី (សរ) ដោយលុបជើង វ ចោល ហើយបានក្លាយមកជាពាក្យខ្មែរ ស្វូរ ដោយប្រែជើង វ (្វ) ជាស្រៈ ូ ។ បានសេចក្ដីថាសូរ សំឡេង ។ ក្នុងភាសាបារាំង ស្រៈហៅថា វ៉ូយ៉ែល (voyelle) ពាក្យនេះក៏មកពីពាក្យមូលបទ (racine) ដែលប្រែថា សំឡេងដូចគ្នាដែរ (voix)។

ស្រៈទាំងឡាយតាមគោលវិជ្ជាមាន ២១ អង្គ ។ គឺ៖

អ អា អិ អី អឹ អឺ អុ អូ អួ អើ អឿ អៀ អេ អែ អៃ

អោ អៅ អុំ អំ អាំ អះ ។

នេះហៅថាស្រៈពេញតួ ។ កាលណាត្រូវសរសេរបញ្ចូលនឹងព្យញ្ជនៈ ស្រៈទាំងនេះនឹងមានរូបដូច្នេះវិញ៖

– –ា –ិ –ី –ឹ –ឺ –ុ –ូ –ួ –ើ –ឿ –ៀ

–េ –ែ –ៃ –ោ –ៅ –ុំ –ំ –ាំ –ះ ។

សេចក្ដីសង្កេត.– តាមរបៀបសរសេរបែបនេះ យើងសង្កេតឃើញថា ស្រៈ អ គ្មានរូបគ្មានអង្គទេ ។ អក្សរ អ លោកដាក់ចូលក្នុងចំពួកព្យញ្ជនៈ អាចប្រកបនឹងស្រៈបានដូចព្យញ្ជនៈឯទៀត ។ ព្យញ្ជនៈទាំងឡាយរមែងមានស្រៈ អ ក្នុងខ្លួនជាដរាប ។ កាលសរសេរជាពាក្យទៅហើយ បើចង់សំដែងឲ្យដឹងថាព្យញ្ជនៈអង្គណាគ្មានស្រៈ អ អាស្រ័យទេ នោះលោកយកព្យញ្ជនៈអង្គនោះដាក់តំរួតពីលើព្យញ្ជនៈ ដែលនៅបន្ទាប់ពីក្រោយ ដូចក្នុងពាក្យ ប្ដី ក្ដោ ពន្ធ ។ ព្យញ្ជនៈ ប ក ន ក្នុងទីនេះគ្មានស្រៈ អ អាស្រ័យទេ ។ ដូច្នេះយើង

ឃើញថាព្រោះតែស្រៈ ឫ ឬ គ្មានរូប បានជាយើងត្រូវសរសេរអក្សរតំរួតលើគ្នា នាំឱ្យយើងបង្កើតជើងអក្សរសំរាប់តំរួត ។ ជាការណ៍នាំឱ្យមានរូបអក្សរច្រើនឡើង មួយជាពីរ លំបាកខាងសរសេរ ខាងបោះពុម្ព ដែលខានសូត្ររៀនឱ្យចាំផង ។ សេចក្តីសន្និដ្ឋានគឺថាបើយើងបង្កើតរូបអក្សរមួយអង្គ សំរាប់តែស្រៈ ឫ ឡើង ហើយយើងសន្មតថាព្យញ្ជនៈទាំងឡាយគ្មានស្រៈ ឫ ក្នុងខ្លួនស្រាប់ទេ នោះយើងនឹងអាចសរសេរជើងគួរអក្សរបានដូចអក្សរបារាំង មិនចាំបាច់តំរួតលើគ្នា មិនចាំបាច់មានជើងព្យញ្ជនៈឡើយ ។ ចំនួនរូបអក្សរយើង ក៏នឹងថយចុះមកជាច្រើន, ហើយជួរបន្ទាត់អក្សរ ក៏នឹងធ្វើឱ្យញឹកបានជាងសព្វថ្ងៃដូចជួរបន្ទាត់អក្សរបារាំង ។

ក្រៅពីរូបដែលបានពោលមកហើយ ស្រៈពេញតួខ្លះ ក្នុងបណ្តាស្រៈ ២១ អង្គនោះ មានរូបមួយយ៉ាងទៀត ។ គឺៈ

ឥ ឦ ឧ ឩ ឯ ឭ ឱ ឳ ។

ក្រៅពីស្រៈ ២១ អង្គ យើងនៅមានស្រៈពេញតួ៤អង្គ

ទៀតជាពិសេស ៗ គឺ៖

ឫ ឬ ឭ ឮ ។

ស្រៈពេញតួ ៤ អង្គនេះ ជាស្រៈសំស្រ្កឹតដោយចំពោះ ។ សំឡេងស្រៈទាំងឡាយ នឹងមានអធិប្បាយទៅខាងក្រោយក្នុងវិធីអាន ។

## ឈ្មោះសញ្ញាខ្លះដែលប្រើក្នុងស្រៈ

ា.- ហៅថាតាញយារ ប្រើក្នុងស្រៈ អា អោ អៅ និង អាំ ។

ុ.- ហៅថារុកដើង ប្រើក្នុងស្រៈ អុ និង អុំ ។

េ.- ហៅថាបាំងឈើ ប្រើក្នុងស្រៈ អើ អឿ អៀ អេ អែ អៃ អោ អៅ ។

ំ.- ហៅថានំលើឬនិគ្គហិត ។ និគ្គហិតជាពាក្យស័ព្ទបាឡី ក្នុងភាសាសំស្រ្កឹតហៅថាអនុស្សារៈ ។ ប្រើក្នុងស្រៈ អុំ អំ អាំ និង អ៊ំ ។

ះ.– ហៅថា រះមុខ តាមសំស្ក្រឹតហៅថា វិសជ្ជនីយ ឬ វិសគ៌ ។ ក្នុងភាសាបាឡីគ្មានប្រើសញ្ញានេះទេ ។ ក្នុងភាសាខ្មែរ វិសជ្ជនីយអាស្រ័យបានតែនឹងស្រៈ អ (ជ្រះ), អិ (ជិះ), អឹ (ភ្ញឹះ), អុ (ប៉ុះ), អេ (បេះ), អែ (កែះ), និង អោ (ទោះ) ។ ការសរសេរវិសជ្ជនីយបញ្ចូលនឹងស្រៈឯទៀតក្រៅពីនេះ ទុកជាខុស ។ ដូចជា ខ្លះ បាះ លោកឲ្យសរសេរជា ខ្ទះ បាស់ ទើបត្រូវ ។

## ១– ស្រៈខ្លី ឬ រស្សៈ

ស្រៈដែលមានសំឡេងខ្លី លោកហៅតាមភាសាបាលីថា រស្សៈ ។ ស្រៈខ្មែរដែលកប់ថាខ្លីនោះគឺ ៖

អិ អី អឹ អុ អៃ អៅ អុំ អំ អាំ អះ ( ១០ អង្គ ) ។

## ២– ស្រៈវែង ឬ ទីឃៈ

ស្រៈដែលមានសំឡេងវែង លោកហៅតាមភាសាបាលីថា ទីឃៈ ។ ស្រៈខ្មែរដែលកប់ថាវែងនោះគឺ ៖

អ អា (អ៊ី) អី អូ អួ អើ អឿ អៀ អេ អែ អោ

( ១១ អក្ខរ ) ។

## ៣– ស្រះសុទ្ធ និងសំយុត្តស្រះ

ក្នុងភាសាបាលី សំស្ក្រឹត បារាំង . . . លោកចែកស្រះជាស្រះសុទ្ធ (voyelles simples) និងស្រះផ្សំ ឬសំយុត្តស្រះ ( អាន ស័ង យុត តៈស្រះ ) (diphtongues) ។ ស្រះផ្សំគឺជាស្រះសុទ្ធដែលបញ្ចូល ឬផ្សំជាមួយនឹងស្រះមួយអក្ខរទៀតដែលជាស្រះសុទ្ធដែរ ឬជាអឌ្ឍស្រះ ( អាន អាត់-ធៈ-ស្រះ)[1] ។ ក្នុងភាសាខ្មែរ ការបែងចែកយ៉ាងនេះ នឹងធ្វើឲ្យជាក់ច្បាស់ឥតប្រកែកបាននោះ ពុំងាយទេ ព្រោះភាសាយើងសំបូណ៌ទៅដោយស្រះជាងភាសាដែលពោលមកហើយនោះ ជាច្រើន ។ យើងបានឃើញហើយថា ស្រះខ្មែរមានលើសពី ២១ អក្ខរ ។ បើទុកជាយើងមានត្រឹមតែ២១អក្ខរ គឺដោយ សំឡេងស្រះទាំងនោះ គង់ប្រែប្រួលទៅតាមព្យញ្ជនៈ

---

១– ចូរមើលសេចក្តីអធិប្បាយពីអឌ្ឍស្រះ នៅទំព័រ ៤០ ។

ជាឃោសៈឬអឃោសៈ[១] ។ កាលបើយើងបញ្ចូលស្រៈ ២១ អង្គ នោះ ទឹងព្យញ្ជនអឃោសៈដូចជា ក ស្រៈនោះក៏ទីងនៅជាអឃោសៈ អ អា អិ អី ។ល។ កាលបើយើងបែរជាឲ្យស្រៈទាំងនោះនឹងព្យញ្ជនៈឃោសៈដូចជា គ វិញ ស្រៈនោះក៏នឹងប្រែទៅជាឃោសៈ អ៊ អ៊ា អ៊ិ អ៊ី ។ល។

ដូច្នេះស្រៈយើង ២១ អង្គ ដោយពិតត្រឡប់ហាងដល់ ៤២ អង្គ ។

ដើម្បីឲ្យអ្នកអានខ្លះ ដែលមិនទាន់យល់ច្បាស់ត្រង់ស្រៈសុទ្ធនិងស្រៈផ្សំ បានដឹងន័យកុំងវៀងនេះបន្តិចបន្តួចយើងនឹងយកស្រៈអឃោសៈខ្លះមកចែក ដើម្បីជាឧទាហរណ៍ដូចតទៅនេះ ៖

អ អា អិ អី អុ អូ . . . ជាស្រៈសុទ្ធ ។

អឹ អួ អឿ អៃ អៅ . . . ជាសំយុត្តស្រៈ ព្រោះ

---

១– ចូរមើលទំព័រ ៤០ ។

អឺ គឺ អិ + យ

អួ - អូ + អា

អៀ - អី + អា

អៃ - អា + យ់

អៅ - អា + វ៌ ។

១|- ព្យញ្ជនៈ

ព្យញ្ជនៈជាពាក្យសព្ទបាឡី ត្រង់នឹងពាក្យសព្ទសំស្រ្កឹត វ្យញ្ជនៈ ប្រែបានច្រើនយ៉ាង ។ ប្រែតាមនិរុត្តិសាស្រ្ត (étymologie) ថា គ្រឿងសំគាល់, អាការសំដែងឲ្យឃើញ ជាក់ច្បាស់ ។

ព្យញ្ជនៈ មាន ៣៣ អង្គ គឺ ៖

កខគឃង ចឆជឈញ ដឋឌឍណ តថទធន

បផពភម យរលវសហឡអ ។

## ១- វគ្គ

ព្យញ្ជនៈ ៣៣ អក្ខរៈនេះ បុរាណាចារ្យលោកបានចាត់ជា

របៀបដាក់រៀងបន្ទា ដោយបាននេរគ្នាន់យ៉ាងល្អិតល្អ ៗ

លោកចែកជាវគ្គប្រាំអង្គ តាមទីកើតនៃសម្លេងតាំងពីក្នុងក

រហូតដល់បបូរមាត់ ៗ វគ្គទាំងអស់មាន ៥ គឺ៖

វគ្គ ក មាន ក ខ គ ឃ ង

វគ្គ ច - ច ឆ ជ ឈ ញ

វគ្គ ដ - ដ ឋ ឌ ឍ ណ

វគ្គ ត - ត ថ ទ ធ ន

វគ្គ ប - ប ផ ព ភ ម

ក្រៅពីនោះ ហៅថាព្យញ្ជនៈឥតវគ្គ (អវគ្គ) ឬសេស

សល់ពីវគ្គ (សេសវគ្គ) មានដល់ព្យញ្ជនៈ យ រ ល វ

ស ហ ឡ អ ។

## ២- ឋានកើតនៃព្យញ្ជនៈ

តាមកន្លែងកើត លោកចែកសម្ដែងដូចតទៅនេះ

កណ្ឋជ: (gutturales) កើតនៅក គឺ ក ខ គ ឃ ង ហ អ;

តាលុជ: (palatales) កើតនៅក្រអូមមាត់ គឺ ច ឆ ជ ឈ ញ យ;

មុទ្ធជ: (cérébrales ou linguales) កើតនៅក្បាល គឺ ដ ឋ ឌ ឍ ណ រ ឡ;

ទន្តជ: (dentales) កើតនៅធ្មេញ គឺ ត ថ ទ ធ ន ល ស;

ឱដ្ឋជ: (labiales) កើតនៅបបូរមាត់ គឺ ប ផ ព ភ ម វ ។

ក្នុងចំនួនអក្សរអម្បាលនេះ នៅមានអក្សរខ្លះដែលលោក

ទុកដោយឡែកផ្សេងទៅទៀត ហៅថានាសិកជៈ (អ.ន នា-សិ-កៈ-ជៈ) និងអឌ្ឍស្រៈ ។

នាសិកជៈ– គឺអក្សរដែលកើតនៅកន្លែងដូចពោលមក ហើយផង ព្រមទាំងកើតក្នុងច្រមុះផង (nasales) ។ គឺ ង ញ ណ ន ម (ដែលលោកហៅមួយយ៉ាងទៀតថា អក្សរចុងវគ្គ ឬ វគ្គន្តៈ) និងនិគ្គហិត ( ំ ) ដែលបញ្ចេញសំឡេងដូចខ្យល់ ម ។

អឌ្ឍស្រៈ (semi-voyelle)– ប្រែថាស្រៈពាក់កណ្ដាល (ព្យញ្ជនៈពាក់កណ្ដាល) បានដល់ យ និង វ ។

យ ត្រង់គ្នានឹងស្រៈ អ៊ិ (ឬ អិ អី) ។ ពាក្យបច្ចុប្បន្ន ភី ពីរ ប្រាំពិល សឹង ក្នុងអតីតកាល លោកចារឹកក្នុងរូបជា

វ្យ វ្យរ ប្រាំវ្យល ស្យង ។

វ ត្រង់គ្នានឹងស្រៈ អ៊ូ ( ុ > ូ ) ។

ឧ. ស្វរ (សំស្ក្រឹត) > សួរ

បន្ទ្វលិ (ខ្មែរបុរាណ) > បន្ទូល

ផ្ទ្វន៑ (– „ –) > ផ្ទូន ។

## ៣– ឃោសៈ – អឃោសៈ

ព្យញ្ជនៈសំឡេងគ្រលួច បានឲ្យហៅថាអឃោសៈ (អាន អៈ-ឃោ-សៈ) (sourdes) ប្រែថាសំឡេងមិនគឹកកង ៗ ព្យញ្ជនៈចំពូកនេះ តាមសំឡេងខ្មែរ បានដល់៖

ក ខ ចឆ ដឋណ តថ បផ សហឡអ។

ព្យញ្ជនៈឯទៀតសំឡេងគ្រលរ ៗ បានឲ្យហៅថាឃោសៈ (sonores) ប្រែថាគឹកកង ៗ ព្យញ្ជនៈចំពូកនេះ តាមសម្លេងខ្មែរ បានដល់៖

គឃង ជឈញ ឌឍ ទធន ពភម យរលវ ។

សេចក្ដីសង្កេត.-- ការបែងចែកព្យញ្ជនៈជាឃោសៈ អឃោសៈនេះខុសពីក្នុងភាសាបាឡីសំស្ក្រឹតដោយអន្ទើ ព្រោះ ព្យញ្ជនៈខ្មែរទាំងពួង មិនបញ្ចេញសម្លេងដូចក្នុងភាសាទាំងពីរ

នោះទេ ។ ដូចយ៉ាងព្យញ្ជនៈសម្លេងគ្រលួច ណ ហ ឡ ក្នុងភាសាបាលីលោកហៅថា ឃោសៈ (សម្លេងគ្រលរ) ។ ហេតុនេះ បើយើងហៅសម្លេងគ្រលរ សម្លេងគ្រលួច ដូចពាក្យឃោសៈអឃោសៈដូចជាត្រូវល្អជាង ។

## ៤–សិថិល–ធនិត

ព្យញ្ជនៈទី ១ និងទី ៣ ក្នុងវគ្គទាំង ៥ គឺ ក គ ច ជ ដ ឌ ត ទ ប ព លោកហៅតាមភាសាបាលីថា សិថិល ប្រែថា ធូរ រលុង ។ តាមសម្លេងខ្មែរ ព្យញ្ជនៈចំពូកនេះ បើរាប់ជាព្យញ្ជនៈសម្លេងតឹងដូចជាសមជាង ។

ព្យញ្ជនៈទី ២ និងទី ៤ ក្នុងវគ្គទាំង ៥ គឺ ខ ឃ ឆ ឈ ឋ ឍ ថ ធ ផ ភ លោកហៅតាមភាសាបាលីថាធនិត ប្រែថា ព្រួសតឹង ។ តាមសម្លេងខ្មែរ ព្យញ្ជនៈចំពូកនេះ គួរទុកជាព្យញ្ជនៈសម្លេងធូរ ។

សេចក្ដីប្រែទាំងពីរ តាមអក្ខរៈនេះ មិននាំឲ្យយើងក្លឹ

ប៉ុន្មានទៀត ៗ ការណ៍ដែលគួរចាំនោះគឺថា ធនិតជាសិថិល ផ្សំនឹង ហ (aspirées) ៗ

១. ក + ហ > ខ

គ + ហ > ឃ

ច + ហ > ឆ

ជ + ហ > ឈ

...ៗល ៗ...

ក ច ដ ត ប ជាសិថិលអឃោសៈ ៗ

គ ជ ឌ ទ ព ជាសិថិលឃោសៈ ៗ

ខ ឆ ឋ ថ ផ ជាធនិតអឃោសៈ ៗ

ឃ ឈ ឍ ធ ភ ជាធនិតឃោសៈ ៗ

គ/– វណ្ណយុត្តិ

ក្នុងការកត់សំរួលក្នុងភាសាខ្មែរ ក្រៅអំពីស្រៈនិងព្យញ្ជនៈ យើងនៅប្រើសញ្ញាមួយយ៉ាងទៀត ហៅថាវណ្ណយុត្តិ (signes

acritiques) ។ វណ្ណយុត្តិជាសញ្ញាសំរាប់កែលំអៀងសម្លេង ស្រៈនិងព្យញ្ជនៈ ឲ្យប្រែទៅតាមត្រូវការ ។ វណ្ណយុត្តិមាន ដូចរៀបរាប់តទៅនេះព្រមទាំងវិធីប្រើផង ៖

## ១– មូសិកទន្ត[1]

អាន មូ-សិ-កៈ-ទាន់ ។ មូសិកទន្ត ប្រែតាមអក្សរៈ ថា ធ្មេញកណ្ដុរ ។ ហៅតាមពាក្យសាមញ្ញថាសក់ពីរ ឬបុកពីរ ។ មូសិកទន្ត ប្រើសំរាប់ធ្វើព្យញ្ជនៈខ្លះឲ្យទៅជា អឃោសៈ ។

ព្យញ្ជនៈដែលទទួលមូសិកទន្តបាន ឬបើនឹងស្រដីមួយយ៉ាងទៀតថា ព្យញ្ជនៈដែលសំឡាប់បាននោះ គឺ ៖

១) ព្យញ្ជនៈចុងវគ្គ ៣ ង ញ ម,

២) ព្យញ្ជនៈអវគ្គ ៣ យ រ វ,

របស់អក្សរដែលមានសម្លេងគ្រលរ ។ កាលសំឡាប់ហើយ សម្លេងត្រឡប់ជាគ្រលួចវិញ ង៉ ញ៉ ម៉ យ៉ រ៉ វ៉ ។ ព្យញ្ជនៈ

សម្លេងគ្រលរ ៦ អក្ខរនេះ អាចទៅជាសម្លេងគ្រលួច ដោយហេតុតែតាំងរបស់ខ្លួនក្នុងពាក្យនិមួយ ៗ (valeur de position) ដូចក្នុងពាក្យ ផ្កា ប្រាជ្ញា សីមា... ។ ដូច្នេះក្នុងពាក្យចំពូកនេះ មិនត្រូវប្រើមូសិកទន្តទេ (មើលក្នុងវិធីអានខាងក្រោយនេះ) ។

ព្យញ្ជនៈសម្លេងគ្រលរឯទៀតដូចជា គឃ ជឈ ង ល... មិនត្រូវសំឡាប់ឲ្យទៅជាសម្លេងគ្រលួចទេ ព្រោះមានព្យញ្ជនៈសម្លេងគ្រលួចដែលត្រង់គ្នាស្រាប់ហើយ ដូច កខ បឆ ណកឡ... ។

៣) ព្យញ្ជនៈសម្លេងគ្រលួច ១ ឬ ទៅជាសម្លេងគ្រលួចមួយ យ៉ាងទៀត ឬ(១) . ។

---

១– ប មិនអាចទៅជា ប៉ បានដោយលំនៅរបស់ខ្លួនក្នុងពាក្យនីមួយ ៗ ទេ ។ បើពុំនោះសោត សំបារ ចម្បាប់ តម្បាញ ត្រូវអានថា សំ-ប៉ា ចំ-ប៉ាប់ តំ-ប៉ាញ ។ ឯ ចម្ប៉ា ចំប៉ី ត្រូវសរសេរដាក់មូសិកទន្ត មិនត្រូវសរសេរ ចម្បា ដូចក្នុងវេយ្យាករណ៍ នៃក្រុមវិទ្យាសាស្ត្រ (ទំព័រ ៥) នោះទេ ព្រោះបើសរសេរដូច្នេះត្រូវអានថា ចំ-បា ។

## ២– ត្រីស័ព្ទ ( ˜ )

ត្រីស័ព្ទមិនត្រូវយកសេចក្ដីតាមអក្ខរៈថាសំឡេង ៣ ទេ ។ ស័ព្ទ ប្រែថាសូរសំឡេង ដូចមានពោលមកហើយ ។ ដែលហៅថាត្រី ស័ព្ទ ក៏ព្រោះតែសញ្ញានេះជាលេខ ៣ ក្នុងលេខនព្វន្ត ឬក្នុងលេខដែលហៅតាមពាក្យសាមញ្ញថាលេខអត្ថៈ ។ គ្រឿងសំគាល់នេះ បើហៅថាលេខត្រី ឃើញថាសមជាងដូចជាហៅថាលេខទោ លេខអស្ដា ដែលនឹងអានអធិប្បាយខាងក្រោយតទៅនេះ ។

ត្រីស័ព្ទជាវណ្ណយុត្តិសំរាប់ញាំងព្យញ្ជនៈសំឡេងត្រលួចខ្លះឲ្យទៅជាព្យញ្ជនៈសំឡេងត្រលរ ។ ប្រើដាក់លើព្យញ្ជនៈសំឡេងត្រលួចណាដែលគ្មានព្យញ្ជនៈសម្លេងត្រលរ ជាគូស្រាប់មកហើយ ។ ព្យញ្ជនៈត្រលួចចំពូកនេះបានដល់ ប ស ហ អ ដែលទៅជា ប៊ ស៊ ហ៊ អ៊ ។

សេចក្ដីសង្កេត.– មូលហេតុនឹងត្រីស័ព្ទ អាចផ្លាស់

រូបជាគំនូសបញ្ឈរមួយក្រោមព្យញ្ជនៈវិញ កាលបើវណ្ណយុត្តិទាំងពីរនេះជាទំនាស់ ដល់ការដាក់ស្រៈបញ្ចូលនឹងព្យញ្ជនៈដូចក្នុង ស៊ី អ៊ឹង ម៉ឺន ញ៉ាំ រ៉ឹង ។

សំរាប់អក្សរ ប គឺលោកផ្លាស់រូបវណ្ណយុត្តិទាំងពីរនេះដូចគ្នាដែរ ឧ. ប៉ី ប៉ុន ប៉ើង ។ ធ្វើដូច្នេះអាចនាំឲ្យមានការច្រឡំសំឡេងទៅបានដោយព្រោះ ក្នុងអសាធារណនាម ( noms propres ) ។ ប៉ី ប៉ុន ប៉ើង អាចអានថា ប៊ី ប៊ិន ប៊ើង ក៏បាន, អាចអានថា ប៉ី ប៉ិន ប៉ើង ក៏សឹងបាន ។

## ៣- រស្សសញ្ញា ( ់ )

មាន សែ.ស: - សាញ់ ញ៉ា ។ ហៅតាមពាក្យសាមញ្ញថា បន្តក់ឬសង្កត់ ។ ប្រើសំរាប់ញ៉ាំងស្រៈទីឃៈ អ អា ដែលប្រកបនឹងព្យាក់ឲ្យខ្លីដូចជារស្សៈ, ឧ. កុំ កាន់ បង់ បាត់ តប់ សល់ . . . ។

ចំពោះ អា ប្រកបនឹងខ្យល់ ង ដើម្បីធ្វើឲ្យខ្លី លោកមិនប្រើសង្កត់ទេ, លោកប្រើនិគ្គហិតវិញ ឧ. តាំង ទាំង វាំង. . . ។ ប្រើបែបនេះគឺធ្វើទៅតាមទំលាប់ មិនមានសមហេតុសមផលអ្វីសោះឡើយ ។

១ វិញទៀត សំរាប់ស្រៈ អុ ប្រកបនឹងខ្យល់ក្នុងពាក្យដែលមកពីភាសាសំស្រ្កឹត ឬបាលី ស្រៈ អុ នោះទៅជាស្រៈ តែលោកមិនឲ្យដាក់សសញ្ញាទេ ឧ. ផល កុសល ភព...។ សរសេរបែបនេះនាំឲ្យលំបាកអាន ហើយលំបាកចាំថាក្នុងព្យាង្គខ្លីរបស់ពាក្យណាត្រូវសង្កត់ ក្នុងព្យាង្គខ្លីរបស់ពាក្យណាមិនត្រូវសង្កត់ ។

## ៤– សំយោគសញ្ញា ( ័ )

វណ្ណយុត្តិនេះសំរាប់ប្រើតែនឹងពាក្យដែលមកពីបាលីសំ-ស្រ្កឹត ដើម្បីបំបែរសំឡេងឲ្យត្រូវទៅតាមទំនួលសំដីខ្មែរ ។ អានដូចស្រៈ អា ប្រកបនឹងខ្យល់ ហើយមានសង្កត់ផង ។

ឧ. ភ័ត្ត < បាលី ភត្ត (ភាប់-តៈ) អានថាភាប់,

ស័ព្ទ < សំ. ឝព្ទ (សាប់-ពៈ-ទៈ) អានថាសាប់,

ភ័យ < បា. សំ. ភយ (ភៈ-យៈ) អានថា ភាយ់ (ភៃ)

មានពាក្យស័ព្ទបាលីនិងសំស្ក្រឹតខ្លះដែលមានព្យញ្ជនៈជាន់ចុងតំរួតគ្នា ដូចជា ប្រត្យក្ស ប្រតិពទ្ធ ទុក្ខសប្ប ប្រយត្ន បន្ធ សមគ្រ ... ពាក្យនេះកាលទៅជាពាក្យខ្មែរ លោកប្រើសំយោគសញ្ញាខ្លះមិនប្រើខ្លះ៖ ប្រត្យក្ស ប្រតិ-ព័ទ្ធ ទុក្ខសប្ប ប្រយ័ត្ន បន្ធ ស័គ្រ ... ។ ខ្ញុំសូមលន់តួថា មិនដឹងជាមកពីហេតុអ្វីសោះ ។ ខ្ញុំនឹងព្យាយាមខំនឹកឲ្យចាំថាពាក្យណាត្រូវដាក់សំយោគសញ្ញា ពាក្យណាមិនត្រូវដាក់ ។ តែសូមកុំឲ្យអ្នកអានសង្ឃឹមខ្លាំងពេក ថាខ្ញុំនឹងចាំបាន ។ រឿងនេះនឹងមានពេលតទៅទៀតក្នុងវិធីអាន ។

ក្រៅពីពាក្យដែលមកពីបាលីសំស្ក្រឹត សំយោគសញ្ញា

នៅមានប្រើក្នុងពាក្យខ្មែរសុទ្ធខ្លះ សម្រាប់កត់សម្លេងមួយយ៉ាង ដូចក្នុងពាក្យ ញ័រ ទទ័រ ទំព័រ ... ។

## ៥- របាទ ( ៌ )

គាថ ៖- បាទ ។ ប្រែតាមអក្ខរៈថាជើង រ ។ សេចក្តីពិត ទំនងដូចជាសក់ រ ផ្សិតជើង រ មានរូបផ្សេងពីនេះ ( ្រ )។ ប្រើសម្រាប់សរសេរអក្សរ រ កាលអក្សរ រ នៅតំរួតលើព្យញ្ជនៈដទៃមួយអង្គទៀត ឧ. ពណ៌ សួគ៌ គភ៌ ។ ពាក្យចំពូកនេះយើងអាចសរសេរ ពរ្ណ សួរ្គ គរ្ភ ប៉ុន្តែលោកមិនយកបែបនេះមកប្រើ ព្រោះមិនល្អមើល ដោយ រ រូបតូច ហើយជើងព្យញ្ជនៈពីក្រោមមានរូបធំជាង នាំឲ្យមិនសម ។ តែក្នុងពាក្យខ្លះដែលដាក់របាទមិនស្រួល លោកក៏សរសេរបែបនេះដែរ ដូចជាក្នុងពាក្យ ទុរ្ល តិរ្យ អាចារ្យ ... ។

របាទក្នុងសម័យអក្សរថ្មនាសតវត្សទី ១១ ជាតួ រ ចំតែមួយ ៗ ពាក្យ ពណ៌ សួគ៌ គភ៌ បើសរសេរតាមទំនងសម័យ

នោះ ទៅជាដូច្នេះ ពណ៌ ស្វគ៌ គភ៌ ។ តពីសម័យនោះមក តួ ៌ នោះក្លាយបន្តិចបន្តួចៗ ។ សក់កាន់តែរីកធំឡើងៗ ទាល់តែលុបលើខ្លួនអក្សរ ប្រែជារូបដូចសព្វថ្ងៃនេះទៅ ។

បើនឹងពោលមួយយ៉ាងទៀត របាទប្រើសំពប់សរសេរព្យញ្ជនៈ ៌ កាលគ្មានស្រៈ អ អាស្រ័យជាប់គង់ខ្លួនដូចប្រក្រតី ។ ក្នុងពាក្យឧទាហរណ៍ខាងលើនេះ អក្សរ ៌ សុទ្ធសឹងតែគ្មានស្រៈ អ អាស្រ័យ ៖ ពណ៌ (barna), គភ៌ (garbha), ទុរ្ភិក្ស (durbhiksa) ។

បើមានស្រៈអាស្រ័យគង់ ៌ នោះត្រូវសរសេរដូច្នេះ ពរណ (barana) គរភ (garabha) ទុរភិក្ស (durabhiksa) ហើយអានតាមសំស្ក្រឹតថា ព: រ: ណ:, គ: រ: ភ:, ទុរ: ភិក្ស: ។ ឯរបាទមិនត្រូវអានថា រ: ទេ, គ្រាន់តែរលាស់ចុងអណ្តាតបានហើយ ។ របាទប្រើចំពោះតែគង់ពាក្យណាដែលមកពីសំស្ក្រឹត និងបារាំង, ពាក្យខ្មែរសុទ្ធនឹង

ពាក្យដែលមកពីបាលីគ្មានប្រើទេ ។

បោចដែលបង្កើតមានឡើង ក៏ព្រោះតែស្រៈ អ គ្មានរូប ហើយត្រូវសន្មតថាស្រៈ អ មាននៅបង្កប់ខ្លួនក្នុងព្យញ្ជនៈជាដរាប ។ ប្រសិនជាស្រៈ អ មានរូបឡើងដូចក្នុងភាសាបារាំង យើងមិនចាំបាច់មានបោចនេះទេ ។

## ៦– ទណ្ឌឃាត ( ៍ )

អាន ទាន់-ឌៈ-ឃាត ។ ទណ្ឌៈ ប្រែថាដំបង ថាអាជ្ញា; ឃាត ប្រែថា ប្រហារ ថាសំឡាប់ ។ ទណ្ឌឃាតមានឈ្មោះមួយទៀតថា បដិសេធ ។ ប្រើសំរាប់សំគាល់ថាអក្សរដែលដាក់សញ្ញានេះពីលើ មិនត្រូវបញ្ចេញសំឡេងទេ ។ ដូច្នេះអក្សរដែលដាក់ទណ្ឌឃាតពីលើគ្មានប្រយោជន៍ខាងសូរសាស្ត្រទេ (pas de valeur phonétique) លោកដាក់អក្សរនោះផង ដើម្បីឲ្យដឹងឫសគល់របស់ពាក្យតែប៉ុណ្ណោះ ឬបើនឹងពោលមួយយ៉ាងទៀត គឺថាដើម្បីសំគាល់និរុត្តិសាស្ត្ររបស់

ពាក្យតែប៉ុណ្ណោះ (valeur étymologique) ។ ហេតុនេះ ទណ្ឌឃាតមានប្រើតែចំពោះក្នុងពាក្យណា ដែលយើងខ្ចីមកពីភាសាដទៃដូចជាបាលីសំស្ក្រឹតជាដើម; ក្នុងពាក្យខ្មែរសុទ្ធគ្មានប្រើទេ ។

## ៣– យុគលពិន្ទុ (:)

អាន យុ-គល់-ល:-ពិន-ទុ ។ យុគល ប្រែថា គូ; ពិន្ទុ ប្រែថា តំណក់ ចំណុច រង្វង់តូច ដូចនិគ្គហិត ឬដូចជាលេខសូន្យក៏បាន ។ យុគលពិន្ទុ គឺចំណុចមួយគូ ។ ប្រើសំរាប់ញ៉ាំងស្រៈ អ ខ្មែរ ឲ្យបញ្ចេញសម្លេងខ្លីតាមបាឡីសំស្ក្រឹត ។ លោកតែងប្រើនឹងស្រៈ អ នៅចុងពាក្យដែលមកពីភាសាទាំងពីរនេះ ដើម្បីឲ្យងាយអាន ឧ. ឧបការៈ ទិយៈ ខេមរៈ ។

យុគលពិន្ទុ ជាគ្រឿងសំគាល់ទើបនឹងកើតថ្មី ។ ព្រះតេជព្រះគុណលោកគ្រូព្រះពោធិវង្ស ជួន-ណាត ជាអ្នកបង្កើតសញ្ញានេះឡើង ។

## ៨– លេខទោ (ៗ)

លេខទោគឺលេខពីរ ប៉ុន្តែរូបប្លែកផ្សេងបន្តិច ដើម្បីមិនឲ្យច្រឡំគ្នា ៗ ប្រើសម្រាប់សំគាល់ថាត្រូវអានពាក្យខាងមុខវណ្ណយុត្តិនេះផ្ទួនពីរដងជាប់គ្នា ៗ ឧ. ដើរមួយៗ សក់រុយៗ និយាយតិចៗ ៗ

ជួនកាលលេខទោធ្វើឲ្យអានផ្ទួនមិនត្រឹមតែពាក្យមួយម៉ាត់ខាងចុងបង្អស់ដូចពាក្យឧទាហរណ៍ខាងលើនេះទេ ត្រូវផ្ទួនពាក្យ ២ ឬ ៣ ម៉ាត់ក៏មានស្រេចតែករណី (selon le cas) មិនបានអ្វីជាចំណាំក្រៅពីសេចក្ដីរបស់រឿងដែលអាននោះឡើយ ៗ ឧ. ធ្វើបន្តិចម្ដងៗ (ពាក្យ ២ ម៉ាត់) គ្រូឲ្យសិស្សឈរម្ដងពីរនាក់ៗ (ពាក្យ ៣ ម៉ាត់) ។

លេខទោសម្រាប់ធ្វើឲ្យអានផ្ទួនពីរដងជាប់គ្នា មិនមែនសម្រាប់វៀរជៀសមិនសរសេរពាក្យដដែលពីរដងទេ ៗ ហេតុនេះពាក្យណាត្រូវអានពីរដង តែមិនមែនផ្ទួនគ្នា ត្រូវសរសេរ

ពាក្យនោះពីរដង មិនត្រូវប្រើលេខទោទេ ។ ឧ. ប្ញើ ក្ដៅទៅពីងទឹក ទឹកក៏ក្ដៅពេញកំសាំង បាំភ្លៀង ភ្លៀងក៏រាំង... ។ ក្នុងប្រយោគទាំងពីរនេះមិនត្រូវប្រើលេខទោទេ ព្រោះមិនត្រូវអានថា ទឹក ៗ ភ្លៀង ៗ ជួនជាប់គ្នា ។

## ៩– លេខអស្ដា ( ៨ )

អាន ឡេក-កាស់-ស្ដា (ដើនជ) ។ អស្ដ្រៈ ក្លាយពីពាក្យស័ព្ទសំស្ក្រឹតដែលត្រង់នឹងពាក្យស័ព្ទបាលី អដ្ឋ ប្រែថាប្រាំបី(១) ។ វណ្ណយុត្តិនេះក្នុងភាសាសៀម គេប្រើសម្រាប់

---

១– យើងប្រើលេខច្រើនអង្គជាគ្រឿងសំគាល់ខ្សែនឹងអក្សរផ្សេង ៗ ។ លេខ ១ អត្ថៈ ( ^ ) ប្រើសម្រាប់បញ្ជាក់ស្រៈ អ កុំឲ្យអានប្រែទ្បំ, ហៅថាលេខឯកឬអន្ត្យបន្ទ ឧ. រ^ឆ៌ា គ^មក ថប^រ ។ លេខឯកនេះយើងលែងប្រើហើយ ។ លេខ ២ ជាលេខទោ (ៗ) ។ លេខ ៣ អត្ថៈ ជាត្រីស័ព្ទ (˜) ។ ចុងលេខ ៥ ដាក់លើបាំងឈើជាស្រៈ ៃ ។ លេខ ៦ ដាក់លើបាំងឈើជាស្រៈ ៃ ។ លេខ ៧ ហៅថាលេខសប្ត ប្រើសម្រាប់ប្រែស្រៈអេជាស្រៈអឺ ឧ. មេឝ> ប៊ឹង, សញ្ញានេះយើងលែងប្រើហើយ ។ លេខ ៨ ជាលេខអស្ដា ។ លេខ ៩ ជាទណ្ឌឃាត ។ លេខសូន្យជានិគ្គហិត ។

ម្សើសម្លេងឲ្យខ្លី ចំនួនស្រៈសញ្ញាយើងមួយគល់ ។ ក្នុងភាសាខ្មែរ និងជាលេខអស្ដាញ៉ាំងសម្លេងឲ្យខ្លីដែរក៏សឹងបាន តែមិនជាការណ៍ជាក់ប្រាកដណាស់ទេ ។ យើងប្រើលេខអស្ដាដាក់លើ ក៏ (ក៏), ដ៏ (ដ៏), ហ៏ (ហ៏) ន៏ (ន៏) [ ថែប ប៉ាំងដាក់ accent grave លើ a (à) និងលើ ou (où) ] ជាប្រយោជន៍ដើម្បីមិនឲ្យច្រឡំនឹងសទិសសព្ទ (១) របស់ពាក្យទាំងនោះច្រើនជាងដើម្បីកែលំអៀងសម្លេង (២) ។

---

១– អាន សៈ ទិ សៈ សាប់ ។ សទិសៈ ប្រែថាប្រហែលគ្នា,ដូចគ្នា ។ សទិសសព្ទ ប្រែថា ពាក្យសម្លេងដូចគ្នា តែសេចក្ដីខុសគ្នា (homonymes) ។

២– ក្នុងវចនានុក្រមខ្មែរក្បាល ទី ២ ព្រះតេជព្រះគុណលោកគ្រូព្រះពោធិវ័ង្សជួន-ណាត ជាអ្នករៀបរៀង លោកកាប់វិសជ្ជនីយ ( ៈ ) ជាវណ្ណយុត្តិផង ។ ខ្ញុំយល់ថា បើទុកវិសជ្ជនីយជាវណ្ណយុត្តិ ក៏គួរទុកទាញយារ (-ា), រុកជើង ( ុ ), និគ្គហិត ( ំ ), ជាំងឈើ (េ– )... ជាវណ្ណយុត្តិផងដែរ ។ ក្នុងសៀវភៅនេះ ខ្ញុំទុកវិសជ្ជនីយជាស្រៈទៅហើយ ទើបមិនយកមកអធិប្បាយក្នុងទីនេះ ។ (នៅ...)

## ឃ) ខណ្ឌសញ្ញា

ក្នុងសង្កាត់នេះ ខ្ញុំនឹងពោលដល់សញ្ញាផ្សេងៗ ដែលប្រើសំរាប់កាត់ចែកការសរសេរជាវគ្គ ជាអនុច្ឆេទ ជាប្រយោគ ជាវាក្យៈ(១) ។ ដោយមិនទាន់មានឈ្មោះសំរាប់បណ្ដាគ្រឿងសំគាល់ទាំងនេះ ខ្ញុំសូមសន្មតហៅថា ខណ្ឌសញ្ញា ប្រាថ្នាដើម្បីឱ្យត្រូវគ្នានឹងពាក្យបារាំងថា signes de ponctuation ។

ខណ្ឌ ជាពាក្យស័ព្ទបាលីសំស្រ្កឹតប្រែថាសង្កាត់ ប៉ែក ការបែងចែក ។ ពាក្យនេះខ្មែរយកមកប្រើជាកិរិយាស័ព្ទក៏មាន ដូចក្នុងប្រយោគ៖ «ផ្ទះថ្មីនេះគេខណ្ឌជាបីបន្ទប់» ។

សញ្ញា ជាពាក្យស័ព្ទបាលី យើងមានខ្ចីមកប្រើជាពាក្យខ្មែរ

---

១ទៀតក្នុងវចនានុក្រមខ្មែរក្បាលនដែល លោករាប់គ្រឿងសំគាល់ ៥ ។ ( )... [illegible] ជាវណ្ណយុត្តិផង ។ វណ្ណយុត្តិប្រែតាមនិរុត្តិសាស្ត្រថាគ្រឿងសំគាល់កែសៀងសម្លេងអក្សរ ។ ឯសញ្ញា ៥ ។ ( )... មិនញាំងសម្លេងអក្សរឲ្យប្រែប្រួលអ្វីសោះ ។ ដោយហេតុនេះ ខ្ញុំកសញ្ញាណរម្យាបនេះដោយ [illegible] ឲ្យឈ្មោះថាខណ្ឌសញ្ញាដូចបាន[illegible]នេះ ។

១— វាក្យៈ ជាប្រយោគដែលមានសេចក្ដីពេញបរិបូណ៌ក្នុងខ្លួន (phrase) ។

ហើយដែរ, ប្រែថាគ្រឿងសំគាល់ ។ ហេតុនេះពាក្យថា ខណ្ឌសញ្ញា (អាន ខាន់-ឌៈ សញ្ញ៉ា) ក៏មិនជាប្លែកអ្វីណាស់ ល្មមស្តាប់បានសេចក្តីមិនចាំបាច់ប្រែដោយពិស្តារពេក ។

មែនពិត ខណ្ឌសញ្ញាមិនប្រែលំអៀងសម្លេងអក្សរដូចវណ្ណយុត្តិទេ ។ ម៉្លោះហើយអ្នកអានអាចឆ្ងល់ថា ហេតុអ្វីបានជាខ្ញុំនាំយកគ្រឿងសំគាល់ចំពូកនេះ មកពោលក្នុងភាគសូរសាស្ត្រ ។ សូមឱ្យសង្កេតមើលថាក្នុងការអាន ខណ្ឌសញ្ញាជាគ្រឿងសំគាល់ឲ្យដឹងថា ដំណើររបស់សម្លេងត្រូវធ្វើទោះដោយរួសរាន់ ឬ ដោយបង្អង់ ត្រូវឲ្យលើកសម្លេងឲ្យខ្ពស់ឡើង ឬ ត្រូវទំលាក់ចុះ ។ ដូច្នេះ ទើបយល់ថាខណ្ឌសញ្ញាជាសង្កាត់មួយក្នុងសូរសាស្ត្រដែរ ។

សេចក្តីសង្កេត.— ខណ្ឌសញ្ញា គេប្រើដោយប្រិតប្រៀបជាខ្លាំងក្នុងភាសាអឺរ៉ុប ។ ក្នុងភាសាយើង ជួនកាលក៏ប្រើជួនកាលក៏ទេ ។ ដើម្បីជាប្រយោជន៍ដល់សំឡាញ់រួមជាតិទាំងឡាយ ដែលពុំបានទទួលសេចក្តីសិក្សាភាសាបារាំង

ខ្ញុំនឹងនាំមកអធិប្បាយដោយពិស្ដារនូវខណ្ឌសញ្ញាផ្សេងៗដោយចំពោះខណ្ឌសញ្ញាដែលយើងខ្ចីពីបារាំងមកប្រើ ។

## ១- ភ្នែកមាន់ (៙)

ហៅតាមសំស្ក្រឹតថា កុក្កុដនេត្រ (អានកុក-កុត-ដះ-នេត) ។ ប្រើសំរាប់ដាក់នៅដើមបទក្នុងពាក្យកាព្យឃ្លោង ។ ក្នុងពាក្យធម្មតាខាបុរាណសម័យលោកដាក់គ្រឿងសំគាល់នេះនៅដើមលិខិត ឬរឿងរ៉ាវផ្សេងៗជាគូនឹងគោមូត្រ (៚) ដែលលោកដាក់បញ្ចប់លិខិតឬរឿងរ៉ាវនោះ ។ សព្វថ្ងៃនេះ ក្នុងពាក្យរាយ លោកមិនសូវប្រើទេ ។

## ២- គោមូត្រ (៚)

មូត្រ ប្រែថាទឹកនោម; គោមូត្រ ប្រែតាមអក្សរថា ទឹកនោមគោ ។ លោកប្រើដាក់ក្នុងទីបញ្ចប់ពាក្យកាព្យឃ្លោង ជាគូនឹងភ្នែកមាន់ដែលដាក់ខាងដើម ។ ក្នុងពាក្យរាយ មានប្រើពីមុនណា តែសព្វថ្ងៃមិនសូវប្រើទេ ។

## ៣- ល្បះ (។)

ប្រើសំរាប់ដាក់ចុងវាក្យៈ ដើម្បីសំដែងថាវាក្យៈអស់តែត្រឹមនោះ ។ បារាំងប្រើចំណុច ១ ( . ), យើងគួរប្រើល្បះជំនួសចំណុច ព្រោះចំណុចតូចពេក មិនធ្វើឲ្យឃើញចុងវាក្យៈបានដោយច្បាស់លាស់ ។ បារាំងគេប្រើចំណុចបានងាយឥតទាស់ ដោយហេតុគេដាក់ចំណុចរួច-បើមានសរសេរតទៅទៀត-គេដាក់អក្សរធំមួយអង្គជាដើមដំបូងរបស់វាក្យៈថ្មី ។ ឯៈយើងមិនមានប្រើអក្សរពីរយ៉ាងលាយឡំគ្នាដូច្នេះទេ ។.

ល្បះបានប្រើក្នុងការកត់ត្រាថ្ងៃខែក្នុងចន្ទគតិ ។ ឧ.

ភ្នំពេញ ថ្ងៃ ៥ ៩ ១ ឆ្នាំរកាសប្តស័ក ព. ស. ២៤៨៨ ។

លេខខាងឆ្វេងល្បះជាលេខថ្ងៃ, លេខខាងលើសំរាប់កត់កើត, បើជារនោចលោកដាក់ក្រោមល្បះ, លេខខាងស្តាំជាលេខខែ ។

## ៤ - ល្បះបប់ (៕)

ឈ្មោះមួយយ៉ាងទៀតថា ល្បះបរិយោសាន ។

ប្រើសំរាប់ដាក់នៅទីបំផុតនៃលិខិតផ្សេងៗ កាលបើគ្មានភ្នែកមាន់នៅខាងដើម ។ គ្រឿងសំគាល់នេះមិនជាប្រយោជន៍ណាស់ទេ, នាំតែឲ្យមានសញ្ញាជាចំនួនច្រើនពេក ។ យើងប្រើល្បះតែមួយយ៉ាងក៏បានហើយ ។

## ៥– បេយ្យាល

តាមវចនានុក្រមខ្មែរ លោកឲ្យអានថា «បេ៉ យ៉ា-ល៉ះ»ៗ លោកសរសេរកាត់ដាក់តែអក្សរខាងដើមជា ។បេ។ អានថា «បេ៉» ក៏បាន ឬដាក់តែអក្សរចុងបំផុតជា ។ល។ អានថា «ឡះ» ក៏បាន ។

ប្រើសំរាប់ប្រួញសេចក្ដី ធ្វើឲ្យដឹងថានៅមានតទៅទៀត តែមិនចាំបាច់នាំមកសរសេរទាំងអស់ទេ ។ ឧ. ព្រៃដែលបុរសនោះទៅកាប់ឈើមានសត្វច្រើនណាស់ មានខ្លា ដំរី ខ្ទីង ទន្សោង ប្រើស ។ល។

សេចក្ដីសង្កេត.– បេយ្យាលត្រូវគ្នានឹងពាក្យ etc.,

ក្នុងភាសាបាលី ។ គ្រឿងសំគាល់ៗលើនេះ កាលណាយើងយក មកប្រើក្នុងភាសាខ្មែរ ពាស់បន្តិចត្រង់ការបញ្ចេញសម្លេងមិន ស្រួលមាត់ មិនត្រូវនឹងនិយាយរបស់ខ្មែរ ។ ប្រសិនជាយើងដាក់ ។ ន.ទ. ។ ហើយអានថា "និងដទៃទៀត" ដូចជាសមទីងទំនងភាសាខ្មែរជាង ។ ឧ. ឡូ ដិរ ទ្វីង ទន្សោង ។ ន. ទ. ។ (និងដទៃទៀត) ។ យើងគួរហៅសញ្ញានេះថា សង្ខេបសញ្ញា ។

## ៦– កាកបាទ (+)

អានថា កាកៈ បាទ ។ កាកៈ ប្រែថាក្អែក, បាទ ប្រែថាជើង ។ សញ្ញានេះហៅតាមពាក្យសាមញ្ញថា ជើងក្អែក ឬខ្វែងជើងក្អែក ។ ប្រើបាន ៣ យ៉ាង៖

១)- សំរាប់ជ្រៀតពាក្យដែលខ្វះ ហើយនាំយកមកសរសេរបន្ថែមជាក្រោយ ដាក់ខាងលើឬខាងក្រោមបន្ទាត់ (ហៅថាការជើងក្អែក) ។

២)- សំរាប់ដាក់លើអក្សរខ្វះដូចជា អ៊ាំ អ៊ុយ ណាំ ប៉ិះ ... ។ ក្នុងពាក្យទាំងនេះ បើយើងមិនដាក់គាកបាទ ក៏មិនជាខុសអ្វីណាស់ទេ ។ យើងគាប់ធ្វើពាក្យនេះ មិនឲ្យប្រទាំនឹងពាក្យសំស្រ្គតបានដោយ អាស្រ័យវិធីដទៃ ដូចក្នុងភាសាបារាំង ។ ក្នុងភាសាអង់គ្លេសគេព្យាយាមឲ្យមាន អក្សរនិងសញ្ញាឯទៀតតិចអន្តយាំងបំផុត ដើម្បីសំរួលការបោះពុម្ព ។

៣)- សំរាប់ះលខបូកក្នុងវិជ្ជានព្វន្ត ។

## ៧- ឃ្នាប (})

ប្រើសំរាប់ប្រមូលសេចក្ដីច្រើនបទជាមួយគ្នា ។

## ៨- វង់ក្រចក ( )

...ពាក្យបាឡីថា ឆទសញ្ញា មកពី ឆ្នុខ: ប្រែថាក្រចក ។ ប្រើសំរាប់ដាក់ជៀតជ្រែកសេចក្ដីកាយវាង បន្ទាប់បន្សំ ក្នុងប្រយោគនិមួយៗ ។ ឧ. ប្រាសាទវិត្តធំគរនៅ

ខេត្តកំពង់ចាម (សូមកុំច្រឡំនឹងប្រាសាទនគរវត្ត) សាងក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ៖

ក្នុងអាណាចក្រសៀម (មានម្តងហៅថា ប៉ៃឡង្គ) មានជនជាតិខ្មែរនៅរាប់សែននាក់ ។

*សេចក្តីក្នុងវង់ក្រចកមិនមានសារៈសំខាន់ទេ ។ គេអាចមិនអានឬលុបចោលក៏បាន ឥតធ្វើឲ្យខូចសេចក្តីក្នុងប្រយោគឡើយ ។*

សេចក្តីសង្កេតទី ១– *មានអ្នកខ្លះប្រើវង់ក្រចកដោយការច្រឡំ ។ គឺមិនដាក់សេចក្តីបន្ទាប់បន្សំក្នុងវង់ក្រចក ត្រឡប់ជាដាក់សេចក្តីសំខាន់ទៅវិញ ។ ឧ.* ខ្ញុំបាទឈ្មោះ (សៅ) ជាតិខ្មែរ អាយុ... ។ *ខ្ញុំគិតថាសរសេរបែបនេះជាការច្រឡំ ព្រោះបើពុំអានពាក្យក្នុងវង់ក្រចកហើយ ប្រយោគក៏នឹងខ្វះសេចក្តី យកជាការពុំបាន ។ វង់ក្រចកនៅទីនេះ គេប្រើច្រឡំនឹងអញ្ញសញ្ញា ៖* ខ្ញុំបាទឈ្មោះ

«សៅ»... ៗ បើកុំដាក់សញ្ញាអ្វីសោះត្រង់ឈ្មោះ សៅ នោះល្អជាង ។

សេចក្ដីសង្កេតទី ២– វង់ក្រចករូបដូចខាងលើនេះ ជាវង់ក្រចកធម្មតា ។ នៅមានវង់ក្រចកមួយយ៉ាងទៀត គួរហៅថា វង់ក្រចកធំ ឬ វង់ក្រចកជ្រុង រូបយ៉ាងនេះ [ ] ។ ប្រើដូចគ្នានឹងវង់ក្រចកធម្មតា ប៉ុន្តែប្រើចំពោះសេចក្ដីត្រង់ណាដែលមានប្រើវង់ក្រចកធម្មតារួចហើយ ។ ខណ្ឌសញ្ញានេះមានប្រើមកហើយ ក្នុងសេចក្ដីអធិប្បាយអំពីលេខអស្ដាខាងមុខនេះ (ទំព័រ ៦៣) ។

## ៩– រជ្ជុសញ្ញា (–)

មកពី រជ្ជុ ប្រែថាខ្សែ ។ ប្រើបានច្រើនយ៉ាង ៗ

១)– ប្រើក្នុងទំនងវង់ក្រចក ដើម្បីជ្រៀតសេចក្ដីក្នុងប្រយោគ ។ សេចក្ដីនោះនឹងថាដាច់បន្ទាប់ចេញក៏បាន តែក៏មានសារៈសំខាន់ដែរ ។ ឧ. កុមារនោះ ក្រឡេកទៅ

ឃើញក្តីក្តឹងពីរនាក់ដើរចូលមក - ពុកចង្កាស្រមូមផ្លូត
ក្បាលយ៉ាងធំ ភ្នែកតាខ្មៅ- ក៏ភិតភ័យរត់ទៅពួន ។

២)- ប្រើសំរាប់ខណ្ឌពាក្យនិយាយឆ្លើយឆ្លង ។ ឧ.
បុរសនោះបានស្តាប់ហើយ សួរទៅវិញថា ៖

- អ្នកធ្លាប់ជិះកប៉ាល់ហោះឬទេ?

- ទេ ។

- ចុះបងអ្នក?

- បងខ្ញុំក៏មិនធ្លាប់ជិះដែរ ។

៣)- ប្រើដាក់ក្រោយលេខរៀង និងក្រោយចំណងជើងខ្លះដូចមានប្រើពាសពេញក្នុងសៀវភៅនេះជាឧទាហរណ៍ស្រាប់ ។

## ១០- សហសញ្ញា (-)

ហៅ ស: ហ: សញ្ញា ។ ឈ្មោះមួយទៀតថា
យតិភង្គ អំពី យតិ ប្រែថាបញ្ឈប់ និង ភង្គ ប្រែថាការ

បំបែកបំបាក់ ។ លោកប្រើកុនពាក្យកាព្យឃ្លោង ត្រង់ពាក្យពហុព្យាង្គណាដែលត្រូវបំបែកជាពីរ ដើម្បីឲ្យបានជួន(១) ឬឲ្យត្រូវចង្វាក់(២) ។

ឧ. ទន្សាយឈ្មៀតឈ្លប ប្រួញខ្លួនលបមើលណា
យល់ឃើញជាក់ប្រា- កដដូច្នោះហើយវិលទៅ។

គ្រឿងសំគាល់នេះបារាំងហៅថា trait d'union ។ បើយើងទុកឈ្មោះយតិកន្តប្រើក៏បាន តែខ្ញុំយល់ថា សេចក្តីតាមអក្ខរៈរបស់ពាក្យនេះ និងផ្ទុយគ្នានឹងសេចក្តីយល់របស់ជនសម័យថ្មីទាំងឡាយ ព្រោះយើងធ្លាប់យល់ថា ជាសញ្ញាសំរាប់ភ្ជាប់កាត់នៃពាក្យដែលត្រូវញែកពីគ្នាដោយផុតបន្ទាត់ ឬដោយហេតុផ្សេងៗ ។ ទើបខ្ញុំសន្មតហៅថា សហ-សញ្ញា វិញ ពី សហៈ ប្រែថាជាមួយគ្នា រួមគ្នា ។

ឧ. ស៊ុន-យ៉ាត់-សេង ជារដ្ឋបុរសយ៉ាងល្បី

១— la rime. ២— le rythme.

បំផុតរបស់ប្រទេសចិនក្នុងសម័យបច្ចុប្បន្ន ។

### ១១- ន័យសញ្ញា (...)

អាន នៃ·យ:-សាញ់-ញ៉ា ។ ឈ្មោះមួយទៀតថា សញ្ញាប្រកាស់ អាន សាញ់·ញ:-ប្រកាស ។ គឺបន្ទាត់ដែលគូសពីក្រោមពាក្យសំខាន់ ដើម្បីឲ្យឃើញជាក់ស្តែងឡើង ។

### ១២- បំណុប (·)

ក្នុងភាសាបារាំង គេប្រើសំពប់ដាក់ក្នុងទីបំផុតនៃពាក្យៈ។ ដោយហេតុនេះបានជាមានឈ្មោះមួយទៀតថា មហាភាគ ប្រែថាភាគធំ ។ ប៉ុន្តែខ្ញុំយល់ថា គួរប្រើល្បះសំពប់ដាក់បញ្ចប់ពាក្យៈវិញដោយអាស្រ័យហេតុផលដូចមានអធិប្បាយក្នុងមាតិកាល្បះរួចហើយ ។ ដូច្នេះសញ្ញានេះគួរហៅថា បំណុប ឬ បុប សមជាង មហាភាគ ។ ចំណុចគួរទុកប្រើក្នុងករណីដទៃទៅវិញ មានករណីសង្ខេបពាក្យជាដើម ដូចជា

ក. ជំនួសកិរិយាស័ព្ទ, ខ. ជំនួសឧទាហរណ៍, គ. ជំនួសនាមនាម ។ល។ ក្នុងវិធីលេខមានប្រើចំណុចដែរ ឧ. ៦៦.៦៣០ ។

## ១៣- ក្បៀស (,)

ហៅមួយយ៉ាងទៀតថា ចុល្លភាគ ប្រែថាភាគតូច ៗ តាមរបៀបអក្សរបារាំង ក្នុងពាក្យមួយម៉ាត់ៗ គេសរសេរអក្សរជាប់គ្នា; ដល់សរសេរចប់ពាក្យមួយម៉ាត់ហើយ គេដកឃ្លាមួយដង ។ ដោយហេតុពាក្យបារាំងដាច់ៗពីគ្នាដូច្នេះ ទើបគេប្រើចុល្លភាគ ដើម្បីញែកសេចក្ដីក្នុងប្រយោគជាភាគតូចៗ តាមត្រូវការ ។ ឯក្នុងរបៀបអក្សរខ្មែរ យើងសរសេរពាក្យជាប់រៀងគ្នា ។ ដើម្បីនឹងញែកសេចក្ដីក្នុងវាក្យៈជាភាគតូចៗនោះ តាមធម្មតា យើងគ្រាន់តែដកឃ្លាក៏គ្រប់គ្រាន់ហើយ មិនចាំបាច់ដាក់ក្បៀសផងទេ ។

ឧ. នៅលើតុនោះ ខ្ញុំឃើញមានដងប៉ាកកាមួយ

ទឹកខ្មៅមួយដប សៀវភៅអានបី និងសៀវភៅសរសេរពីរ ។

មានតែកន្លែងករណីពិសេសខ្លះ (cas spéciaux) ដែលគួរប្រើក្បៀសដូចក្នុងឧទាហរណ៍តទៅនេះ ៖ ក្នុងភាសាអង់គ្លេសមានលិង្គ ៣ គឺ បុំលិង្គ សំរាប់ភេទប្រុសឬឈ្មោល, ឥត្ថីលិង្គ សំរាប់ភេទស្រីឬញី, នបុំសកលិង្គ សំរាប់របស់ដែលគ្មានភេទ ។ ហេតុថាក្នុងអក្សរខ្មែរ សញ្ញានេះមិនសូវប្រើក្នុងការតែងសេចក្ដីប្រយោគជាការ ខ្ញុំយល់ថាគួរឲ្យឈ្មោះតាមពាក្យខ្មែរសុទ្ធថា ក្បៀស វិញល្អជាង ។ ក្រៅពីនេះ ក្បៀសនៅមានប្រើក្នុងវិធីលេខ ឧ. ២,៥០ ។

## ១៤– បំណុប-ក្បៀស (;)

ឈ្មោះមួយទៀតថា ឧទ្ធក្បក្រ ប្រែថាកន្លះការ ។ ខ្ញុំយល់ថាគួរតែហៅឈ្មោះ តាមទំនងសេចក្ដីក្នុងពាក្យបារាំងថា

បំណុប-ក្បៀស ឬ ចុប-ក្បៀស (point-virgule) ។

គ្រឿងសំគាល់នេះសំរាប់ញែកសេចក្ដីជាភាគ តែភាគនោះធំជាងភាគដែលញែកដោយដកឃ្លា ឬប្រើក្បៀស ហើយតូចជាងភាគដែលញែកដោយប្រើល្បះ ។

ឧ. ឪពុកកុមារនោះធ្វើការនៅស្រែវាល់ល្ងាចគ្មានឈប់ដៃ ម្ដាយវានៅផ្ទះ ក៏មិននៅដៃស្ងៀមដែរ។

## ១៥– បំណុបវាយ (...)

ហៅ ពងត្រី ក៏មាន ឬហៅតាមបាលីថា មជ្ឈុណ្ណាសញ្ញា ក៏មាន (មជ្ឈ: ត្រី; អណ្ណ: ពង) ។ ប្រើវែបវេយ្យាល សំដែងសេចក្ដីថា នៅមានដទៃទៀត តែមិនចាំបាច់អានបញ្ចេញសម្លេងឡើយទេ ។ ឧ. លោកភិក្ខុអង្គនោះឡើងលើគ្រែធម្មាសន៍ហើយក៏តាំងបាប់ “ នមោ តស្ស ... ” ភ្លាម ។

## ១៦- បុច្ឆសញ្ញា (?)

អាន ប៉ុច-ឆៈ-សញ្ញា ។ ប្រើដូចល្បះតែចំពោះសេចក្ដីសួរ ។ ឯសេចក្ដីសួរនោះតោងជាសេចក្ដីសួរដោយចំ ។ ឧ. អ្នកស្ដាប់បានឬទេ?

បើសេចក្ដីសួរនោះជាសេចក្ដីសួរដោយផ្សក លោកមិនប្រើបុច្ឆសញ្ញាទេ ។ ឧ. ខ្ញុំចង់ដឹងថាអ្នកស្ដាប់បានឬទេ។

## ១៧- ឧទានសញ្ញា (!)

អាន អ៊ុ-ទា-នៈសញ្ញា ។ ឧទាន ប្រែថាដង្ហើមចេញ ការបញ្ចេញខ្យល់តាមដង្ហើម ការបញ្ចេញសម្ដែង ។ ប្រើដូចល្បះ តែចំពោះសេចក្ដីអរ ព្រួយ ខឹង សំវេគ ងួល...។ ឧ. សប្បាយមែន! យូរអ៊ីម្ល៉េះទេ! ឱ! ។ល។

## ១៨- ចំណុចពីរ (:)

ហៅឲ្យងាយថា ចុចពីរ ។ សំដែងថាខ្ទឹមមានសេចក្ដីអធិប្បាយតទៅ ឬថាសេចក្ដីតទៅនោះជាសំដីអ្នកដទៃ ។

ឧ. ព្រះរាមមានព្រះរាជបុត្រពីរអង្គ៖ រាមលក្ខណ៍ ១ ជិប្បលក្សណ៍ ១ ។ ព្រាហ្មណ៍នោះប្រាប់ថា៖ «ខ្ញុំនឹងទៅកាន់នគរសាវត្ថី» ។ *ក្នុងរវាងចំណុចទាំងពីរមានគំនូសមួយដើម្បីកុំឲ្យច្រឡំនឹងយុគលពិន្ទុនឹងវិសជ្ជនីយ៍ ។*

## ១៩- អញ្ញប្រកាស (« »)

*អាន* អាញ់-ញៈ-ប្រៈ-កាស់ ។ *ពី* អញ្ញៈ *ប្រែថា ដទៃ ផ្សេង ។ ប្រើសំរាប់ដាក់ពីមុខនិងពីក្រោយសំដីអ្នកដទៃ ដែលគេនាំមកសរសេរ ។ ឧ.* ស្តេចទ្រង់ព្រះសណ្តាប់ ហើយក៏ទ្រង់ព្រះសម្រួលមានព្រះឱង្ការថា៖ «អាពីយ ឯងត្រូវនៅគាល់បំរើអញសព្វថ្ងៃ ៗ កុំឲ្យខាន» ។ *អញ្ញប្រកាសអង់គ្លេសរូបយ៉ាងនេះ (“ ”) ។ ច្រើនប្រើដាក់ត្រង់ពាក្យខ្លះ ឲ្យដាច់ពីពាក្យឯទៀតក្នុងប្រយោគជាមួយ ដូចមានបែបក្នុងមាតិកាគំរូនេះ ។*

## គ្រឿងសំគាល់វាយរង

= ក្នុងអក្សរសាស្ត្រសំគាល់ថា "គឺ", ក្នុងគណិតសាស្ត្រ(១) ថា "ស្មើនឹង" ឬ "ត្រូវជា" ។

+ សំគាល់ថា "នឹង" ឬ "ហើយនឹង" ។

< ក្នុងអក្សរសាស្ត្រសំគាល់ថា "មកពី" ក្នុងគណិតសាស្ត្រថា "តូចជាង" ។

> ក្នុងអក្សរសាស្ត្រសំគាល់ថា "ទៅជា", ក្នុងគណិតសាស្ត្រថា "ធំជាង" ។

## ៥– ប្រវត្តិនៃអក្សរ

ប្រទេសខ្មែរមានមនុស្សនៅតាំងពីព្រេងនាយឆ្ងាយបំផុត គឺតាំងពីយុគថ្ម (âge de la pierre) ។ យុគថ្មជាសម័យមួយ

---

១–គណិតសាស្ត្រ ពី គណិត ជាពាក្យវង្សជាមួយគ្នានឹង គណនា ដែលប្រែថារាប់ ។ គណិតសាស្ត្រជាវិជ្ជារាប់, វិជ្ជាលេខទូទៅ ត្រង់នឹងពាក្យបារាំង mathématiques ។ ពាក្យនេះនៅតំណ្ណកមានប្រើមករាប់ពាន់ឆ្នាំហើយ ។

ក្នុងភូមិវិទ្យា (géologie) ។ ក្នុងយុគនោះ មនុស្សទើបនឹងចេះយកថ្មមកធ្វើជាគ្រឿងឧបករណ៍ (instruments) មានធ្វើជាពូថៅជាដើម ។ កាលបើមានមនុស្សហើយ ភាសាក៏មានទៀតផង, ប៉ុន្តែអក្សរមិនទាន់នឹងកើតមានឡើងព្រមនឹងភាសាទេ គឺកើតក្រោយមកជាយូរឆ្នាំ ។ កាលមុនព្រះថោង (កៅណ្ឌិន្យ:) មកកាន់ស្រុកយើង – រវាងសតវត្សរ៍ទី ១ ក្រោយពុទ្ធកាលប្រហែល ៦០០ ឆ្នាំ – នោះប្រហែលជាយើងមិនទាន់មានអក្សរប្រើនៅឡើយទេ ។

តែជនណាដែលមកកាន់ប្រទេសយើង បាននាំភាសារបស់គេ ព្រមទាំងអក្សរមកឲ្យយើងផង ។ អក្សរឥណ្ឌាមានច្រើនយ៉ាង ។ នៅបែកខាងជើងប្រទេសឥណ្ឌា គេប្រើអក្សរមួយយ៉ាងកងជ្រុងៗ ដែលកំណត់មកក្លាយជាអក្សរទេវនាគរី ឬនាគរីសព្វថ្ងៃនេះ ។ ឯអក្សរដែលជនឥណ្ឌានាំមកកាន់ប្រទេសយើងវេលានោះ មានរូបទ្រង់ជាមូលៗ, ជាអក្សរដែលគេប្រើនៅប្រទេសឥណ្ឌាបែកខាងត្បូង ក្នុងសម័យ

នោះ ៗ អក្សរបែបនេះគេហៅគ្រន្ថៈ ឬគ្រន្ថ: ៗ

សិលាចារឹកដំបូងៗនៅប្រទេសខ្មែរយើង តាមដែលគេបានរកឃើញក្នុងវេលានេះ ធ្វើឡើងក្នុងសតវត្សទី ៣ ៗ លោកអូគុស្តបាថ៌ (Auguste Barth) សរសេរថាអក្សរសិលាចារឹក វ៉េនឆ័ក (ឃុំគោះ ស្រុកបាភ្នំ ខេត្តព្រៃវែង) ដែលធ្វើក្នុងសតវត្សទី ៧ ដូចគ្នានឹងអក្សរសិលាចារឹកដែលក្សត្រិយ៍ជើងចលុក្យៈ បានឲ្យធ្លាក់នៅប្រាសាទ ពាទាមិ ព្រះហាល បត្តទកល់ ក្នុងទក្ខិណាប្រទេស (Dekan) រវាងសតវត្សទី ៦ ទៅទី ៨[១] ៗ គឺអក្សរនេះហើយដែលក្លាយមុខបន្តិច ៗ រាល់តែមកជាអក្សរដែលយើងប្រើសព្វថ្ងៃនេះ ៗ

## ១– ប្រវត្តិនៃស្រៈ

អក្សរឥណ្ឌាប៉ែកខាងត្បូងនេះ ជាអក្សរសំរាប់សរសេរ

១– អក្សរសិលាចារឹកនៅប្រាសាទ ពាទាមិ មានបែបនៅក្នុងសៀវភៅ "Le Cambodge" របស់លោក Aymonier ។ ក្នុងសៀវភៅនោះ មានទាំងអក្សរសិលាចារឹកអង់ជម្ពីកសំរាប់ប្រៀបផង ។

ភាសាភិន្ទ និងភាសាសំស្ក្រឹតដែលជាភាសាពហុព្យាង្គ ។ ឯចម្ភាភាសាពហុព្យាង្គ មានស្រៈប្រើតិចណាស់ ។ ដើមឡើយ ខ្មែរយើងប្រើស្រៈដែលមានក្នុងអក្សរនោះតែប៉ុណ្ណោះ គឺស្រៈសំស្ក្រឹត ១៤ អង្គ៖ អ អា ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ ហើយនិងនិគ្គហិតនិងវិសជ្ជនីយ៍ ។

ហេតុក្នុងសម័យដែលយើងមានចម្លាក់សិលាចារិក – គឺរហូតសម័យដែលជាតិយើងបានធ្វើជាចក្រវត្តិ មានអំណាចលើភាគធំនៃសុវណ្ណភូមិ (Presqu'île indochinoise) លុះដល់សតវត្សរ៍ ១៤–យើងគ្មានស្រៈប្រើលើសអំពីនេះទេ ។ ស្រៈប៉ុណ្ណោះអង្គមិនអាចគ្រប់គ្រាន់នឹងការប្រើប្រាស់របស់ភាសាយើងឡើយ ព្រោះភាសាយើងជាភាសាដែលមានពាក្យឯកព្យាង្គនិងទ្វិព្យាង្គជាច្រើន ។ ភាសាចំពួកនេះត្រូវការប្រើស្រៈច្រើនអង្គ ដើម្បីនឹងធ្វើឲ្យពាក្យខុសពីគ្នា កុំឲ្យច្រឡំគ្នាបាន ។ ប៉ុន្តែក្នុងសម័យដ៏អន្លើនោះ យើងបានទទួលស្រៈពីសណ្ឋាមកប៉ុន្មានយើងប្រើតែប៉ុណ្ណោះ ដូចក្នុងពាក្យតេវានេះដែល

ស្រង់យកមកពីអក្សរថ្ម ៖

ទិក៑, ស្លិក៑, លិង៑ (១) ដូច ទឹក, ស្លឹក, តំលឹង;

គី — គឺ,

-ម្សិយ៑, ក្សាយ៑ — ម្សៅ;

ជេង៑, ស្មេ, បំរេ — ជើង, ស្មើ, បំរើ;

ទ្យាត៑, បង្រ្យាន៑ — ទៀត, បង្រៀន;

បេក៑, ស្រេ — បែក, ស្រែ ;

គួរតាំងជាបញ្ហាថា ៖ ក្នុងសម័យនោះសំឡេង អំ អី អួ អើ អៀ អែ មិនទាន់មានក្នុងភាសាខ្មែរនៅឡើយរឺ បានជាគ្មានស្រៈសំរាប់កត់សំឡេងទាំងនោះ? ពាក្យឆ្លើយ ៖ ពិតមែនជាភាសាយើងក្នុងសម័យនោះ ខុសប្លែកពីសម័យបច្ចុប្បន្នជាច្រើនណាស់, ប៉ុន្តែមិនបមជាសន្និដ្ឋានបានថា យើង

១— គ្រឿងសំគាល់—គឺជាវណ្ណយុត្តិសំស្ក្រឹត ហៅថាវិរាមៈសំដែងសេចក្តីថា ព្យញ្ជនៈដែលនៅពីក្រោមគ្មានស្រៈ អ៖ អាស្រ័យហេតុ (ទិក៑ = dik) បើគ្មានវិរាមៈទេ ត្រូវអានថា ទិកៈ (ទិក = dika) ។

គ្មានប្រើសំឡេងតាំងពីបុរាណនោះឡើយ ។ បើទុកជាគង់សតវត្សដំបូងៗ មិនទាន់មាន ក៏គង់សតវត្សក្រោយៗមកពីសតវត្សរ៍ ១០ មកដល់ចុងសតវត្សទី ១៤. គួរជឿថាមានឡើងហើយដែរ ។ ទោះយ៉ាងណាក៏ដោយ ពាក្យ មួយ ម្វាយ ធ្វើឲ្យយើងឃើញថាសំឡេង អួ មានហើយដោយពិតប្រាកដ; ប៉ុន្តែគេអ្វីដាក់តាងសំឡេងនេះពុំបាន បុព្វបុរសរបស់យើងក៏យកជើង វ មកប្រើជាស្រៈ អួ មួយគល់ទៅ ។ តែក៏នៅពុំទាន់ពេញចិត្តនៅឡើយ ទើបក្រោយបន្តិចមក លោកយកស្រៈ អា មកផ្សំផង ដើម្បីជាគ្រឿងតំណាងសំយុក្តស្រៈ អួ៖ ម្វាយ = មួយ ។ សំរាប់ស្រៈ អៀ ក៏ដូចគ្នា ។ ទៀ = ទី អក្សរស្រៈគានជាស្រៈ, លោកថែមស្រៈ អា មកទៀត ទៅជាសំយុក្តស្រៈ៖ ទៀា = ទី + អា = ទៀ ។

ហេតុអ្វីក៏បុព្វបុរសរបស់យើង ស៊ូទ្រាំខ្វះរូបស្រៈប្រើបានដល់អស់វេលាជាងពាន់ឆ្នាំដូច្នេះ? ហេតុដែលបណ្ដាលឲ្យទៅយ៉ាង

នេះមានពីរប្រការ ។

ប្រការ ១.– គឺមកពីចិត្តប្រកាន់វាទៀមដើម (esprit conservateur) ។ ជាការណ៍គួរគប់ជាសេចក្ដីពិតបាន ជាកាលទើបនឹងយកអក្សរវេណ្ណាមកប្រើថ្មីៗនោះ បុព្វបុរសរបស់យើងពុំទាន់មានវេលា ពុំទាន់មានឱកាសនឹងបង្កើតសញ្ញាថ្មីថែមទៀត ដើម្បីកត់សូរសំឡេងភាសាខ្មែរឲ្យសព្វគ្រប់ទេ ។ លោកប្រើតែស្រៈសំស្ក្រឹតដែលមានមកហើយតែប៉ុណ្ណោះ ដូចជាយើងប្រើអក្សរបាលីនិងសរសេរឈ្មោះខ្មែរសព្វថ្ងៃនេះៗ ភាសាបាលីជាភាសាពហុព្យាង្គ ក្រស្រៈជាភាសាសំស្ក្រឹតទៅទៀត ។ ម្ល៉ោះហើយយើងក៏សរសេរតាមតែបានទៅ ៖ ឧ. kompong-cham នឹងអានថា កំពង់ចាម ក៏បាន ថា កំពោងចាំ ក៏សឹងបាន ។

លុះសរសេរ ទិក̄, ស្លិក̄, លិង̄, មូយ̄, ម្វាយ̄, ជើង̄... ដូច្នេះរាប់រយឆ្នាំទៅ បែបសរសេរ

នេះក៏ទៅជាទំនៀម ។ កាលបើទៅជាទំនៀមហើយ លោកក៏មិនចង់ទុកបែបដើម មិនសូវចង់ប្រែប្រួលទៅតាមសម្លេងនិយាយឡើយ ដូចជាពាក្យ អ្នក អញ ហោង សព្វថ្ងៃនេះៗ

សេចក្ដីខ្លះស្រះប្រើក្នុងសម័យបុរាណ គង់មាននាំមកនូវសេចក្ដីបង្វៀតចង្អល់ចិត្ត ដល់អ្នកសរសេរនិងអ្នកអានក្នុងសម័យនោះមិនលែងឡើយ ។ ទើបយើងឃើញមានសរសេរ ម្ដាយិ ដោយអនុលោមទៅតាមសូរម្លេងក្នុងសិលាចារឹកពីដើម រហូតមកដល់សតវត្ស ទី ១០ ។ ប៉ុន្តែតាំងពីដើមសតវត្ស ទី ១១ ទៀតមក លោកលើករបៀបសរសេរបែបទំនើបថ្មី ម្ដាយ បោលចេញទៅ ត្រឡប់សរសេរជា ម្ដាយិ ឲ្យត្រូវតាមទំនងដើមវិញ ។ រហូតដល់មកសតវត្ស ទី ១៨ ដែលមានស្រៈ ឬ ហើយក៏នៅតែសរសេរ ម្ដ្យ ទៀត ។ ហេតុការណ៍នេះបង្អុលឲ្យយើងឃើញថា សន្តានចិត្តដែលនាំឲ្យទុកទំនៀមដើមនោះ មានបុព្វានុភាពប៉ុន្មានទៅ ។

ប្រការ ២.- តាំងពីយើងបានទទួលភាសាធម៌ពីឥណ្ឌា មករហូតដល់ផុតសម័យសិលាចារឹក (សតវត្សទី ១៤) ភាសាខ្មែរជាភាសាទី ២ គឺជាភាសាសំរាប់សមញ្ញជន ប្រើនិយាយឲ្យស្តាប់បានដោយងាយ គឺជាភាសាសំរាប់អ្នកល្ងង់ខ្លៅនិយាយគ្នា ឬសរសេរទៅមកកាន់គ្នា ។ ឯភាសាដែលអ្នកចេះដឹងប្រើការក្នុងសាសនាក្តី ក្នុងវិទ្យាសាស្ត្រផ្សេងៗក្តី ក្នុងអក្សរ-សាស្ត្រក្តី ក្នុងផ្លូវរាជការ ( ដោយចំពោះក្នុងផ្លូវទូត )ក្តី គឺភាសាសំស្ក្រឹត បែបកែភាសាបារាំងដែលយើងប្រើក្នុងសម័យបច្ចុប្បន្ននេះ ។

ភាសាសំស្ក្រឹតជាភាសាពិបាករៀនណាស់ គេត្រូវប្រើពេលអស់ច្រើនឆ្នាំទើបចេះល្មមប្រើការបាន ។ ប៉ុន្តែជាភាសាដែលលោកបានរៀបចំមានក្បួនខ្នាតដោយហ្មត់ចត់ ប្រើការសំរាប់សំដែងសេចក្តីនឹកគិត របស់មនុស្សបានដោយច្បាស់លាស់ស្រឡះទូលាយ ។ ម្ល៉ោះហើយយើងខំប្រឹងសូត្ររៀនតែភាសាសំស្ក្រឹត; យើងខំគុបតែងថែទាំទុកសំស្ក្រឹត ផ្ទុស

ប្រហែសមិនបានរៀបចំផ្ចិតផ្ចង់កំពង់ខ្មែរផង ។ បើទោះជា ភាសាខ្មែរខ្វះគ្រឿងសំគាល់ខ្វះ ដាក់គាងសម្លេងមិនគ្រប់គ្រាន់ ក៏មិនជាអ្វីដែរ ព្រោះគេមិនប្រើភាសាខ្មែរក្នុងការសំខាន់ៗ ។

ជោគអាក្រក់មកដល់ជាតិយើងនៅកណ្ដាលសតវត្សទី ១៤ ។ កាលនោះជាតិសៀមដែលពីដើមជាជាតិអនារ្យៈ នៅជាយដែនខាងជើងរបស់អាណាចក្រខ្មែរ ធ្លាប់ចំណុះខ្មែរ ធ្លាប់រៀនសូត្រពីខ្មែរ បានកសាងខ្លួនជាប្រទេសខ្លាំងពូកែជាលំដាប់ ទាល់តែបានជាប្រទេសឯករាជ ហើយចូលមករបៀតបៀនវាយប្រទេសយើងជាច្រើនលើកច្រើនគ្រា ដណ្ដើមយកយសោធរ (អង្គរ) ដែលជារាជធានីរបស់យើងក្នុងសម័យនោះបានសំរេច ។ កាលណាទ័ពសៀមត្រឡប់ទៅប្រទេសសៀមវិញ តែងដឹកនាំជញ្ជូនទ្រព្យសម្បត្តិនិងកៀរមនុស្សជាច្រើនយកទៅផងជាដរាប៖ កៀរយកអ្នកប្រាជ្ញរាជបណ្ឌិតគ្រូអាចារ្យ ព្រមទាំងគម្ពីរសាស្ត្រាក្បួនតម្រាផ្សេងៗ ។ ខ្មែរក្នុងគ្រាបរាជ័យនោះ រវល់នឹងរត់ភៀសភ័យរកវេលាឲ្យកូនទៅរៀន

សូត្រតាមប្រក្រតីពុំបាន, សមត្ថៈគ្រូនិងគម្ពីរសាស្ត្រាទៀតផង ភាសាសំស្ក្រឹតក៏លត់សូន្យក្នុងប្រទេសខ្មែររាប់ ១ ត ឬ ២ ត មនុស្ស ព្រមទាំងវិជ្ជាការទាំងឡាយដែលយើងធ្លាប់ចេះដឹង ដោយការអាស្រ័យភាសានោះផង ។

កាលមហាក្សត្រិយ៍របស់យើងថយចាកចោលយសោធរ ក្នុងភាគដំបូងនៃសតវត្សទី ១៥ ទូកសំស្ក្រឹតដ៏វិចិត្របទនានោះ ចេញបាត់ទៅហើយ, នៅសល់តែកំពង់ខ្មែរដែលស្តុកពេញ ទៅដោយវល្លិ៍លតាស្មៅបន្លាផ្សេង ៗ ។ យើងក៏ត្រូវត្រឡប់ បែរមកកាប់គាស់រៀបចំភាសាខ្មែររបស់យើងវិញ ។

ការរៀបចំភាសាខ្មែរជាដំបូង បានធ្វើឡើងក្នុងសម័យ លង្វែក ដោយចំពោះក្នុងរជ្ជកាលព្រះបាទអង្គចន្ទទុកជានិងព្រះ បាទបរមរាជា (សតវត្សទី ១៦) ។ គឺធ្វើឡើងដោយ អាស្រ័យគម្រាប់គម្រាខ្វះដែលនៅសល់ពីសម័យអង្គរ ។

នៅចុងសតវត្សទី ១៦ យើងមានស្រៈ ឰ ថែមមួយ

ទៀត ឧ. កម្រែតង លែង (មុនសម័យនោះសរសេរ កម្រេតនិ លេនិ) ។ សម្ដេច អៀ លែងសរសេរ អ្យា ដូចក្នុង ព្យាង់ ទៀតហើយ ត្រឡប់សរសេរជា អ្យ វិញ ឧ. រៀង បៀតបៀន ។

សម្ដេច អួ សរសេរដោយបោកអន្ត្យស្រៈ ៀ និងស្រៈ អូ ផ្សំគ្នា ឧ. រៀប ឬ រៀូ = រួប ។

ក្នុងសម័យនោះឯង សៀមមកវាយបើងជាគ្រាធំមួយផងទៀតវាយកំទេចក្រុងលង្វែក ដឹកនាំយកសម្បត្តិទ្រព្យគម្ពីរ-សាស្ត្រក្បួនតម្រាអ្នកចេះដឹងបណ្ឌិតបន្ទៀរយកទៅអស់ ។ តាំងពីគ្រានោះមក ខ្មែរសរសេរពាក្យដែលខ្ចីយកពីសំស្ក្រឹតឬបាលីមកប្រើ លែងត្រឹមត្រូវដូចសម័យមុនៗ ។

ភាសាខ្មែរបានល្អូតលាស់មួយផងទៀត ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី៤ ក្នុងភាគខាងចុងនៃសតវត្សទី ១៧ ។ ក្នុងសម័យនោះស្ដេចខ្មែរកាលនៅកុមារនៅឡើយ តែងតែត្រូវ

យ៉ាងជ្រៅទទួលការសិក្សានៅប្រទេសសៀមទើបទទួលអារ្យធម៌ (influence) សៀមមានផ្សាយចូលមកក្នុងស្រុកខ្មែរ ។

ដល់គ្រិស្តសករាជ ១៧០១ យើងមានស្រៈ

អ៊ឺ (គឺ)

អ៊ួ (ជួយ)

អើ (កើត) (១)

អឿ (គ្រឿង) (២)

---

១— ក្នុងភាគដើមនៃសតវត្សទី ១៧ កាលយើងមិនទាន់មានស្រៈ *អើ* នៅឡើយ យើងមានកត់សំឡេង *អើ* តាមសៀមខ្លះ ។ ដើមដំបូងឃើញមាន ចំពោះតែពាក្យ *បើ* ក្នុងសិលាចារឹកលេខ ១០ គ.ស. ១៦២៨ (សៀវភៅសិលាចារឹកនគរវត្ត ទំព័រ ៣០) សរសេរម្តងៗជា *ប្អេហ* ។ កាលនោះសៀមនៅសរសេរមិនដើងតាមយើង, ប្រសិនជាសរសេរតាមបែបសៀមឥឡូវនេះ ត្រូវដាក់ *បេអ* អានថា *បឺ* ។

២— ចំពោះពាក្យ *មឿន* ដែលជាពាក្យសៀមឃើញមានសរសេរជាដំបូងជា *ម្អើន* (សៀវភៅដដែលទំព័រ ២២) ក្នុងសិលាចារឹកលេខ ៨ គ.ស. ១៦២៥ ។ សព្វថ្ងៃសៀមសរសេរ *មើអន* ។

## អៀ (គេះជៀស)(១)

ប៉ុន្តែស្រៈថ្មីទាំងនេះជួនកាលក៏ប្រើ ជួនកាលក៏នៅសរសេរតាមបែបពីដើម ដូចជា គុំ (គឺ), ព្រុយ (ព្រួយ) បើកេត (បើកើត). . . ។

ស្រៈ អ៊ឹ កើតក្រោយគេបង្អស់ តែមិនប្រាកដជាកើតនៅក្នុងកាលណា ។ ក្នុងសម័យអង្គរយើងមានប្រើនិគ្គហិតដាក់លើស្រៈ អ៊ិ មួយគ្រាដែរ តែឲ្យអានទៅតាមសំស្រ្កឹត គឺនិគ្គហិតបញ្ចេញសំឡេងដូចខ្យល់ ម្ង៉ៈដូចពាក្យ ប្ញឹ ដែលមានក្នុងសិលាចារឹកប្រាសាទកំផែស ( K. 668 គ.ស. ៩៧៦ ) ។ ពាក្យ ប្ញឹ នេះ គ្រង់ទឹងពាក្យខ្មែរបច្ចុប្បន្ន ផ្ញឹម ក្នុង ផ្ញឹម-អំពរ(២) ។

---

១– ស្រៈ អៀ កាលនៅកណ្តាលសតវត្សទី ១៧ មានសរសេរជាអៀ ឧ. រៀង (រៀង) បៀតបៀន (បៀតបៀន) ។ សៀប៖ រើយង គានរៀង ។ ២–ក្នុងវចនានុក្រមខ្មែរ, លោកដាក់ជាពាក្យ ផ្ញឹម ( ឆ្នង .. )

និគ្រហិតក្នុងសម័យបុរាណ មានការប្រើច្រើនយ៉ាងជាង
សព្វថ្ងៃ ។ ឯសម្លេងដូចខ្យល់ ឬ ទាំងអស់ ។
ក្រៅពីដាក់លើស្រៈ

---

នេះមកពីសៀម ។ កាលបើយើងដឹងថាពាក្យនេះយើងបានប្រើមកយ៉ាងតិចតាំងពីសតវត្សទី ១០ នោះប្រការមួយ; ហើយប្រការពីរ កាលបើប្រវត្តិសាស្ត្រសំដែងថា កាលនោះសៀមនៅក្នុងដែនចិននៅឡើយ តាំងខ្លួនជាប្រទេសឯករាជ្យ ១ ឈ្មោះណានចាវក្នុងខេត្តយូណានសព្វថ្ងៃនេះ មិនទាន់តាំងនាមជាសៀមឡើង, ជនជាតិថៃមានចូលមកនៅក្នុងអាណាចក្រខ្មែរខ្លះមែនក្នុងសម័យនោះតែមកនៅតែឯជាយដែនភាគខាងជើងត្រង់កំពង់សុខោទ័យ (ខាងត្បូងឈៀងម៉ៃ) ជាដើមចូលមកដោយភ័យរងបន្តិចម្តង ប៉ែបយួនចូលមកក្នុងស្រុកខ្មែរសព្វថ្ងៃនេះ ប៉ុន្តែថៃវេលានោះនៅជាអនារ្យជននៅឡើយ មិនប្រាកដជាមានអក្សរប្រើយ៉ាងណាផង;—ប្រការ ៣ កាលបើតាមប្រវត្តិសាស្ត្រ ខ្មែរក្នុងសម័យនោះមានឫទ្ធានុភាពធំមហិមាព្រមទាំងអារ្យធម៌ដ៏ខ្ពង់ខ្ពស់ជាតិថៃជាកូនជំពាក់យើងខាងអារ្យធម៌រហូតមកដល់សម័យលង្វែក (សតវត្សទី ១៦) ទើបចាប់សងបំណុលអារ្យធម៌យើងមកវិញខ្លះ; — កាលបើយើងដឹងថាហេតុការណ៍បានបង្កើតឡើងដូច្នេះហើយ សេចក្តីសង្ស័យទើបមានឡើងត្រង់ទីកំណើតនៃពាក្យ ផ្ទុំ ។ ទីកំណើតពាក្យនេះបើជានៅមាត់ទន្លេភាបត្រើយខាងជើងហាក់ដូចជាសមជាងជានៅឯណានចាវ ។

អ ៣ អំ (សំលោ=សម្ល)

អា - អាំ (ប្រាំ)

អុ - អុំ (កុំ=ខ្ញុំ)

ដូចក្នុងសម័យបច្ចុប្បន្ននេះហើយ នៅមានដាក់លើស្រៈ

អិ (ប៉ិ = ផិម)

អេ (តេំ = ដើម)

អោ (កពោំ= ក្រោម)

ទៀតផង ។

## ២- ប្រវត្តិនៃព្យញ្ជនៈ

ព្យញ្ជនៈដែលយើងប្រើពីដើម ជាព្យញ្ជនៈបំស្រុត មានចំនួនលើសចំនួនព្យញ្ជនៈដែលយើងប្រើសព្វថ្ងៃពីរអក្ខ ។

គឺ ឞ និង ឝ

ហៅថា ស-ប (ឞ) ស-គ (ឝ) ។

ឯ ស ដែលយើងប្រើសព្វថ្ងៃនេះ ហៅថា ស · ឈ ។

ឞ និង ឝ មានប្រើដល់មកផុតសតវត្សទី ១៧ តែដល់មក គ.ស. ១៧៤៧ ឃើញយក ស ប្រើជំនួសវិញ លើកលែងប្រើអក្សរពីរអង្គនេះទៅ ។

ក្នុងសម័យបុរាណ ព្យញ្ជនៈមុទ្ធជៈ (cérébrales) ដ ឋ ឌ ឍ ណ ឡ ហើយនិង ឞ ឝ ទុកសំរាប់ប្រើ តែចំពោះពាក្យដែលមកពីសំស្រ្កឹត ឬបាលី, ក្នុងពាក្យខ្មែរសុទ្ធៈលោកមិនប្រើទេ ។ លោកយក

ឝ ប្រើជំនួស ដ ឧ. ឝល់ (ដល់)

ង – ណ ឧ. ឯងាម្ស្យ (ឯណាមួយ)[1]

ល – ឡ ឧ. លេយ (ឡើយ) ។

---

១– មើលសៀវភៅ « សិលាចារឹកនគរវត្ត » ទំព័រលេខ ៨២ ។ សៀវភៅនេះមានដាក់នៅព្រះរាជបណ្ណាល័យភ្នំពេញ ។

# ៣- ប្រវត្តិនៃវណ្ណយុត្តិ

ហេតុមកដល់ផុតសម័យអង្គរ (ចុងសតវត្សទី ១៤) យើងមានប្រើតែវណ្ណយុត្តិ ២ គឺ វិរាមៈ (-) ដែលជាវណ្ណយុត្តិសំស្ក្រឹតហើយនិងរបាទ (៌) ដែលមានប្រើក្នុងភាសាសំស្ក្រឹតដែរ ។ របាទ អ្នកបានស្គាល់ស្រាប់ហើយព្រោះមានប្រើមកដល់សម័យបច្ចុប្បន្ន ។ ឯវិរាមៈលោកប្រើសំរាប់សំគាល់ថាព្យញ្ជនៈដែលនៅពីក្រោមវណ្ណយុត្តិនេះ គ្មានស្រៈ អ អាស្រ័យទេ ដូចមានអធិប្បាយរួចមកហើយ ។

តអំពីសម័យអង្គរ មកដល់អស់សម័យលង្វែក (ចុងសតវត្សទី ១៦) វិរាមៈលើកលែងប្រើទៅ តែមិនមានបង្កើតវណ្ណយុត្តិថ្មីឡើងទេ ។

សំយោគសញ្ញា យើញមានប្រើជាដំបូងនៅភាគដើមនៃសតវត្សទី ១៧ តែមុខការរបស់វណ្ណយុត្តិនេះ មិនទាន់បានទៀងទាត់ភ្លាមទេ ។ ជួនកាលប្រើបែបសព្វថ្ងៃនេះ ឧ. ត្រ័ស (ត្រាស់), ទ័ង (ទាំង), អម្ប័ល (អម្បាល់),

ជូនកាលប្រើជាស្រៈសញ្ញា ឧ. ប្រ់ាក (ប្រាក់), អម្ប់ាល (អម្បាល់), ក់ាន (កាន់); ជូនកាលប្រើជួសឲ្យ ង (១) ឧ. ឆ់ា (ឆាង), អានិស់ (អានិសង្ស), អ់ (អង្គ), ទ់ា (ទាំង)... ។ មុខការខាងក្រោយនៃសំយោគសញ្ញានេះ នាំឲ្យសន្ស័យថា ៈគ្រឿងសំគាល់នេះមានកំណើតមកពីដើម ឯ ( ្យ ) ទេក៏មិនដឹង ។ សិលាចារិកដែលខ្ញុំបានប្រទះឃើញនោះ អស់នៅ គ.ស. ១៧៤៧ ។ ដល់មកឆ្នាំនោះមិនឃើញមានប្រើវណ្ណយុត្តិអ្វីឲ្យលម្អិតយកមកពោលក្នុងទីនេះបានក្រៅពីបារ និងសំយោគសញ្ញានេះឡើយ ។ វណ្ណយុត្តិឯទៀត សុទ្ធសឹងតែកើតក្រោយសម័យនោះទាំងអស់ តែមិនប្រាកដថាកើតក្នុងសម័យណា ។ ឯវណ្ណយុត្តិដែលកើតក្រោយគេបំផុតនោះគឺយុគលពិន្ទុ (:) ។

---

១— «មើលសៀវភៅសិលាចារិកនគរវត្ត» ត្រង់លេខ ១២ ទៅដល់លេខ ១៨ ពីទំព័រ ៣១ ទៅដល់ ៤៩ ។

## ៤- ប្រវត្តិនិងលក្ខណៈនៃខ្យល់

ខ្យល់របស់ពាក្យខ្មែរសុទ្ធ មានលក្ខណៈ ៣ យ៉ាង ។

ក)- ខ្យល់របស់ពាក្យខ្មែរសុទ្ធជាព្យញ្ជនៈ មួយអង្គ ក្នុងបណ្តាព្យញ្ជនៈ ១៣ អង្គតទៅនេះ ៖ ៨ អង្គជាព្យញ្ជនៈដើមវគ្គនិងចុងវគ្គ លើកលែងវគ្គ ដ ចេញ គឺ ក ង, ច ញ, ត ន, ប ម; ៥ អង្គទៀតជាព្យញ្ជនៈអវគ្គ គឺ យ រ ល វ ស។ ក្រៅពីព្យញ្ជនៈ ១៣ អង្គនេះ ព្យញ្ជនៈឯទៀតមិនអាចប្រើជាខ្យល់ក្នុងពាក្យខ្មែរសុទ្ធបានឡើយ ។

ខ)- ខ្យល់របស់ពាក្យខ្មែរសុទ្ធ ជាព្យញ្ជនៈពោលមិនដែលជាព្យញ្ជនៈគំរូតទេ ។

លក្ខណៈទាំង ២ យ៉ាងនេះជាគ្រឿងសំគាល់នាំឲ្យយើងក្រឡេកទៅដឹងបានភ្លាមថាជាពាក្យខ្មែរសុទ្ធ ឬជាពាក្យខ្ចីពីភាសាក្រៅ ។ ប៉ុន្តែមិនត្រូវវាយសេចក្តីថាពាក្យដែលប្រកបដោយលក្ខណៈទាំងពីរនេះ សុទ្ធតែជាពាក្យខ្មែរសុទ្ធទាំងអស់

ទេ ។ ពាក្យដូចជា ត្រកូល ពល អាកាស ជាពាក្យខ្ចី ពីបាលីសំស្ក្រឹត ។

គ)- ខ្យល់របស់ពាក្យខ្មែរសុទ្ធជាតួព្យញ្ជនៈ មិនមែនជាជើងព្យញ្ជនៈទេ ។

លក្ខណៈទាំង ៣ នេះ ជាសម្បត្តិរបស់ពាក្យខ្មែរសុទ្ធ ទាំងពួងអស់កាលដ៏អង្វែង តាំងពីយើងកខ្លួនបានជាប្រទេសជាតិ ហើយថ្កុំថ្កើងជាចក្រវត្តិ រហូតមកដល់ជាតិយើងធ្លាក់ខ្លួន លើករាជធានីចេញចាកពីអង្គរក្នុងសតវត្សទី ១៥, គិតទៅវាង ១ ពាន់ឆ្នាំ ។ តាំងពីគ្រានោះមក អក្សរយើងសរសេរទៅដោយខ្វល់ល្ងង់ ឥតគោរពដល់ក្បួនខ្នាតអ្វីដោយបាំបួនឡើយ ៖

១)-យក ណ៎ា និង ហ ជាខ្យល់ក៏មាន ឧ. ខណ្ហា (ខ្ហ) ស្លាហអំម្ហ[1] (ស្លាម្ហ) ។

---

(១) មើលសៀវភៅ ‘‘សិលាចារិកនគរវត្ត,, ត្រង់លេខ ៤ គ. ស. ១៩៦៦ ទំព័រ ១៣-១៥ ។

២)– ដាក់ខ្យល់ជាព្យញ្ជនៈត្រួត ក៏មាន ឧ. ប្រកោប្ប (ប្រកប), វន្តាប្ប (វពាប់), ពុំនាក្ក (ពំនាក់)(១)

៣)– យកជើងព្យញ្ជនៈជាខ្យល់បក ដូច្នេះ រហូតមក ដល់ទីរសតវត្សទី ២០ នេះ ឧ. ទាំ្ង (ទាំង), តា្ម (តាម) ហើ្យ (ហើយ) ។

ក្នុងសម័យបច្ចុប្បន្ន លោកលើកបោលលែងសរសេរតាមបែបការច្រឡំនេះទៀតហើយ ។ ដោយចំពោះត្រង់យកជើងអក្សរជាខ្យល់នេះ ធ្វើទៅដោយខុសទិសរបៀបអក្សរពិត ។ ព្រោះជើងអក្សរសំរាប់សំគាល់ថា តួព្យញ្ជនៈដែលនៅពីលើគ្មានស្រៈ អ អាស្រ័យទេ ដូចក្នុងពាក្យ ល្អ ប្រធាន ។

(១) សៀវភៅដែលលេខ ៣ ចុងសតវត្សទី ១៦ ទំព័រ ៧-៨ ។ ខ្ញុំសូមទៀតខកាលនេះតវ៉ាអំពីពាក្យ ពំនាក់ ដែលលោកដាក់ក្នុងវចនានុក្រមជាមកពីសៀម ។ ពាក្យនេះជាពាក្យខ្មែរកើតមកពីពាក្យ ពាក់ ជាមូលបទ ។ ពាក្យ [illegible] ពាក់ មិន ពំនាក់ សៀមខ្ចីយើងយកទៅប្រើជាមួយនឹងពាក្យរបស់វាច្រើន ។

គួរញ្ញូវៈ ល្ប និង ឬ គុនពាក្យនេះបញ្ចេញសម្លេងតែកន្លះមាត្រា ឯដើមអក្សរត្រូវបញ្ចេញសម្លេងពេញមាត្រា ។ កាលយកដើមអក្សរជាខ្យល់ ដើមអក្សរនោះត្រឡប់ជាត្រូវបញ្ចេញសម្លេងដោយខុសក្បួនមិនពេញមាត្រាវិញ ។ ខ្ញុំយល់ដូច្នេះបានជាខ្ញុំលែងប្រើដើមអក្សរជាខ្យល់ទាល់តែសោះទៅតែម្តង ។ ស្រាប់តែសរសេរសៀវភៅនេះជិតរួចទៅហើយ ទើបបើកវចនានុក្រមប្រទះនឹងពាក្យ ឱ្យ លោកឲ្យយកដើម ឃ ជាខ្យល់ ។ ខ្ញុំក៏កែពាក្យ ឱ្យ នេះឡើងវិញឲ្យត្រឹមត្រូវគ្រប់កន្លែង បើតាមស្មានជិតដល់យកខ្លែង ។ កាលខ្ញុំកែរួចហើយ ខ្ញុំសូមគិតគ្រង់ពាក្យនេះដោយពេញកំលាំង ។ បើពាក្យដូច ញុំ ញ៉ា ញ៉ើ ញើ ញ៉ូ... យើងតែហាលលែងសរសេរដូច្នេះអស់ហើយ ខ្ញុំរកនឹកមិនឃើញជាមកពីហេតុអ្វីបានជាត្រង់ពាក្យ ឱ្យ ក៏លោកមិនកែផង ។ បើខុសបែបបុរាណ ខ្ញុំយល់ថាមិនគួរទុកបែបជាន់គាប់ខ្មែរវាង ៣៥០

ឆ្នាំខាងក្រោយ ដែលជាបែបខុសនេះទេ គួរទុកបែបបុរាណ ត្រឹមត្រូវកាលណាយើងថ្កុំថ្កើងរាង ១ ពាន់ឆ្នាំនោះវិញ ។ សូមឲ្យមើលសិលាចារិកសម័យហ្វូណនមុនសម័យអង្គរៗ ពាក្យ ឲ្យ សរសេរ ឱយ ប្រកបចំដើរ ឬ ជាឲ្យល់ជាដរាបគ្មានលោះ មួយដងណានោះ ។

## ផ្នែកទី ២

## វិធីអាន

### ក - សំឡេងស្រៈ

ការអាន ស្រៈ ២១ អង្គ ៖ អ អា អិ អី ... – តាមដែលឲ្យហាត់រៀនក្នុងវគ្គ ១ ក្នុងសាលាពេទ្យការសព្វថ្ងៃនេះ–ពប់ បានជាសមហេតុសមផលហើយ ។ ប៉ុន្តែពីដើម ចំពោះស្រៈខ្លះ យើងមិនមែនអានដូចសព្វថ្ងៃនេះទេ ។ ហេតុដល់មកដើមសតវត្សទី ២០ នេះ

ស្រៈ ឥ យើងអាន អិក

" ឧ " អុក

" ឪ " អូវ ។

ស្រៈ ឪ សព្វថ្ងៃនេះជាទីឃៈ (វែង) ប៉ុន្តែព្រោះតែពីដើមយើងអានទំនងរស្សៈ (ខ្លី) ទើបយើងនៅសរសេរ ស្រូវ ឪ ត្រូវ ។ល។ ជាប់មកដល់វេលានេះ ។ តាមត្រូវយើងគួរសរសេរជា ស្រុវ ឧវ ត្រុវ ។ល។ វិញ ។

ស្រៈ ឥ អានតាមធម្មតាថា អិ ក៏មាន ៖

១. ឥត ឥន្ទ ឥរិយា. . .

អានតាមសំស្ក្រឹតបាលីដោយចំថា អ៊ិ ក៏មាន ៖

១. ឥធលោក ឥស្សា ឥស្សរៈ...

អានតាមគាប់ច្បាប់ថា អី ក៏បាន ៖

ឧ. ឥឡូវ ឥវ៉ាន់ (១) ឥសី... ។

ស្រៈ ឩ អានតាមជនសាមញ្ញថា អ៊ុក តែដល់ភ្ជាប់នឹងអក្សរដទៃទៅមិនមានចេញសម្លេងថា អ៊ុក ទេ;

អានតាមធម្មតាថា អ៊ូ ក៏មាន ៖

ឧ. ឩកញ៉ា ឩក្រិដ្ឋ ឩស...;

អានតាមបាលី សំស្ក្រឹតថា អ៊ុ ក៏មាន៖

ឧ. ឩត្តមៈ ឩប្ការៈ ឩទកៈ... ។ (២)

ស្រៈ ឪ (ឳ) អានតាមជនសាមញ្ញថា អ៊ូវ ក៏មាន៖

ឧ. ឪពុក ឪឡឹក ឪទិន...;

---

១— ក្នុងវចនានុក្រមលោកសរសេរជា អ៊ីវ៉ាន់ វិញ ។ សរសេរដូច្នេះត្រូវតាមសំឡេងល្អជាង ។

២— ក្នុងពាក្យខ្លះ ដូចជាពាក្យ ឧត្តម ឧ០ ឧបាសក តាមសំដីជនសាមញ្ញ ក្លាយទៅជា អូវ ។ សម្លេងក្លាយយ៉ាងនេះ ត្រូវលើកចោលចេញ កុំឲ្យមាន ។

អានតាមធម្មតាថា ឫ ក៏មាន, តែបើអានដូច្នេះ លោកសរសេរជា ឬ៖

ឧ. ឬម! ឬស្សី ;

អានតាមបាលីសំស្ក្រឹតថា រឹ សរសេរ ឫ ដដែលក៏មាន៖

ឧ. ឫទ្ធិ ។

ស្រៈ ឯ អានតាមធម្មតាថា អែ៖

ឧ. ឯកើត ឯង ឯក...;

អានតាមបាលីសំស្ក្រឹត ថា អេ៖

ឧ. ឯរាវណ ។

សេចក្ដីសង្កេត.– ស្រៈសំស្ក្រឹតពេញតួ ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ ១២ អង្គនេះ ច្រើនមានសម្លេងមិនទៀងទាត់ នាំឲ្យពិបាកក្នុងការអានអក្សរខ្មែរបន្តិចម្ដងៗ ស្រៈ ១២ អង្គនេះ យើងមានអក្សរឯទៀត ប្រើជំនួសដោយ

បរិបូណ៌ ហើយដោយទៀងភាគខាងសម្លេងផាងផង ៗ ហេតុនេះបើយើងលើកពោលវែងប្រវៅ កំមិនឃើញមាន ទើសភាស្សំអ្វី ក្រៅពីថ្ងូកក្អួកថ្ងូកដៃតែប៉ុណ្ណោះទេ ៗ ឯសេចក្ដីស្រួលដែលទីទៃបង្កើតឡើងនោះ ក្រៅពីញ៉ាំងសម្លេងអក្សរចំពួកនេះឲ្យបានទៀងភាគងាយការហើយ នៅធ្វើឲ្យចំនួនអក្សរយើងតិចមក ងាយរៀនឲ្យចាំ ងាយបោះពុម្ពទៀតផង ៗ

## ១.– សម្លេងព្យញ្ជនៈ

ក្នុងព្យញ្ជនៈ ៣៣ អក្ខ មាន ១២ អក្ខដែលសម្លេងមិនទៀងភាគគឺ ៖

ព្យញ្ជនៈ ចុងវគ្គទាំង៥ ៖ ង ញ ណ ន ម ៈ

ព្យញ្ជនៈ ដើមវគ្គ ២ អក្ខ ៖ ត ប ហើយនិង

ព្យញ្ជនៈ អវគ្គ ៥ អក្ខ ៖ យ រ ល វ ហ ។

ដែលថាសម្លេងមិនទៀងភាគនោះ មិនមែនថាព្រោះផ្លាស់សម្លេងដោយសារវណ្ណយុត្តិ ដូចជា ង៉ ញ៉ ហ៊...នោះ

ទេ ។ ព្យញ្ជនៈដែលខ្វល់វណ្ណយុត្តិយ៉ាងនេះក៏កប់ចោលរៀង ចាត់បានដែរ ព្រោះអក្ស ២ យ៉ាងពុំបាន ។

ឯថាសំឡេងមិនទៀងនោះ គឺរូបគង់នៅដដែលតែសំឡេងជួនកាលថាយ៉ាងនេះ ជួនកាលថាយ៉ាងនោះ ។ ក្នុងវិធីនេះនឹងនាំយកតែព្យញ្ជនៈ ត មកនិយាយ ។ ព្យញ្ជនៈ ១១ អក្សរទៀតសំរាប់អធិប្បាយក្នុងទំព័រខាងក្រោយនេះ ។ ត នេះពីបូរាណ លោកប្រើជួស ដ ផងព្រោះព្យញ្ជនៈវគ្គ ដ (ដ ឋ ឌ ឍ ណ) លោកមិនប្រើសំរាប់ពាក្យខ្មែរសុទ្ធទេ

ឧ. តែល (ដែល), តល់ (ដល់) តើម (ដើម) ។

ម្ល៉ោះហើយពាក្យដូចជា ត្បូប ត ដើម្បីនឹងចំណាំត្រូវអានថា ដ្បូប ដ៏ មួយ។ សោតថា ត្បូប ត គឺគោលអាស្រ័យទំនងរបស់សេចក្តីខាងនោះឯង ។

សព្វថ្ងៃនេះ យើងលែងប្រើ ត ជួស ដ ដូច្នេះទៀតហើយ ។ យើងគួរត្រេកអរណាស់ ដោយក្រុមប្រាជ្ញយើង

ជាន់ក្រោយនេះ លោកហាក់ទាន់ការឧបសគ្គសំរេចការកែប្រែនេះទៅបាន ដោយមិនរញ៉េរញ៉ៃនឹងការប្ដូរក្ដួរប្ដូរដៃ; ដៈការណ៍ឲ្យយើងសង្ឃឹមថា អ្នកប្រាជ្ញយើងក្នុងបច្ចុប្បន្នកាលគង់ហាក់ទាន់ការឧបសគ្គបែបនេះ ដើម្បីកែប្រែរបៀបអក្សរយើងខ្លះទៀត ឲ្យកាន់តែត្រឹមត្រូវហើយស្រួលបួលទាន់សម័យឡើង ។

ដូច្នេះយើងសំគាល់បានថាក្នុងពាក្យខ្មែរសុទ្ធ គួ ត្ត អានថា ត្ត ជាដកប គ្មានអានថា ដ្ឋ ទេ ។ មានតែក្នុងពាក្យដែលខ្ចីពីបាលីសំស្ក្រឹតខ្លះ ដែល ត្ត ត្រូវអានអនុលោមតាមសម្លេងខ្មែរជា ដ្ឋ ដូចក្នុងពាក្យ បិតា ប្រក្រតី ធម្មតា... ។ ពាក្យបែបនេះក៏មិនមានច្រើនម៉ាត់ប៉ុន្មានទេ ល្មមយើងសំគាល់ចាំទុកបានដោយមិនចាំបាច់កែ ត្ត ជា ដ្ឋ ឲ្យខុសនឹងនិរុត្តិសាស្ត្រ ។

គួរសង្កេតថាជើង ត្ត និងជើង ដ្ឋ រូបដូចគ្នា ។ ក្នុងព្យញ្ជនៈផ្ទួន យើងអាចដឹងបានថាជាជើង ត្ត ឬ ដ្ឋ ដោយ

អាស្រ័យតួព្យញ្ជនៈដែលនៅពីលើ ដូចនឹងមានគេពិប្រាយទៅ ខាងក្រោយ ៗ ឯក្នុងអក្សរផ្ទើជើង យើងគ្មានអ្វីជាសំគាល់បានឡើយ ៗ តែតាមធម្មតា ជើង ក្ត គ្មានក្នុងផ្ទើជើងទេ មានតែជើង ប្ដ ៗ ប៉ុន្តែក្នុងពាក្យខ្លះមានជើង ក្ត ផ្ទើដែរ ដូចក្នុងពាក្យ ស្ដោក ស្ដេត ទ្ដត ៗ សេចក្ដីមិនស្រួលកាន់ត្រង់នេះ មកពីយើងប្រើជើងអក្សរ ៗ កាលណាបើយើងកាត់ចិត្តលែងប្រើជើងអក្សរទៅ ត្រូវឲ្យយើងបង្កើតរូបស្រៈ អូ ឲ្យមានដូចបារាំងឡើង យើងនឹងសរសេរពាក្យអក្សរបានដូចបារាំង សេចក្ដីមិនស្រួលត្រង់នេះក៏នឹងបាត់ទៅឯង ព្រមទាំងសេចក្ដីមិនស្រួលឯទៀតជាច្រើនផង ៗ

## គ– សំឡេងអក្សរកាលសរសេរបញ្ចូលគ្នា

### ១– ព្យញ្ជនៈផ្សំនឹងស្រៈ

ក្នុងភាសាបាលីមានស្រៈ ៨ អង្គគឺ៖ អ អា អិ អី អុ អូ អេ អោ; បញ្ចេញសម្លេងជា អៈ អា អ៉ិ អ៉ី អ៉ុ អ៉ូ អេ អោ

តាមសម្លេងដូច្នេះ យើងអាចចែកស្រៈបាលី ៨ អង្គនេះ បានជាពីរពួកគឺ ៖

អ (អៈ), អា, អេ និង អោ (អូ) សម្លេងគ្រលួច (sourdes); អិ (អិ), អី (អី), អុ (អុ), និង អូ (អូ) សម្លេងគ្រលរ (sonores) ។

ក្នុងភាសាបាលី ព្យញ្ជនៈគ្រលួច—ដូចជា ក – កាលបើផ្សំនឹងស្រៈគ្រលរ គឺបញ្ចេញសម្លេងគ្រលរតាមស្រៈ ។

១. ក + ិ > កិ អានថា គិ

ក + ី > កី អានថា គី

ក + ុ > កុ អានថា គុ

ក + ូ > កូ អានថា គូ ។

ព្យញ្ជនៈគ្រលរ ដូចជា ម – កាលបើផ្សំនឹងស្រៈគ្រលួច គឺបញ្ចេញសម្លេងគ្រលួចទៅតាមស្រៈ ។

២. ម + ា > មា អានថា ម៉ា

ម៉ + ើ > ម៉ើ អានថា ម៉ើ

ម៉ + ោ > ម៉ោ អានថា ម៉ូ ។

និយាយដោយខ្លីថា ការព្យញ្ជនៈខ្ចីបញ្ចូលគ្នានឹងស្រៈ សម្លេងដែលបង្កើតឡើង នឹងទៅជាគ្រលួចឬគ្រលរ ក៏ស្រេច តែលើស្រៈដែលផ្សំជាមួយនោះជាស្រៈគ្រលួចឬស្រៈគ្រលរ ។

វិធីអានយ៉ាងនេះ ប្រើក្នុងភាសាភាគច្រើនក្នុងលោក មានភាសាបាលីសំស្រ្កឹត បារាំង និងភាសាអំបូរឥណ្ឌូ-អឺរ៉ុប ទៀតជាដើម ។ ក្នុងភាសាសៀមក៏អានតាមវិធីនេះដែរ ។

ក្នុងភាសាបារាំង

K ( ក ) + a ( ា ) > ka អានថា កា

K ( ក ) + i ( ិ ) > ki អានថា គិ

ក្នុងភាសាសៀម អ៊ី គេអានថា អ៊ី តែបើព្យញ្ជនៈនេះផ្សំនឹងស្រៈ –ិ (អិ) គេអានថា អ៊ិ មិនអានថា អ៊ុ ទេ ។

ឯក្នុងភាសាខ្មែរយើង វិធីអានត្រូវនេះខុសពីគេ; បាន

តែភាសាមនដែលគានបែបយ៉ាង ។

ក្នុងភាសាខ្មែរយើង – តាមរបៀបអក្សរ ស្រៈទាំងអស់ មានសម្លេងគ្រលួច ៖ អ អា អិ អី... ។ តែតាមសេចក្ដីពិត សម្លេងស្រៈ– កាលបើព្យញ្ជនៈនិងស្រៈផ្សំបញ្ចូលគ្នាហើយ (en composition) –ទៅតាមសម្លេងព្យញ្ជនៈទាំងអស់ ។

ន័យ.– សម្លេងដែលកើតឡើងដោយព្យញ្ជនៈ ផ្សំនឹងស្រៈជាសម្លេងគ្រលួចឬគ្រលរ ស្រេចតែលើ សម្លេងព្យញ្ជនៈជាគ្រលួចឬគ្រលរ ។

ប្រែសេចក្ដីថា ៖

១)– កាលព្យញ្ជនៈមានសម្លេងគ្រលួច សម្លេងកើតឡើងដោយផ្សំព្យញ្ជនៈនោះនឹងស្រៈ ក៏ជាសម្លេងគ្រលួចតាមព្យញ្ជនៈ

៖ ក កា កិ កី... ។

២)– កាលព្យញ្ជនៈមានសម្លេងគ្រលរ សម្លេងដែល

កើតឡើងដោយផ្សំព្យញ្ជនៈនោះនឹងស្រៈ គឺជាសម្លេងត្រលរតាមព្យញ្ជនៈ .

ឧ. ម មា មិ មី... ។

ម៉ + ា ៖ ម៉ា សម្លេងត្រលរ ( សម្លេងត្រលួច ។

កាលណាជា ម៉ា សម្លេងទៅជាត្រលរតាមព្យញ្ជនៈ មិនមែនត្រលួច ម៉ា តាមស្រៈទេ ។

## ២– ព្យញ្ជនៈផ្សំនឹងព្យញ្ជនៈ

ដែលហៅថាព្យញ្ជនៈផ្សំនឹងព្យញ្ជនៈនោះ គឺ : ព្យញ្ជនៈពីរអក្ខរៈនៅជាប់គ្នា ដោយឥតមានស្រៈនៅចណ្ដាកណ្ដាល ។ ដើម្បីកុំឲ្យភាន់ច្រឡំ ខ្ញុំនាំឧទាហរណ៍មកអធិប្បាយដូចតទៅនេះ ។

ក ង រាប់ថាជាព្យញ្ជនៈផ្សំនឹងព្យញ្ជនៈ ពុំបានទេ ព្រោះមានស្រៈ អ នៅចណ្ដាកណ្ដាល ។ យើងមិនអាចមើលស្រៈ អ នោះឃើញ ដ្បិតក្នុងរបៀបអក្សរយើង ស្រៈ អ គ្មាន

រូប ៗ. បើសរសេរពាក្យ ក្ង ជាអក្សរបាំង (kâng) ទើប យើងកេចះមើលស្រៈ អ (ង) ចោះពេញ ៗ

ដើម្បីឱ្យសំគាល់ថា គ្មានស្រៈ អ ទេ ក្នុងវាងព្យញ្ជនៈពីរ អក្ខ យើងសរសេរព្យញ្ជនៈនោះមួយពីលើ មួយពីក្រោម ដូចមានពោលមកខ្លះហើយខាងដើមសៀវភៅនេះ ៗ ព្យញ្ជនៈខាងលើ យើងប្រើតួ, ព្យញ្ជនៈខាងក្រោមយើងប្រើជើង . ក្ង (kngâ) ៗ របៀបសរសេរយ៉ាងនេះឱ្យសំគាល់ថា តួ ក ដែលនៅពីលើនោះ គ្មានស្រៈ អ អាស្រ័យទេ, ឯជើង ង្ង ដែលនៅពីក្រោមទើបមានស្រៈ អ អាស្រ័យ ៗ

ព្យញ្ជនៈផ្សំនឹងព្យញ្ជនៈ ចែកបានជាពីរយ៉ាង៖ ហៅថា ព្យញ្ជនៈផ្សំជើង ១ យ៉ាង; ព្យញ្ជនៈតំរួត ១ យ៉ាង ៗ

ដើម្បីកប្បាប់សេចក្ដីរបស់ពាក្យខ្លះដែលត្រូវប្រើក្នុងវិធីនេះ ខ្ញុំសូមលើកពាក្យ ស្ពាន និង បណ្ដើរ មកជាឧទាហរណ៍ៗ ក្នុងការអានពាក្យ ស្ពាន យើងបញ្ចេញសំឡេងតែមួយដង ប៉ុន្តែត្រង់ពាក្យ បណ្ដើរ យើងបញ្ចេញសំឡេងពីរដង ៗ

លោកថាពាក្យ សាង មានព្យាង្គមួយ (une syllabe), ពាក្យ បណ្ដើរ មានព្យាង្គពីរ ។ ក្នុងព្យាង្គមួយរបស់ពាក្យ សាង នោះ ស ជាអក្សរប្រធាន, ា ជាស្រៈ, ង ជាខ្យល់ ។

### ៤ – ព្យញ្ជនៈផ្ញើជើង

ក្នុងព្យញ្ជនៈផ្ញើជើង ដូចជា ស្ល ស្លួ ស្លា – ព្យញ្ជនៈទី ១ ស គ្មានស្រៈអាស្រ័យ, ត្រូវបញ្ចេញសម្លេងតែកន្លះមាត្រា, ព្យញ្ជនៈទី ២ ល មានស្រៈអាស្រ័យគឺ អ អា អឺ, ត្រូវបញ្ចេញសម្លេងពេញមាត្រា ។

មួយទៀតព្យញ្ជនៈផ្ញើជើងទាំងពីរអក្សរ (ស និង ល) ជាអក្សរប្រធានក្នុងព្យាង្គ ។

សេចក្ដីសង្កេត– បណ្ដាព្យញ្ជនៈទាំង ៣៣ អក្សរ ព្យញ្ជនៈដែលកើតជាព្យញ្ជនៈទី ១ ក្នុងអក្សរផ្ញើជើងនោះគឺ ៖

ក ខ គ ឃ

ច ឆ ជ ឈ

ត ថ ទ ធ

ប ផ ព ភ ម ល ស,

ឬនឹងស្រដីមួយយ៉ាងទៀត គឺថា៖ ព្យញ្ជនៈវគ្គ ក វគ្គ ប វគ្គ ត លើកតែព្យញ្ជនៈចុងវគ្គចេញ; ព្យញ្ជនៈវគ្គ ប ទាំងអស់ ហើយព្យញ្ជនៈអវគ្គពីរអង្គ ល និង ស

ព្យញ្ជនៈដែលអាចជាព្យញ្ជនៈទី ២ ក្នុងអក្សរផ្ញើជើងគឺ៖

ក គ ង

ច ជ ញ

ដ — —

ត ថ ទ ន

ប ព ម យ រ ល វ ស ហ អ

ឬបើនឹងប្រដីមួយយ៉ាងទៀត គឺថា៖ សិថិលទាំងអស់ លើកតែ ឌ ចេញ, ព្យញ្ជនៈចុងវគ្គទាំងអស់លើកតែ ណ ចេញ, ព្យញ្ជនៈអវគ្គទាំងអស់ លើកតែ ឡ ចេញ, ហើយ

និងធនិត ១ អង្គ ប៊ ។ ធនិតឯទៀតៈក្រៅពី ប៊ (ស្ពាន) មិនអាចជាព្យញ្ជនៈទី ២ ក្នុងអក្សរផ្ញើដើមបានឡើយ ។

សេចក្ដីសង្កេតនេះ គ្រាន់តែជាសេចក្ដីគួរជឿនប៉ុណ្ណោះ មិនសូវមានសារៈសំខាន់ទេ ។

## ២– ព្យញ្ជនៈតំរួត

ព្យញ្ជនៈតំរួតមានសណ្ឋានប្រហែលគ្នានឹងព្យញ្ជនៈផ្ញើដើម ឧ. ក្ដ ក្នុង បក្ដៀង ។ ព្យញ្ជនៈទី ១ គ្មានស្រៈ អ អាស្រ័យដូចគ្នា; ប៉ុន្តែព្យញ្ជនៈតំរួតមានលក្ខណៈខុសពីព្យញ្ជនៈផ្ញើដើម ២ ប្រការ ។ ប្រការ ១ ព្យញ្ជនៈតំរួតមានតែក្នុងពាក្យពហុព្យាង្គ(១) ឯព្យញ្ជនៈផ្ញើដើម ច្រើនមានតែក្នុងពាក្យឯកព្យាង្គ ។ ប្រការ ២ ក្នុងព្យញ្ជនៈតំរួត (ន្ត ក្នុងពាក្យបន្ទាន់) ព្យញ្ជនៈទី ១ (ន) ជាខ្យល់ក្នុងព្យាង្គខាងមុខព្យញ្ជនៈតំរួត,

---

(១) ពហុប្រែថាច្រើន ។ ពាក្យពហុព្យាង្គគឺពាក្យដែលមានព្យាង្គច្រើន ចាប់ពី ២ ព្យាង្គឡើងទៅ (Mots polysyllabiques) ។

ព្យញ្ជនៈទី ២ (ឝ) ជាអង្គប្រធានក្នុងព្យាង្គខាងក្រោយព្យញ្ជនៈតំរួត, ឯព្យញ្ជនៈផ្ញើផើងជាអង្គប្រធានទាំងពីរអង្គ ។

តាមវិធីអាន យើងអាចចែកពាក្យដែលមានព្យញ្ជនៈតំរួតជាពីរចំពូក ។

– ចំពូកទី ១ សំរាប់

ក) ពាក្យដែលមានព្យញ្ជនៈតំរួតគ្នាជាមួយគ្នា ឧ. សណ្ដក វិជ្ជា ឧបសម្ប័ទ;

ខ) ពាក្យដែលមានព្យញ្ជនៈទី ១ ជាអាសកដៈ, ព្យញ្ជនៈទី ២ ជាព្យញ្ជនៈអវគ្គ ឧ. បង្ហាញ ពន្យល់ សង្ហារ ។

ក្នុងពាក្យចំពូកនេះ ព្យញ្ជនៈតំរួតទី ១ គ្មានបញ្ចេញសម្លេងទៅក្នុងព្យាង្គខាងក្រោយព្យញ្ជនៈតំរួតទេ ។ ពាក្យក្នុងឧទាហរណ៍ខាងលើនេះ ត្រូវអានដូចនេះ៖

សណ្ដក អានថា សន់-ដក

វិជ្ជា អានថា វិច-ជា

ឧបសម្ប័ទ អានថា ឧ - ប៉ះ - សំម - ប៉ាត់

ពន្យល់ អានថា ពន់ - យល់ ។

ពាក្យចំពូកនេះសរសេរទៅតាមរបៀបបាលី ។ ពាក្យខ្មែរសុទ្ធទាំងអស់ត្រូវសរសេរទៅតាមរបៀបនេះដែរ គឺតម្រួតអក្សរទៅតាមវគ្គ ។ ប្រយោជន៍មួយយ៉ាងធំរបស់របៀបនេះ គឺធ្វើមិនឲ្យប្រឡំជើង ត និងជើង ដ ព្រោះក្នុងអក្សរតម្រួតជើង ដ ត្រូវនៅក្រោមតួ ណ (បណ្ដឹង) ដែលវគ្គជាមួយគ្នា, ជើង ត ត្រូវនៅក្រោមតួ ន (បន្តឹង) ដែលវគ្គជាមួយគ្នា ។ ប៉ុន្តែរបៀបនេះក៏មិនជាទៀងទាត់ពេកទេ ÷ ជើង ដ អាចនៅក្រោមតួ ម (សម្ដេច) ដែលវគ្គផ្សេងគ្នាក៏បានដែរ ។ ក្រៅពីនោះ មានការរៀបចំសំរាប់ពាក្យបាលីសំស្ក្រឹតខ្លះ ដូចជាពាក្យ សន្ដាន ។ ពាក្យនេះលោកទុករូបដើមដោយនិរុត្តិសាស្ត្រជាហេតុ តែព្យញ្ជនៈតម្រួតទី ២ ត្រូវអានតាមសម្លេង ដ ។ សំរាប់វិធីអាន ត្រង់

ព្យញ្ជនៈដែលតម្រួតទី ១ ជានាសិកជៈ ទី ២ មិនមែនជាព្យញ្ជនៈវគ្គជាមួយ ។ មានការរៀបផ្ទុះ ត្រង់ ម និង ណ ជា ព្យញ្ជនៈទី ១ ដូចជាពាក្យ អម្ចាស់ អម្ចត់[1] វម្សៈ តណ្ហា... ដែលត្រូវអានដូចពាក្យចំពូកទី ២ ខាងក្រោមនេះ ។

ពាក្យចំពូកទី ១ ច្រើនជាពាក្យខ្មែរសុទ្ធនិងពាក្យដែលមកពីបាលី ។

– ចំពូក ទី ២ សំរាប់ពាក្យដែលខុសពីរបៀបសរសេរខាងលើនេះ ។ ពាក្យចំពូកនេះច្រើនមកពីសំស្រ្កឹត ។

---

១– ក្នុងពាក្យ អម្ចាស់ អម្ចត់ ព្យាង្គទី ១ រកកល់នឹងបាត់បង់ទៅហើយ ។ យើងប្រើតាមរូបទី២ជា ម្ចាស់, ជា ម្ចត់ (ក្នុងម្ចរម្ចត់) ពុំច្បាស់ក៏មាន ។ មានពាក្យខ្លះទៀតក្នុងទំនងនេះគឺ អម្ចប់, អម្ចុ, អម្ចេញ, អម្រាម,... សព្វថ្ងៃទៅជា ម្ចប់ ម្ចុ ម្ចេញ ម្រាម... ។ អម្ចប់ ឃើញមានក្នុងសាស្រ្តាខ្លះ, អម្ចុលែងប្រើមកជាយូរអង្វែងហើយ, ខ្ញុំមានប្រទះក្នុងសិលាចារិកមួយមុនសម័យអង្គរ (សិលាចារិកបំណោម K. 30 សតវត្សទី៧ ក្នុងអក្សរថ្មីនោះសរសេរ អំណោ) ។

ព្យញ្ជនៈទី ១ ជាខ្យល់គន្លងព្យាង្គខាងមុខព្យញ្ជនៈតម្រួត ហើយ
ត្រូវបញ្ចេញសម្លេងគន្លឹះមាត្រាគន្លងព្យាង្គខាងក្រោយព្យញ្ជនៈតំ-
រួតផង ៗ ឧ.

ភោគ្គា អានថា ភោក-គ្គា, បក្រើ អានថា បាក់-ក្រើ,
ឧត្បាទ អានថា ឧត់-ត្បាត, សត្យា អានថា សាត់-ត្យា
បុត្រា - បុត-ត្រា, វិទ្យា - វិត-ទ្យា
ដុប្ចេះ - ដុប - ប្ចេះ, ឫស្យា - រឹស-ស្យា។

ការៈវៀរចង់មានត្រង់ព្យញ្ជនៈតំរួត ៣ យ៉ាងគឺៈ

ត្រ្គ ឧ. ភក្ត្រា អានថា ភាក់-ត្រា
ក្ស ឧ. បក្សា " បាក់-សា
ប្ស ឧ. អប្សរ " អប់-សរ ។

## ឃ - វិធីអានពាក្យគ្រង់សម្លេងវែងខ្លី

វិធីអានពាក្យខ្មែរសុទ្ធ និងវិធីអានពាក្យដែលមកពីបាលី-
សំស្ក្រឹតមិនចំជាដូចគ្នាទេ ៗ ហេតុនេះយើងនឹងចែកវិធីអាន

ជាតិចំណែក ។

១– សំរាប់ពាក្យខ្មែរសុទ្ធ.– វិធីអានរបស់ខ្មែរត្រង់នេះសមហេតុសមផលល្អណាស់ ៖ យើងអានទៅតាមធម្មជាតិ មិនមែនទៅតាមសន្មត ។

ព្យញ្ជនៈប្រធាន ក ដាក់ស្រៈ អ ដល់ខ្យល់ ង ទៅជា កង ។ កាលបើចេះនូវ ក-ង ៗ ឲ្យញាប់ទៅក៏នឹងកើតទៅជា កង ដោយធម្មជាតិ មិនដូចជាក្នុងភាសាខ្លះ មានសៀម និងបារាំងជាដើម ។

សៀម ៖ ក ដល់ ង អានថា កុង;

បារាំង ៖ កា (Ka) ដល់ ង (Kan) អានថា កង់ ។

តាមវិធីអានរបស់យើង ក្នុងព្យាង្គនីមួយៗ បើស្រៈសម្លេងវែង ព្យាង្គនោះក៏សម្លេងវែង, បើស្រៈសម្លេងខ្លី ព្យាង្គក៏សម្លេងខ្លីទៅតាមផង ។

ឧ. ស្រៈខ័យៈ អ ៖ សុ, កង; –អា ៖ ត្រា, សាប;–

អ៊ីៈ លី, លីត្រ, — អ៊ីៈ គី, គីឡូៈ — អ៊ូៈ គ៊ូ, គ៊ូន,... ។

ដើម្បីនឹងកាត់សម្លេងខ្លី លោកប្រើស្រៈខ្លី ។ ឧ. យឺត ជាព្យាង្គវែងព្រោះ អ៊ឺ ជាស្រៈវែង, បើយើងចង់ធ្វើព្យាង្គនោះ ឲ្យទៅជាខ្លីលោកឲ្យយកស្រៈ អ៊ឹ ដែលជាស្រៈខ្លីត្រង់នឹងស្រៈ អ៊ឺ វែងនោះ មកប្រើវិញ ទៅជា យឹត;

គ៊ូន ជាព្យាង្គវែង ព្រោះ អ៊ូ ជាស្រៈវែង បើយើងចង់ ធ្វើព្យាង្គនោះឲ្យទៅជាខ្លី លោកឲ្យយកស្រៈ អ៊ុ ដែលជាស្រៈ ខ្លីត្រង់នឹងស្រៈ អ៊ូ វែងនោះ មកប្រើវិញ, ទៅជា គ៊ុន ។ល។ ការរៀបចំមានត្រង់ស្រៈ អ៊ូ ប្រកបនឹងខ្យល់ វ ។ ព្យាង្គបែប នេះត្រូវបញ្ចេញសម្លេងខ្លី ដូចមានពោលមកហើយក្នុងវិធីអាន ស្រៈ ឧ. ត្រូវ ស្រូវ នូវ ។ របៀបសរសេរតាមសម្លេង បូកណាបែបនេះ បន្តសេចក្តីលំបាកដោយឥតមានផល ប្រយោជន៍អ្វីឡើយ ។

កាលបើយើងមានស្រៈវែងដូច អូ និង អា ត់តស្រៈខ្លី

ឲ្យគ្រប់ទីងស្រៈវែងនោះ ដើម្បីធ្វើសម្លេងព្យាង្គដែលប្រើស្រៈ វែងណាមួយ ក្នុងពីរអក្ខរនេះឲ្យទៅជាខ្លី លោកឲ្យប្រើស្ស- សញ្ញា (ឬបន្តក់) ឧ. កង់ សាប់ ៗ ដូច្នេះ របស្សញ្ញាប្រើបាន តែក្នុងព្យាង្គណាដែលមានស្រៈ អ៊ូ ឬស្រៈ អ៊ា តែប៉ុណ្ណោះ(១) ៗ

---

(១)ក្នុងរបៀបអក្ខរាវិរុទ្ធតមកដល់ដើមសតវត្សទី ១៩ យើងគ្មានប្រើស្ស- សញ្ញាទេ ក្នុងសម័យនោះស្រៈ អ កាលប្រកបនឹងខ្យល់ លោកទុកជាស្រ្សៈដូចក្នុងភាសាខ្មែរ និងភាសាបាលី (អៈ) បញ្ចេញសម្លេងបានពីរយ៉ាង ៖

ជា អ ទីកំបាន ឧ. សង (= សង់), លក (= លក់) យល (= យល់);

ជា អា ទីកំណាន ឧ. សំរប (= សំរាប់), អញ (= អាញ់) អ្នក (= អាក់)

ហេតុនេះបានជាយើងជាប់សរសេរ អញ អ្នក មកដល់សព្វថ្ងៃ ។

ដើម្បីសរសេរព្យាង្គវែងដែលមានសម្លេង អ លោកប្រើស្រៈ អោ ជំនួសវិញ ឧ. ពោង (= ពង) យោក (= យក) មោក (= មក) ៗ

ធ្វើ...

ព្យាង្គដែលមានស្រៈ អ្យ ប្រកបនឹងខ្យល់ កាលបើខ្យល់នោះជាអក្ខរទី ១ របស់ព្យញ្ជនៈតំរួត សម្លេងព្យាង្គនោះជាសម្លេងទី ២ មិនចាំបាច់ប្រើសញ្ញាទេ ។ ឧ. កណ្ដាល (កន់-ដាល), បញ្ចាំ (បញ់-ចាំ), បង្ហាយ (បង់-ហ៊ាយ) ។

ចំពោះព្យាង្គទី ២ ដែលប្រើស្រៈ អា ប្រកបនឹងខ្យល់ ឯលោកប្រើនិគ្គហិតជួសសញ្ញាវិញ ឧ. រាំង តាំង ទាំង ។

ត្រង់ស្រៈ អ្យេ ស្រៈនេះជាទីឃៈ, កាលបើសម្លេងត្រឡប ត្រង់គ្នានឹងស្រៈរស្សៈ អ្យិ ។ ដូច្នេះបើនិយាយតាមហេតុតាមផលទៅ រូបអក្សរ អ្យេប មិនគួរមានទេ គួរប្រើរូប អិប វិញជាដាក ប៉ុន្តែយើងគង់មានប្រើរូប អេប់ ខ្លះដូចជា

---

ដូច្នេះបានជាយើងជាប់សរសេរ ហាន (= ហន) ដល់មកសព្វថ្ងៃនេះ។

ឯព្យាង្គដែលសរសេរដោយស្រៈ អា ប្រកបនឹងខ្យល់ ដូចកាលក៏សម្លេងទី ១. ស្ថាន មាន..., ដូចកាលក៏សម្លេងទី ២ ដោយគ្មានអ្វីដាក់សំគាល់ ឧ. គាន៊ (= ឃ្មាំន) ត្រកាន៊ (= ត្រគាំន) ។

ម្ដេប បេញ ដេញ ។ កាលបើស្រៈ អ៊េ សម្រូនត្រលា (អ៊ើ) នោះមិនមានស្រៈស្រេះអ្វីឲ្យត្រង់ទេ ។ ហេតុនេះ រូប អ៊ើញ ទើបមានប្រើដូចក្នុងពាក្យ ពេញ ធ្មេញ ធ្មេប ។ ប៉ុន្តែសំរាប់ពាក្យបែបក្នុងឧទាហរណ៍នេះ លោកមិនឲ្យដាក់សេស្រសញ្ញាជា ម្ដេប់ បេញ់ ដេញ់ ពេញ់ ធ្មេញ់ ធ្មេប់ ដូច្នេះទេ ។ ទើបជាការណ៍គួរឆ្ងល់ថា ហេតុម្ដេច ព្យាង្គវែងទាំងអម្បាលនេះ ត្រឡប់ទៅជាខ្លីវិញ ដោយឥតសញ្ញាអ្វីជាសំគាល់សោះ ។ ការរើសតាស់ដែលបង្កើតឡើងក្រៅអំពីថារបៀបសរសេរនេះ មិនសមហេតុសមផលឡើយ គឺជានាំឲ្យលំបាកខាងការអាននោះប្រការមួយ ព្រោះយើងនៅមានព្យាង្គឯទៀតដែលមានស្រៈដូចគ្នាដែរ តែត្រូវអានជាព្យាង្គវែង ឧ. ប្រេង បេក កំភេម ។ ត្រង់នេះយើងអាចដោះសាថាស្រៈ អ៊េ ដែលទៅជាសម្លេងខ្លីនោះ ចំពោះតែក្នុងព្យាង្គណាដែលមានព្យញ្ជនៈក្នុងវគ្គ ប ជាខ្យល់ ។ ប្រការ

៤ . បើទុកជាដោះសាបានដូច្នេះក៏ដោយ អក្សរខ្មែរ ក៏គង់នៅជាអក្សរដែលមិនអាចយកមកប្រើកត់សរៈបួនវែង អេប អេញ បានឡើយ ។ ការទើសទាស់ទាំងនេះ តាមសេចក្ដីសង្កេតពិចារណា ហាក់ដូចជាមកតែពីយើងមិនប្រើសរសញ្ញា ។ **នោះបើពិតដូច្នេះមែន** ការគូសសរសញ្ញាមិនសមជាការហត់នឿយ ដល់ជាឲ្យយើងរញ្ចួកទេ ។

មួយវិញទៀត មានពាក្យមួយចំពូកមានស្រៈ អេ ប្រកបនឹងខ្យល់ចេញសម្លេងខ្ទឹះសពីធម្មជាតិដែរ តែសម្លេងនោះមិនមែនជាស្រៈ អេ ខ្លីទេ ក្លាយទៅជាស្រៈ អា ខ្លីវិញ ។ ពាក្យចំពូកនោះមានតិចណាស់ល្មមចាំមាត់បានគឺ ស្រេប សម្រេច ស្ដេច សម្ដេច ផ្ដេច (១) ។

---

១) - តាមវចនានុក្រម ឃើញមានពាក្យចំពូកនេះតែ ៤ ម៉ាត់ប៉ុណ្ណោះ ។ ពាក្យ ស្ដេច សម្ដេច ផ្ដេច ជាពាក្យវង្សជាមួយគ្នា ។ បើពាក្យ ៣ ម៉ាត់នេះសរសេរខុសគ្នា ត្រូវតែពាក្យឯទៀតក្នុងវង្សនេះសរសេរតាមទំនងដូចគ្នាដែរ ។

ឬង...

ក្រៅពីនេះនៅមានស្រៈវែង អោ ១ទៀត ដែលផ្លាស់សម្លេងទៅជា អូ ក្នុងកាលប្រើប្រកបនឹងវិសជ្ជនីយ៍ដូចក្នុងពាក្យ ឈ្មោះ ទោះ កោះ (១)

## ២- សំរាប់ពាក្យដែលមកពីភាសាបាលីសំស្ក្រឹត

ស្រៈ ឬ ដែលជាស្រៈវែងក្នុងភាសាខ្មែរ កាលបើគ្មានប្រកបនឹងខ្យល់ទេ លោកអានតាមសម្លេងខ្លីជា អឺ: តែបើស្រៈ ឬ នោះជាស្រៈពេញតួក្តី ឬផ្សំនឹងព្យញ្ជនៈក្តី ។ ឧ. អវ្ទិគ្គ អាន អឺ:-រ៉ាក់; អកតញ្ញូ អាន អ:-ក:-តាញ់-ញូ

---

ពាក្យនោះគឺ ជាប់ បណ្តាច់ កុំប ។ ឯរបៀបសរសេរ ស្រេច សម្រេច ស្តេច នេះទើបមានឡើងនៅសម័យលង្វែកភាគចុងនៃសតវត្សទី ១៦ ។ កាលមុនសម័យនេះ លោកសរសេរ ស្រាចិ សំរចិ ស្តចិ ស្តាចិ ។

១)- ក្នុងសម័យអង្គរ ឈ្មោះ ឃើញសរសេរ ផ្នះ ។

សរសេរអាន ស់ៈ គ់ៈ-វាគ់ ។

កាលបើស្រៈ អ្ន មានប្រកបនឹងខ្យល់ ដូចក្នុងពាក្យ ពល កុសល យស ស្រៈ អ ក៏ត្រូវអានតាមសម្លេងខ្វីដែរ តែលោកមិនឲ្យដាក់រស្សសញ្ញា ៈ ពល់ កុសល់ យស់ ទេ ។

វិធីសរសេរបែបនេះនាំឲ្យលំបាកចាំ ដើម្បីសរសេរនិងអានកុំឲ្យខុស ។ សេចក្ដីលំបាកនេះគ្មាននាំមកនូវផលប្រយោជន៍អ្វីជាដុំឲ្យល្មមសមគួរឡើយ ។ បើយើងដាក់រស្សសញ្ញាទៅ ក៏មិនអាចនាំឲ្យវង្វេងក្នុងការស្រាវជ្រាវរកដើមកំណើតរបស់ពាក្យបានទេ ។

យើងបានឃើញមកហើយក្នុងវិធីអានពាក្យខ្មែរសុទ្ធ ថាព្យាង្គដែលមានស្រៈទីឃៈ អ្ន ប្រកបនឹងខ្យល់គំរូត ត្រូវអានជាសម្លេង អ្ន រស្សៈ ។ ពាក្យបាលីសំស្ក្រឹតដែលមានលក្ខណៈដូច្នេះ យើងអានតាមវិធីនេះក៏បាន ឧ. សម្បូណ៌ (សម់...) និវត្ត (... វត់ ...) អានន្ទ (...ណាន់)...។

តែយើងច្រើនអានតាមវិធីបាឡីសំស្ក្រឹត គឺជាសំឡេង អា ខ្វិញ ឧ. សម្បទា (សាម់. . .), ក្សត្រ (ក្សាត់), វត្ត (វាត់) ។ ពាក្យចំពូកនេះលោកឲ្យអានទៅតាមសេចក្ដីចាំ គ្មានអ្នកជាសំគាល់ទេ ។

ក្នុងពាក្យខ្វះ ហាក់ដូចជាលោកអាណិតអ្នកអានអ្នកសរសេរខ្វះលោកដាក់សំយោគសញ្ញាជាសំគាល់ឲ្យផង ដូចមានពោលមកខ្វះហើយក្នុងមាតិកាសរុបសញ្ញា ឧ. ប្រយ័ត្ន ព្រ័ត្ត រ័ត្ន ។

សំរាប់អ្នកអាន កាលបើប្រទះពាក្យចំពូកនេះដូចជា បក្រ គេនឹងគិតក្នុងចិត្តថាត្រូវអាន ប៉ក់ ឬ ហាក់ ។ សំរាប់អ្នកសរសេរ កាលបើចង់សរសេរពាក្យ បក្ន គេនឹងគិតថាត្រូវដាក់សំយោគសញ្ញាជា ប័ក្ន ឬមិនត្រូវដាក់ទេ ។ នោះបើលោកបើកអនុញ្ញាតឲ្យដាក់សំយោគសញ្ញាទៅគ្រប់ពាក្យដែលស្រៈ អ ចេញសំឡេងជា អា ខ្វី នោះប្រាកដជានឹងបាន

ទទួលពរសព្ទសាធុការពីជនជាតិខ្មែរទាំងឡាយ ដែលមិនចង់សរសេរពាក្យរបស់ជាតិខ្លួន ឱ្យខុសពីបែបក្បួនវចនានុក្រមនោះជាមិនខាន ។ កាលបើលោកសរសេរ ប្រយ័ត្ន ព្រ័ត្ត... មានសំយោគសញ្ញាដូច្នេះបាន តាមស្មានទៅប្រហែលជាមិនមានគាស់ទើសក្បួនអ្វីទាំងណាស់ទេ បើសរសេរ វ័គ្គ វ័ត្ត ក្ស័ត្រ ដាក់សំយោគសញ្ញាផងដូច្នេះ ។

វិសជ្ជនីយ៍– វិសជ្ជនីយ៍ញុំាងសម្លេងវែងឲ្យទៅជាខ្លី ។ វិសជ្ជនីយ៍បញ្ចេញសម្លេងស្រដៀងនឹងខ្យល់ ស តែមិនចេញចុងសម្លេងច្បាស់ជា ស ទេ ។ ប៉ុន្តែតាមសម្លេងនិយាយធម្មតា វិសជ្ជនីយ៍នឹងខ្យល់ ស សម្លេងដូចគ្នា នាំឲ្យអ្នកសរសេរភាន់ច្រឡំជាញយ ៗ សេចក្តីពិតវិសជ្ជនីយ៍បញ្ចេញសម្លេងដូចខ្យល់ ស ក្លាយជា ហ បានជាជនជាតិអឺរ៉ុបសន្មតយកអក្សរ h (= ហ) ប្រើជំនួស មានចុចពីក្រោមមួយផង (ḥ) ដើម្បីកុំឲ្យច្រឡំនឹង h ធម្មតា ។

សំរាប់ស្រៈ អិ (ជិះ), អុ (ប៊ុះ), អឹ (ផ្កឹះ), អេ (បេះ), អៃ (កៃះ), វិសជ្ជនីយ៍គ្រាន់តែធ្វើសម្លេងឲ្យខ្លីមកដោយបញ្ចេញខ្យល់ ស ក្លាយជា ហ តែប៉ុណ្ណោះ ។ ប៉ុន្តែសំរាប់ស្រៈ អុ និង អោ វិសជ្ជនីយ៍ញុំាងសម្លេងស្រៈដោយចំឲ្យប្រែទៅទៀត ៖

អ > អា ខ្វី ឧ. វះ អាន វាស់ (កុំច្រឡំថា វ័ស)

អោ > អ ខ្វី ឧ. ទោះ អាន ទស់ ។

វិធីអានពាក្យត្រង់សម្លេងគ្រលួច ឬ គ្រលរ

វិធីអានត្រង់នេះ គឺត្រូវចែកជាពីរយ៉ាង សំរាប់ពាក្យខ្មែរសុទ្ធ និងសំរាប់ពាក្យដែលមកពីបាលីសំស្ក្រឹត ។ យើងបានឃើញរួចមកហើយថាសម្លេងព្យាង្គដែលទៅជាគ្រលួច ឬ គ្រលរ ស្រេចតែលើព្យញ្ជនៈប្រធានរបស់ព្យាង្គនោះ ។ ប៉ុន្តែមានព្យញ្ជនៈ ១១ អង្គ គឺ ៖

ព្យញ្ជនៈចុងវគ្គ ៥ អង្គ ៖ ង ញ ណ ន ម

ព្យញ្ជនៈអវគ្គ ៥ អង្គៈ យ រ ល វ ហ ហើយនិង ប, ដែលអាចប្រែប្រួលសម្លេងគ្រលរ ង ញ ន ម យ រ ល វ ជាគ្រលួច ង៉ ញ៉ ណ ម៉ យ៉ រ៉ ឡ វ៉, ចុះសម្លេងគ្រលួច ណ ហ ជាសម្លេងគ្រលរ ន ហ៊ ដោយគតអាស្រ័យវណ្ណយុត្តិ, គឺប្រែទៅតាមទីតាំងរបស់ខ្លួនក្នុងពាក្យនិមួយៗ(១) ។ ឯ ប អាចប្រែសម្លេង ប៊ ដោយគត់អាស្រ័យវណ្ណយុត្តិដែរ ។

១- សំរាប់ពាក្យខ្មែរសុទ្ធ.- ក្នុងពាក្យខ្មែរសុទ្ធ ប មិនមានប្រែសម្លេងជា ប៊(២) ដោយគតអាស្រ័យវណ្ណយុត្តិទេ, ណ ក៏មិនមានប្រែសម្លេងជា ន ។

ព្យញ្ជនៈ៩ អង្គក្រៅពីនោះ អាចប្រែសម្លេងតាមក្បួនតទៅនេះ

ក្បួនទី ១- ព្យញ្ជនៈសម្លេងគ្រលរ ៥ អង្គ ង ញ ន

(១) valeur de position

(២) វៀរលែងតែក្នុងអក្សរធ្វើដើង ឧ. ប៊ូស្ទ ប៊ីន ប្រាប់ ។

ម យ រ ល វ កាលបើជាអក្ខរប្រធានក្នុងព្យាង្គ ត្រូវប្រែសម្លេងទៅជាគ្រលួច ឯកាលព្យញ្ជនៈដែលជាប្រធានក្នុងព្យាង្គជាមួយ ឬក្នុងព្យាង្គខាងមុខរបស់ពាក្យជាមួយៈនោះមានសម្លេងគ្រលួច ។

ព្យាង្គជាមួយ៖ បានដល់ព្យញ្ជនៈផ្ញើជើង ឧ. ផ្សារ ខ្ញុំ ស្នាម ប្ដី ខ្យល់ ... ។

ព្យាង្គខាងមុខរបស់ពាក្យជាមួយ៖ បានដល់អក្សរត្រួត សម្ងាត់ កំរាល បង្វិល ... ។

ក្បួនទី ២– ព្យញ្ជនៈសម្លេងគ្រលួច ណ និង ហ កាលបើជាអក្ខរប្រធានក្នុងព្យាង្គ ត្រូវប្រែសម្លេងទៅជាគ្រលរ ន ហ៊ ឯកាលព្យញ្ជនៈជាប្រធានក្នុងព្យាង្គខាងមុខរបស់ពាក្យជាមួយនោះមានសម្លេងគ្រលរ ។

សំគាល់ (១) ក្នុងករណីចំពូកនេះ គ្មានប្រើក្នុងពាក្យខ្មែរសុទ្ធទេ, យើងទុកអធិប្បាយក្នុងពាក្យដែលមកពីបាលីសំ-

...

១

ស្រ្កឹត ៗ ឯគ្រន់ ប្រា មានឧទាហរណ៍ដូចតទៅនេះ៖ ដំបារ ព្រហាម ទាហាន ត្រូវអានដូចមានគ្រ.ប័ត្តលើ ហ ៗ

ក្បួនទាំងពីរនេះមិនមានការវៀរបង់ទេ សំរាប់ពាក្យខ្មែរសុទ្ធ ៗ

សេចក្ដីសង្កេត— អក្សរ អ្ន លោកដាក់រៀងក្នុងក្រុម ១ ៗ បើនឹងស្រដីមួយយ៉ាងទៀត គឺថាៈលោកដាក់ អ្ន ក្នុងពពួកព្យញ្ជនៈ, ប្រែសេចក្ដីថាលោកទុក អ្ន ជាព្យញ្ជនៈ ៗ សេចក្ដីពិតក្នុងពាក្យ អ្នី អ្ន មានលក្ខណៈជាព្យញ្ជនៈពេញបី ត្រូវតាមក្បួនទី ១ ដូចព្យញ្ជនៈសម្រេងត្រលួចឯទៀត ៗ

ហេតុនេះពាក្យពហុព្យាង្គ ដែលមានព្យាង្គមួយជាស្រះពេញតួ គួរលុះទៅតាមក្បួនទី ១ ទាំងអស់ ៗ ឧ. តិរាន់[១]

(១) ក្នុងវចនានុក្រម លោកសរសេរ តវ៉ាន់ ៗ

ឥល្សូវ(១) ឯនេះ ឯនោះ ឯលិច(២) អង្វរ អង្វែង អម្ពុរ អម្ពាប ឱម៉ាល់(៣) ។

ប៉ុន្តែមានការវៀរបង់ត្រង់ពាក្យចំពូកនេះ ដែលមានព្យញ្ជនៈតំរួត នាគាលព្យញ្ជនៈទី ២ នៃព្យញ្ជនៈតំរួតនោះជា រ ឬ ល (les liquides) ។ ឧ. អង្រឹង អង្រុត អង្រែ អន្លក់ អន្លង់ អន្លើ ។

## ២– សម្រាប់ពាក្យមកពីបាលីសំស្រ្កឹត

ពាក្យចំពូកនេះកាន់ទៅដោយចំណាំ ជួនកាលក៏តាមក្បួនខាងលើនេះ ជួនកាលក៏កាន់ទៅតាមវិធីបាលីសំស្រ្កឹត

---

(១) ក្នុងវចនានុក្រម លោកចូលចិត្តសរសេរជា ឥឡូវ ផង ។

(២) ឯនេះ ជាពាក្យមួយម៉ាត់, ឯនោះ ជាពាក្យមួយម៉ាត់ ដូចជាពាក្យខាងលិច ici, dehors, plutôt មិនមែនជាពាក្យពីរទេ ។

(៣) បើតាមក្បួនទី ១ ឱម៉ាល់ មិនត្រូវដាក់មូសិកទន្តទេ តែក្នុងវចនានុក្រម លោកដាក់មូសិកទន្ត ។

រកអ្វីជាសំគាល់ពុំបានឡើយ ។

ពាក្យដែលអានតាមវិធីខ្មែរនោះ ច្រើនតែជាពាក្យសំស្ក្រឹតដែលយើងខ្ចីមកប្រើជាយូរអង្វែងហើយ ។ ឧ.

ក) តាមក្បួនអានព្យញ្ជនៈផ្សំនឹងស្រៈ៖ ញាតិ នគរ មាតា យាគូ រាត្រី លាមក វាចា... ។ សំរាប់ពាក្យឯកព្យាង្គ ឬព្យាង្គដើមរបស់ពាក្យពហុព្យាង្គដែលមានព្យញ្ជនៈជាប្រធាន វិធីអានទៅតាមវិធីខ្មែរទាំងអស់ វៀរតែពាក្យខ្លះដោយចំនួនតិចដូចជា វច្ឆកាល (វ៉ាច់.. ), មច្ឆា(ម៉ាច់...), លេខ (ឡេក) ។ ក្រៅពីនោះ មិនថាព្យញ្ជនៈណាជាប្រធានទេ–លើកតែ ឫ ចេញ, ព្យញ្ជនៈ ឫ នឹងអធិប្បាយនៅខាងក្រោយ–សឹងអានទៅតាមវិធីខ្មែរ ឧ. កុមារ បិត្ត តុលាការ ភាសា ។

ខ) តាមក្បួនទី ១ ខាងលើនេះ៖ បរលោក(...ឡោក), ប្រយោជន៍ (...យោច), អាយុស (...យ៉ូស)... ។

គ) តាមក្បួនទី ២ ពាក្យបែបនេះ មណី (...នី), មាណព (...នព), មរណា (...នា), វិហារ (...ហារ), គុហា (...ហា), លេហា (...ហា) ។

ពាក្យបាលីសំស្ក្រឹតជាច្រើនតែងតែកាន់ទៅតាមវិធីរបស់ភាសាកំណត់នោះ ។ ឧ.

ក)- ប្រយោគ អាយុ ហនុមាន កតញ្ញូ បារមី អរូប ប្រមុខ វិទ្យាល័យ... ។

ខ)- ជីវា ជិវ្ហា អាហារ សគុណា... ។

កាលព្យាង្គដើមជាស្រៈពេញតួ ស្រៈនោះដូចកាលកាន់ទៅតាមវិធីខ្មែរ ឧ. ឧក្រិដ្ឋ, ឧត្បល[1] ឧបជ្ឈា[1] ពិត ពិរោះ...; ដូចកាលកាន់ទៅតាមវិធីបាលីសំស្ក្រឹត ឧ.

---

(១) ក្នុងវចនានុក្រម [illegible] តាមបាលីថា ឥ, ប៉ុន្តែតាមទំលាប់ [illegible] មកដូចជាសព្វថ្ងៃ ឥ ។

ពិជ្ជា (អ៊ិ...), តិជះលោក (អ៊ិ...), ឧប្បារៈ (អ៊ុ...), ឧតុ (អ៊ុ...), ។

សំកបញ្ចាន់: ប ដូចកាលអានតាមវិធីខ្មែរជា ប ឧ. បរម បាទ បិតា បុត្រ; ដូចកាលក៏អានតាមវិធីបាលី-សំស្រ្កឹតជា ប៉ ឧ. បប៉រម ប៉ាប៉ទ ប៉ិតា ប៉ុត្រ។

សេចក្តីសង្កេត.— តាមដែលយើងបានឃើញមកនេះ វិធីអានពាក្យដែលបកពីបាលីសំស្រ្កឹត រកអ្វីជាបំគាល់ឲ្យទៀងទាត់ពុំបានឡើយ នាំឲ្យលំបាកអានជាច្រើន ដោយចំពោះសំកប់ផនជាតិក្រោមឱវាទកូនដែលរៀនអក្សរខ្មែរ ។ ដើម្បីនឹងឲ្យស្រួលបាននោះ មានតែវិធីមួយ គឺរើសណាយកគ្រប់ពាក្យណាដែលមិនលុះទៅតាមក្បួនអាន ។

## ៣– វិធីអានពាក្យបកពីបាលីសំស្រ្កឹតខ្លះ ដែលមិនធាប់អធិប្បាយ

១– អក្សរបុងពាក្យ.— អក្សរបុងពាក្យ នោះបិតា

ព្យញ្ជនៈគោលក្តី រូតក្តី លោកទុកជាខ្យល់ មិនបញ្ចេញសូរសម្លេងពេញមាត្រា ដូចក្នុងភាសាបាលីសំស្រ្កឹតដោយចំទេ ឧ. ពល សេស ចិត្ត វត្ត;

កាលបើត្រូវបញ្ចេញសម្លេងពេញមាត្រា លោកដាក់យុគលពិន្ទុជាសំគាល់ ឧ. វីរិយៈ សាធារណៈ សាក្យៈ;

កាលបើជាព្យញ្ជនៈគោល ហើយមិនត្រូវបញ្ចេញសម្លេងសោះនោះលោកដាក់ទណ្ឌឃាតជាសំគាល់ ឧ. ប្រយោជន៍ សាសន៍ លក្ខណ៍ ។

កាលស្រៈ ិ នៅចុងពាក្យ លោកច្រើនតែលមិនអានៗ ឧ. ឫទ្ធិ សម្បត្តិ សក្តិ;

តែជួនកាល អានក៏បានមិនអានក៏បាន ឧ. សិទ្ធិ (ថា សិត ក៏បាន ថា សិត-ធិ ក៏បាន);

ជួនកាលត្រូវតែអាន ឧ. លទ្ធិ វឌ្ឍិ អដ្ឋិ ។

តែនេះបើប្រើទណ្ឌឃាត ឃើញថាលំបាកសរសេរ

បន្តិច ប៉ុន្តែរួបជាស្រួលការអាន ។

២.- ពាក្យសមាស (អាន ស..ម៉ាស់).- តាមវិធីការដែលយើងទើបនឹងពិពណ៌នារួចមកនេះ អក្សរចុងពាក្យត្រូវបញ្ចេញសម្លេងតែកន្លះមាត្រា ដូចជា ពល បុរាណ កម្ម ឬមិនត្រូវបញ្ចេញសម្លេងសោះ ដូចជា ឫទ្ធិ ប្រវត្តិ ។

កាលបើមានពាក្យណាលំ ប្រស្រគមួយបវះទៀតមកដាក់បន្ទាប់ពីក្រោយ រួមជាពាក្យតែមួយម៉ាត់ ពាក្យដែលបង្កើតឡើងដូច្នេះ លោកហៅថាពាក្យសមាស ។ ឧ. ពលកាយ បុរាណសម័យ កម្មសិទ្ធិ ឫទ្ធិវន្ត ប្រវត្តិសាស្ត្រ ។

ក្នុងពាក្យសមាសដែលនាំយកមកជាឧទាហរណ៍នេះ អក្សរ ល ក្នុង ពល, ណ ក្នុង បុរាណ, ម ក្នុង កម្ម, ធិ ក្នុង ឫទ្ធិ, តិ ក្នុង ប្រវត្តិ លែងជាអក្សរចុងពាក្យហើយ ។ ហេតុនេះអក្សរទាំងនោះត្រូវបញ្ចេញសម្លេងពេញមាត្រា៖ ត្រូវអានថា ពល់-លៈ-កាយ ..., ក័ម្មៈ-សិត ...

ប្រ-វាត់-តិ-សាស់ ដោយមិនចាំបាច់ដាក់យុគលពិន្ទុ ។

ពាក្យដែលមានយុគលពិន្ទុសម្រាប់កាលនៅពេល ដូច វីរិយៈ សាធារណៈ សាក្យៈ នោះបើចូលជាបទសមាស ត្រូវលុបយុគលពិន្ទុចោល ហើយអានសម្រួលដែល ឲ វីរិយភាព សាធារណការ សាក្យវង្ស ។

មានការវៀរបន្តិច ដូចជាពាក្យ សក្តិសិទ្ធ សក្តិ-យស, យសសក្តិ . . . ដែលត្រូវអានថា សាក់-សិត, សាក់-យស់, យស់-សាក់ ។

ពាក្យសមាសដែលមិនត្រូវទៅតាមក្បួនទាំងនេះ កើតឡើងដោយខ្មែរយើងយកពាក្យបាលីសំស្ក្រឹតមកបញ្ចូលគ្នាខ្លួនឯង មិនមែនមានសម្រាប់ក្នុងភាសាដើមទាំងពីរនោះមកទេ ។ បើពិនិត្យដោយល្អិតទៅ ពាក្យ សក្តិយស យសសក្តិ សមជាពាក្យគូជាងជាពាក្យសមាស បែប ទឹកកក ផ្ទះសំបែង។ ឯពាក្យដូចជា សមសក្តិ ជាពាក្យសំស្ក្រឹតមែន តែជាពាក្យ

ពីរម៉ាត់ផ្សេងគ្នា មិនមែនជាពាក្យសមាស ។ ដូច្នេះត្រូវអានថា សម់-សាក់, មិនត្រូវអានថា សមៈ-សាក់ ទេ ។

៣– វិធីអាននិគ្គហិត.– ក្នុងភាសាបាលី និគ្គហិតបញ្ចេញសម្លេង ង ។ ក្នុងភាសាសំស្ក្រឹតលោកហៅថាអនុស្វារៈ បញ្ចេញសម្លេង ម ។ ក្នុងភាសាសំស្ក្រឹតនេះ មានដំណើមួយយ៉ាងទៀតហៅថា អនុនាសិកជៈ បញ្ចេញសម្លេងជា ង ។

អំ– ក្នុងពាក្យខ្មែរសុទ្ធ អានថា អម់ ឧ. សំយុង អំពល់ ទំ;

ក្នុងពាក្យមកពីបាលីសំស្ក្រឹត អានតាមបាលីថា អាង ក៏មាន ឧ. បំសុកូល សំខ្យា សំយោគ[1];

---

១)– គម្ពីរនេះ លោកលែងសរសេរ បំសុកូល ហើយ. លោកសរសេរ បង្សុក្កូល វិញ; ឯ សំខ្យា លោកបត្ដូរបន្ថយឲ្យសរសេរ សង្ខ្យា ជាដ ។ ហេតុនេះជាការគួរសង្ឃឹមថាទៅថ្ងៃក្រោយ លោកគង់មានសេចក្ដីករុណាបើកឲ្យសរសេរ សង្ខ្យាត ជាដដង ព្រមទាំងពាក្យចំពូកនេះទាំងអស់ ។

អានថា អ៊ំ ក៏មាន ឧ. សំគេត សំភាស សំយ[១];

អានតាមសំស្រ្កឹតថា អម៉ ដូចវិធីខ្មែរក៏មានខ្លះ ឧ. សំរិទ្ធិ ។

អាំ– អានបានតែមួយយ៉ាងថា អាម់ កាលគ្មានខ្យល់ ឧ. ចាំ ចាំ បណ្តាំ;

កាលបើប្រកបនឹងខ្យល់ ង ឯ អានថា អ៉ាង ឧ. ទាំង បាំង រាំង[២] ។

អឹ– ក្នុងពាក្យខ្មែរសុទ្ធ ជាសម្លេងខ្លីដែលត្រង់គ្នានឹងសម្លេងវែង អឺ ឧ. ទឹក សន្ទឹក សន្ទឹង;

ក្នុងពាក្យបាលីសំស្រ្កឹត ប្រើបានពីរយ៉ាង ៖

ក) បញ្ចូលនឹង ឫ ជា ឫ សំរាប់ប្រើជួស ឬ ឧ. ក្រឹត្យ

១)– លោកបើកឲ្យសរសេរ សង្គេត សង្ភាស សង្យ បាន ។

២)– ប្រើចិត្តហិតពីសរសេរសញ្ញាផ្ទះភ្ជាប់សបហេតុសមផលសោះ ៖

ចាំង = ចាំ + ង = ចាម់ + ង ។

ព្រឹក្សា សំស្ក្រឹត:

១) ចំពោះពាក្យខ្លះដូច តារត្តិសា (១) មហឹសា ការ

ថា អ៊ឹង តាមបាឡី ។

អំ - ក្នុងពាក្យខ្មែរយើងអានថា អុម ឧ. សុំ ខុំ កុំ; ក្នុង

ពាក្យដែលមកពីបាលីសំស្រ្កឹតអានថា អុង ឧ. បុំលិង្គ។

## ផ្នែកទី ៣

## ច្បាប់សូរសាស្ត្រ៖

ច្បាប់សូរសាស្ត្រមិនមែនអ្វីក្រៅពីទំនួលសំឡេងរបស់ពាក្យ ដែលប្រែប្រួលបន្តិចម្តងៗរៀងរាល់ពីបុរាណកាលដរាបមក ។ សំឡេងរបស់ពាក្យដែលប្រែល្អៀងពីបែបដើម ក៏ដើម្បីឲ្យស្រួលហៅស្រួលនិយាយ ។ ការប្រែប្រួលដែលបានមកហើយ បានធ្វើទៅឯង គ្មាននរណាតាំងច្បាប់ឲ្យធ្វើតាមទេ ។ ប៉ុន្តែ

---

(១) តារត្តិសា លោកលែងសរសេរបែបនេះហើយ លោកសរសេរ តារត្តិស្យា វិញ ។

បើយើងមើលដំណើររបស់ការប្រែប្រួលនោះ ដោយពិនិត្យពិចារណាយើងអាចឃើញគន្លងដែលធ្លាប់ដើរមកហើយ ៗ គន្លង ឬច្បាប់ទាំងនេះហើយដែលលោកហៅថា សូរសាស្ត្រ (lois phonétiques) ។ គន្លងនេះមានសារៈសំខាន់ ក្នុងការបង្កើតពាក្យថ្មីសំរាប់ប្រើក្នុងភាសាយើង ។ គន្លងនៃការប្រែប្រួលមានច្រើនយ៉ាងដូចមានអធិប្បាយខាងក្រោមនេះ ។

## ក- កែសំឡេងព្យញ្ជនៈ រឹងជាទន់

ពាក្យសំស្ក្រឹតនិងពាក្យបាឡី ដែលយើងខ្ចីមកប្រើជាពាក្យខ្មែរច្រើនប្រែសំឡេងរឹង ត ប៉ ជាសំឡេងទន់ ដ ប ។.

១) ត ជា ដ ៖ បិតា មាតា បតុម្ម ...;

២) ប៉ ជា ប ៖ បរិយាយ បរិ បាប ... ។

ការប្រែប្រួលនេះ មកពីវិធីសរសេរ ព្រោះពីបុរាណព្យញ្ជនៈវគ្គ ប៉ លោកមិនប្រើសំរាប់ពាក្យខ្មែរ លោកទុកប្រើតែក្នុងពាក្យបាឡីសំស្ក្រឹតណាដែលមានប្រើអក្សរក្នុងវគ្គនេះស្រាប់

បកហើយ ៗ ក្ត **ក្នុង**សម័យបុរាណអាចអានបានពីរយ៉ាង ជា ក្តិ ក៏បាន ផា ជិ ក៏បាន ដូចមាន**ពោលមក**ហើយក្នុងហតិកា សម្លេងព្យញ្ជនៈ ៗ ហេតុដូច្នេះទើបពាក្យបាលីសំស្ក្រឹត ដែលមកជាពាក្យខ្មែរស៊ប់យូរយារមកហើយនោះ ប្រែសម្លេង ក្តិ ជា ជិ សឹងតែគ្មានសល់ តែរូបអក្សរលោកទុកឲ្យគង់នៅ ដដែល ៗ ឯ ឫ ក្នុងសម័យបុរាណអាចអានជា រឺ ក៏បាន ជា ឫ ក៏បានស្រេចតែករណី គ្មានអ្វីជាគ្រឿងសំគាល់ទេ ព្រោះ កាលនោះ វណ្ណយុត្តិមូសិកទន្តមិនទាន់មាន ៗ ក្នុងភាសា បាលីសំស្ក្រឹតសម្លេង ឫ គ្មាន, មានតែសម្លេង រឺ ៗ សម្លេង រឺ ខ្មែរយើងមិនសូវចូលចិត្តបាទៅផ្សិតខុសនិស្ស័យរបស់ភាសា យើង ៗ សបអក្សរ ឫ អានបាន ២ យ៉ាង យើងក៏អានជា ឫ អស់ទៅ ៗ ដែលនៅអានជា រឺ ខ្លះដូចក្នុងពាក្យ បរិ-មណ្ឌល បុំលិង្គ បស្សាវៈ ក៏សំកប់តែពាក្យដែលទើបខ្ចីពី បាលីសំស្ក្រឹតមកជាន់ក្រោយ ៗ

## ១– កែសម្លេងព្យញ្ជនៈតឹងជាធូរ

*គឺប្រែសិថិលជាធនិត* (aspiration) *។ ការប្រែប្រួលនេះច្រើនមានតែក្នុងពាក្យខ្មែរសុទ្ធ ។*

ក > ខ ឧ. ក្ញុំ > ខ្ញុំ; ក្មេង, ក្ជយ, ក្មេក (*សម្លេងជា* ខ្មេង, ខ្ជយ, ខ្មេក, *តែបែបសរសេរនៅដដែល*);

គ > ឃ ឧ. គ្មុំ > ឃ្មុំ, គ្លាំង > ឃ្លាំង; គ្មាន (*សម្លេងទៅជា* ឃ្មាន *តែរូបអក្សរនៅដដែល*);

ប > ផ ឧ. ប្អែក > ផ្អែក; ដូប្អេះ, ដូប្អោះ (*សម្លេងទៅជា* ដូប-ផ្អេះ, ដូប-ផ្អោះ *តែរូបអក្សរនៅដដែល*);

ជ > ឈ ឧ. ជ្មោះ > ឈ្មោះ, ជ្រួល > ឈ្រួល, ជ្មោល > ឈ្មោល;

ត > ថ ឧ. ត្មី > ថ្មី; ត្មោ > ថ្មុ; ត្នោត, ត្មាត, អាត្មា... (*សម្លេងទៅជា* ថ្នោត, ថ្មាត, អាត-ថ្មា, *តែ*

អក្សរនៅគង់រូបដដែល)

ត > ធ ឧ. ត្រូ > ប្រូ > ធ្រើ;

ទ > ធ ឧ. ទ្វារ (សម្រួលជា ធ្វារ);

ប > ផ ឧ. ប្លែ > ផ្លែ, ប្សុំ > ផ្សុំ, បទុះ > ផ្ទុះ;

សេចក្តីសង្កេត– ពាក្យសរសេរ ក្មេង ក្មួយ ក្មេក គ្មាន ប្អូន ប្អេះ ត្មោត ត្មាត ទ្វារ ... នេះ យើងមិនត្រូវនឿងឆ្ងល់ទេ ព្រោះភាសាសរសេរមែនដើរយឺតជាងភាសានិយាយ ។ ការណ៍ដែលគួរឆ្ងល់នោះគឺថាក្នុងករណីខ្លះ ភាសាសរសេរហាក់ជាដើរលឿនជាងភាសានិយាយទៅវិញដូចក្នុងករណីនៃពាក្យ ផ្តល់ ផ្តើម ផ្តាំ និងពាក្យឯទៀតដែលមានព្យញ្ជនៈដើមជើង ត ។ ក្នុងភាសានិយាយ ឬ មិនទាន់ប្រែទៅជា ផ្ត ទេ ។ សម្ដីនិយាយនៅតែជា ប្តល់ ប្តើម ប្តាំ ឬ ប្តូល ប្តុំ ។ល។ តាមរំលូលសម្ដីខ្លះដូចជា ឬ មិនអាចប្រែទៅ ផ្ត បានឡើយ ។

## គ- កែសម្លេងស្រៈ

អៈ > អ ឧ. បរម (ប:រ:ម:) > បរម (ប-រ៉ុម),

បរិសុទ្ធ (ប៉ៈ រិ...) > បរិសុទ្ធ (ប-រិ...),

បវរ (ប:វ:រ:) > បវរ (ប-វ៉រ);

អៈ > អា ឧ. បុប្ផ > បុប្ផា, វក្ស > ព្រឹក្សា, មជ្ជ > មជ្ជា[1]

អៈ > អិ > អឹ ឧ. ក្សណ > ក្សិណ, ឧទក > ទិក > ទឹក,

វជ្រ > ពេជ្រ;

អៈ > អូ ឧ. បទុម > បូទុម, បពិត្រ > បូពិត្រ, សកល >

សូកល[2]

---

(១) រូបរបស់ពាក្យ បុប្ផា ព្រឹក្សា មជ្ជា ត្រង់នឹងរូបសិទ្ធិបាលីសំស្ក្រឹត បឋមាវិភត្តិ ឯកវចនៈ ។ ដែលខ្មែរសម្រេចរូបទៅយ៉ាងនេះ គឺដើម្បីឲ្យងាយពោលសម្លេងដែលស្រួលជា; បើទុកជាប្រើជាកម្មក្តី បើទុកជាឯកវចនៈក្តី រូបក៏គង់នៅតែដដែល ឥតប្រែប្រួលឡើយ ។

(២) តាមលោកអ្នកដឹងជ្រៅជ្រះខាងភាសាខ្មែរ ស្រៈ អៈ ដែលប្រែទៅជា

ក្នុង...

ស្រៈ អុ កាលនៅមុខព្យញ្ជនៈ ដែលមានស្រៈ អៈ

អាស្រ័យ ឬនៅមុខព្យញ្ជនៈតំរួតអាចមានសំលេង ៣ យ៉ាង៖

អៈ > អៈ ១. បរមាភិសេក (ប៉ៈរ៉ៈ...);

អៈ > អុ ២. ផលៈ (ផៈលៈ) > ផល (ផល់),

សព្វៈ (សាប់-ពៈ) > សព្វ (សប់);

ភវៈ (ភៈវៈ) > ភព (ភប់);

---

អុ នេះ ព្រោះមកពីការអានច្រឡំ ។ លោកជាតិបូភណ គេសរសេរ ឋុទុម បពិត្រ ស្ទុកល ដោយដាក់វណ្ណយុត្តិ—សង្កត់ពីរពីក្រោម ដើម្បីសំគាល់ថា ជាសម្លេង អ, កុំឲ្យប្រកបទៅនឹងអក្សរផិតខាង ។ វណ្ណយុត្តិនេះតំអក្សរ អ សរសេរដោយកាត់ បំពេញសកណ្ដាលភ្ជាប់គ្នា ។ តាមទំព័រនិពន្ធដោយហ្មត់-ចត់មើលទៅ សេចក្ដីពិតផ្ទុយផ្សេងពីនេះ ។ ជើង អ ដាក់ក្រោមព្យញ្ជនៈ ប្រើជាស្រៈនេះ យើងប្រើតាមសៀម ។ ចាប់ឃើញមានប្រើដំបូងក្នុងសិលា-ចារឹកកាល គ.ស. ១៦២៥ (សៀវភៅសិលាចារឹកនគរវត្តទំព័រ ២២-២៣)។ ប្រើសម្រាប់កត់សម្លេង អឿ (ម្លើង), សម្រង់ ដែលប្រកបខ្យល់ជាព្យាង្គ វែង (ន្ធក, សៀមសព្វថ្ងៃ នអក, អានជា នក ។ កាលនោះ បើ

ធ្ង...

អៈ > អ័ ឧ. សកៈ (សៈ កៈ) > ស័ក (ឡើងស័ក ពេលចូលឆ្នាំ), ស័ព្ទ, វត្ត (វ័ត), ភព្វ > ភ័ព្វ;

អៈ > អុ ឧ. ឧត្បលៈ > ឧត្បល (ឧត-ប្បុល),

វិតក្កៈ > វិតក្ក (វិតុក) ។

អុ > អូ ឧ. ធុរៈ បុរាណ កុមារ (សម្លេងសាមញ្ញ ជា អូ ទាំងអស់).

---

សរសេរ ឧក ត្រូវរកឃើញ ឧក់ ។ មក សរសេរ មោក ឬ ម្អោក), សម្រាប់សម្លេង អើៈ ប្អួហ អាចជា បើ (សៀវភៅដដែលទំព័រ៣០)។ ក្នុងសម័យជំនាន់នោះផង អ បិនទាន់មានដាក់ក្រោមព្យញ្ជនៈ សម្រាប់សំគាល់ថាមានស្រៈ អ អាស្រ័យកុំឲ្យច្រឡំនឹងព្យញ្ជនៈជិតខាងទេ ។ ពាក្យ បវិត្រ ឃើញសរសេរតែក្នុងច្បាប់ដល់ គ.ស. ១៦២៥ (សៀវភៅដដែលទំព័រ ២៣) ឥតមានជើង អ ឬក្បួសពីក្រោមពីរទេ ។ ស្រាប់តែក្នុងសិលាចារិកលេខ៩ (សៀវភៅដដែលទំព័រ ២៥) គ.ស. ១៦២៧ និងលេខពបករទៀតឃើញសរសេរ បូពិត្រ និង បុពិត្រ តែម្តង ។ សេចក្តីសន្និដ្ឋានធំជាស្រៈ អ ប្រែជា អូ នេះ ប្រែទៅតាមទំនួលសម្លេងខ្មែរដោយពិត ។

ឧ (អុ) > អុ សំរាប់ស្រះពេញតួ ដូចជា ឧបមា ឧទ្យាន
ឧបាយ ឧបរាជ ឧត្បាត ឧត្បល ...
សម្លេង ឧ ទៅតាមសម្លេងខ្មែរ អុ ទាំងអស់,
តែក្នុងវចនានុក្រម លោកឲ្យអានតាមសម្លេង
បាលីសំស្ក្រឹតថា អុ;

អិ, អី > អឿ ឧ. កិរ្តិ > កេរ្តិ៍, តិរច្ឆាន (សម្លេងជាតេរ-
ច្ឆាន), មិគសិរ (អានមិគៈសេរ), សីមា
(សម្លេងជា សេមា);

អិ > អឹ ឧ. សិង្ហ (ដេក) (អានថា សឹង), ទិស (អាន
ថា ទឹស), ពិស (អានថា ពឹស), ឧទិក >
ទិក > ទឹក; សំរាប់ពាក្យក្នុងឧទាហរណ៍នេះ ការ
ប្រែសម្លេង អិ > អឹ បានសម្រេចរួចទៅហើយ,
តែចំពោះពាក្យខ្លះដូចជា សិង្ហ (ក្នុង សិង្ហមាន,

សុទ្ធសឹងតែ), គិត, ការប្រែប្រួលកំពុងតែ
មានច្រើនសព្វថ្ងៃនេះមិនទាន់រួចស្រឡះនៅឡើយ,
អ្នកខ្លះនិយាយថា សឹង, អ្នកខ្លះនិយាយថា
សិង, អ្នកខ្លះថា គិត អ្នកខ្លះថា គឹត;

អេ > អែ ៖. ហេតុ (អានថា ហែត) ខេត្ត (សម្រេចជា ខែត), បដិសេធ (អានថា ប៉ៈដិសែត), តេ > តែ[១]
ឆេះ (សម្រេចជា ឆែះ), បេះ (សម្រេចជា បែះ),

---

១) – តែ (ទឹកតែ, ស៊ីកតែ) មកពីពាក្យចិនថា តេ, លោកឲ្យដាក់ស្រៈ អែ តាមសម្លេងហៅ; ក្នុងវចនានុក្រមលោកដាក់ «តែ ន. (ចិ. តេ) ...»។ នោះបើលោកដាក់ដូច្នេះតែងបាន៖ «ហែត ន. (សំ.ម. ហេតុ) ...; ខែត្ត ន. (ម. ខេត្ត) ...» ឃើញជាមិនពេញចិត្តដល់អ្នកប្រើភាសាខ្មែរជាច្រើននាក់ ។ ខ្ញុំយល់ថាគួរធ្វើទៅបានព្រោះបើកែ អេ ជា អែ មិនអាចនាំឲ្យវង្វេងនិរុត្តិសាស្ត្រ ដល់ដំណើរពាក្យដើមកំណើតមិនឃើញនោះទេ, ដ្បិតក្នុងភាសាបាលីសំស្ក្រឹតមានតែស្រៈ អេ, ស្រៈ អែ គ្មានសោះ ។

សេះ (*សម្លេងជា សែះ*)(១) ។

អោ > អ ៖ រង្កោ > អង្ក, សំណោ > សម្ល, យោកិ > យក, មោកិ > មក ។

ឃ.- កែពាក្យព្យាង្គច្រើនជាពាក្យព្យាង្គតិច

សម្លេងសង្កត់.– *ក្នុងពាក្យពហុព្យាង្គ មានព្យាង្គខ្លះយើងអានសង្កត់ ព្យាង្គខ្លះយើងអានបន្ធូរសម្លេង;*

១. ឆង្គល វង្វាល់ ភិក្ខុ ។ *ព្យាង្គសង្កត់គឺ* គល, វាល់, ភិក, *ព្យាង្គបន្ធូរ គឺ* ឆង់ វង់ ខុ ។

---

១)– *កែះ* លោកចេះសរសេរឲ្យត្រឹមត្រូវតាមសម្លេងនិយាយជា *កែះ* (ស្រៈ *អែ*), ឯ *ធេះ ថេះ សេះ* លោកមិនមានអនុញ្ញាតក្នុងវចនានុក្រមឲ្យអានជាស្រៈ *អែ* ឡើយ ។ ដូច្នេះយើងត្រូវអានតាមស្រៈ *អេ*, ប៉ុន្តែ កាលបើយើងធ្លាប់ថា *អែ* ទាំងអស់គ្នាទៅហើយ ហើយត្រឡប់ត្រូវថា *អេ* ដូច្នេះវិញ នោះនាំឲ្យចង្អៀតចិត្តមិនតិចឡើយហាក់បីដូចជាមកបង្ខាប់ឲ្យយើងថាស្រៈ *អែ* មិនច្បាស់ដូចប៉ិន ៖ " *យកសេ ទៅចងសេ* " (យកខ្សែទៅចងសេះ)។

ពាក្យសង្កត់ជាខ្លឹមសាររបស់ពាក្យ ឯពាក្យបន្ទោរជាភាគបន្ទាប់បន្សំ អាចប្រែប្រួលឬបាត់បង់ទៅបាន ដោយឥតធ្វើឲ្យសេចក្ដីរបស់ពាក្យប្រែប្រួលទៅផងឡើយ ។ ឆង្គល ទឹងជា អង្គល ឬ រង្គល់ ក៏នៅស្ដាប់បានសេចក្ដី; រង្វាល់ ទឹងជា អង្វាល់ ឬ លង្វាល់ ក៏នៅស្ដាប់បាន ។ ភិក្ខុ ទឹងជា ភិក្សុ តាមសំស្ក្រឹតក៏សឹងបាន ឬមួយទឹងលុបពាក្យបន្ទោរចោលហៅថា លោកភិក ទទេក៏មានប្រើ ។

ពាក្យដែលមានព្យញ្ជនៈផ្ញើផងដូចជា ប្ដឹង ស្ដាប់ ស្លា វែងជាងពាក្យ ១ ធម្មតា តែខ្វះជាងពាក្យពីរ ។ តាមត្រូវគួរទុកជា ១ ពាក្យកន្លះ ៖ ពាក្យពេញ ជាពាក្យសង្កត់, ពាក្យកន្លះជាពាក្យបន្ទោរ ។ ពាក្យកន្លះនេះអាចប្រែប្រួល ឬបាត់រូបទៅដូចពាក្យបន្ទោរឯទៀតដែរ ។ តាមសង្កេតភាសាខ្មែរបូរាណ ឃើញមានពាក្យបន្ទោរប្រែប្រួលទៅដោយនៅគង់ចំនួនពាក្យដដែលដូចមានតទៅនេះ ៖

កល្ទត៑ > ក្រមួន, បទ្ទ្យក៑ > បំពៀន

បន្លេក៑ > សំលៀក; ប៉ុង៑ > ឆ្នុំង៑ > ស្នុំង

រង្គោ > អង្គុរ; ត្មិ > ថ្មី ។

*ការប្រែប្រួលដល់បាត់ព្យាង្គបន្ទេរនោះមានច្រើនយ៉ាង ៖*

១– បំបាត់ស្រៈចុងពាក្យទុកព្យញ្ជនៈជាខ្យល់

*ច្បាប់ត្រង់នេះ ប្រើទូទៅសម្រាប់ពាក្យដែលខ្ចីពីសំស្ក្រឹត និងបាលីដោយចំពោះសម្រាប់ស្រៈ អៈ ។ ក្រៅពីស្រៈ អៈ មានស្រៈ អិ ខ្លះ ។*

ឧ. ជិនៈ (២ព្យាង្គ) > ជិន (១ព្យាង្គ)

កុសលៈ (៣ព្យាង្គ) > កុសល (២ព្យាង្គ)

បរិសុទ្ធិ (៤ព្យាង្គ) > បរិសុទ្ធ (បរិសុត ៣ព្យាង្គ) ។

២– បំបាត់ព្យាង្គចុងពាក្យពោលទាំងមូល

ឧ. ប្រយោជនៈ (៤ព្យាង្គ) > ប្រយោជន៍ (ប្រយោច ២ព្យាង្គ)

បន្ធនៈ (៣ព្យាង្គ) > បន្ទន់ (ពន់១ព្យាង្គ)

បុត្រៈ (២ព្យាង្គ) > បុត្រ (បុត ១ព្យាង្គ)

៣- បំបាត់ព្យាង្គដើមចោលទាំងមូល

អម្ពុ (២ព្យាង្គ) > ម្ពុ (១ព្យាង្គកន្លះ)

អស្សៈ (២ព្យាង្គ) > អសេះ > សេះ > សេះ (១ព្យាង្គ)

ឧបាសកៈ (៤ព្យាង្គ) > បាសក (២ព្យាង្គ)

៤- បំបាត់ស្រៈក្នុងព្យាង្គដើមយកព្យញ្ជនៈ

ដាក់ផ្ញើជើង

កបាលៈ (៣ព្យាង្គ) > ក្បាល (១ព្យាង្គកន្លះ)

គរុឌៈ (៣ព្យាង្គ) > គ្រុឌ (១ព្យាង្គកន្លះ)

គរុ (២ព្យាង្គ) > គ្រូ (១ព្យាង្គកន្លះ)

ពាក្យខ្មែរបុរាណ ដែលក្លាយយកមកដោយវិធីនេះមាន

ច្រើន ។ ខ្ញុំនឹងចាំមកសំដែងខ្លះជាឧទាហរណ៍ ៖

វគាំ > ផ្គាំ កវាំ > ក្រោម

កន្ទុយ (*មាន កន្ទុយ*) > ក្ដួយ, ក្ករុង > ក្រុង

កន្ទ្រង (*មាន កន្ទបង*) > ក្ដោង, កងោល > ក្រោល

បណ្ដៀង (*មាន បរិង*) > ប្រែង, (អ្នេ) កំយេក>

(ម៉ែ) ខ្មែក ។

ង- កែពាក្យព្យាង្គតិចជាពាក្យព្យាង្គច្រើន

*ការកែប្រែបែបនេះមានតិចណាស់ ។ បំណងគឺថា ឲ្យមានតុល្យភាព (équilibre) កុំឲ្យកំបុកសៈមុន ។*

ឧ. ពី > អំពី, ម្ទូត > អម្រឹត, ម្ចាស់ > អម្ចាស់, បរាជ័យ > អប្បរាជ័យ ឬ អបរាជ័យ(១)

*ក្រៅពីឧទាហរណ៍នេះ នៅមានពាក្យខ្មែរឯណាខ្លះ*

---

(១) ពាក្យនេះញាណក្នុងវចនានុក្រមទេ ប្រែសេចក្ដីថា លោកមិនទទួលយក ក្នុងភាសាសរសេរ ។ *អបរាជ័យ* ដែលមានក្នុងវចនានុក្រមលោកប្រែថា ឈ្នះ ឯពាក្យក្នុងឧទាហរណ៍នេះប្រែថាចាញ់ដូច *បរាជ័យ* ។

ដែលប្រែសការៈពីឯកព្យាង្គ មកជាពហុព្យាង្គរួចយូរមកហើយ, គឺ៖

ជើ > ចញ្ជើ, ជ្យេង (ជើង) > ជញ្ជើង,

ឯតិ > ទម្ងន់, (ស្មោ) ឆា > (ស្មើ) ភ្លា,

លិងិ > តម្បឹង ។

## ប– ការប្រែប្រួលអក្សរ វ

### ១– វ ប្រែជា ព

វ ប្រែជា ព ជាទំនួលសម្ងន់ក្នុងភាសាច្រើនណាស់ក្នុងលោក, មិនចំពោះតែក្នុងភាសាខ្មែរទេ ជាការណ៍ធម្មតាក្នុងភាសាអំបូរ ឥណ្ឌូ-អឺរ៉ុប ។ ក្នុងភាសាយើង ពាក្យខ្មែរសុទ្ធក៏មាន វ ប្រែជា ព, ពាក្យមកពីបាលីសំស្ក្រឹតក៏មានប្រែដូច្នេះដែរ ។

ឧ. វវៃ > ពពៃ; សំវៃង > សំពៃង

វុំ > ពុំ; វត្តមាន > ពត៌មាន

វីរ > ពីរ; សំភៅ > សំពៅ

អំវី > អំពី; ត្រវាំង > ត្រពាំង

វិត > ពិត; វ្រះ > ព្រះ

វៀរ > ពៀរ; វ្រៃ > ព្រៃ

វេទ្យ > ពេទ្យ; វេលា > ពេល

សាវ៉ុង > សាប៊ូ; វ្យញ្ជនៈ > ព្យញ្ជនៈ ។

៦–, វ ប្រែជា ភ

អាចបញ្ចូលគ្នាបានទើងមាត់ការ ១ គ្រាន់តែប្រើសំលេ ព ជាធម្មតា ភ ដូចយើងបានឃើញមកហើយ ។ ពាក្យ ចំពួកនេះមានខ្លះដូចតទៅនេះ៖

វ្ញ > វ្ញី > ភ្ញី; វ្លឹង > ភ្លើង,

វ្នំ > ភ្នំ; វ្នែក > ភ្នែក,

វ្រ្គ > ភ្រ្គ ។

## ៣- វ ប្រែជា អ្វ ឬ អួ

វ ប្រែជាស្រៈបានដោយហេតុ វ ជាអន្តស្រៈដូចបានពោលមកហើយក្នុងមាតិកាព្យញ្ជនៈ ។ វ ប្រែជា អួ ។ នេះជាធម្មតាក្នុងសំបូរភាសាឥណ្ឌូ-អឺរ៉ុបទាំងឡាយ ។ បណ្ដាពាក្យខ្មែរដែលប្រែ វ ជា អួ នោះមាន៖

បន្វល៑ > បន្ទួល; ស្វំ > សួម,

ជ្វិន > ជួន; ក្វន > កួន ។ល។

សំរាប់ពាក្យសំស្ក្រឹតដែលមកជាពាក្យខ្មែរ ដោយ វ ប្រែជា អួ នោះមាន៖

ស្វរ > សួរ; អស្វតរ > អសួតរ[១]

ត្ដៀស្វរ > ត្ដៀសួរ; អស្វពាហ > អសួពាហ[១]

ត្រង់ វ ប្រែជា អួ មានឧទាហរណ៍ដូចតទៅនេះ៖

---

(១) រូបពាក្យពីរបែបនេះ លោកមិនដាក់ក្នុងវចនានុក្រមបញ្ចូលជាភាសាសរសេរទេ នៅជាភាសានិយាយនៅឡើយ ។ អាន អ:-សូ-ផ ។

ម្វយិ > ម្វាយិ > មួយ; ស្វតិ > សួតិ,

ប្វនិ > ប្វានិ > បួន; ស្វស្តិ > សួស្តី ។

ឆ– ការប្រែប្រួលសម្លេងផ្សេងៗទៀត

*ពាក្យដែលខ្ញុំនាំមកជាឧទាហរណ៍នេះគ្រាន់តែជារបស់ប្លែកគួរដឹងតែប៉ុណ្ណោះ មិនមែនតាំងជាក្បួនខ្នាតអ្វីបានទេ ។*

ប > ស ៖ បន្លេក > សំលៀក ។

ធ > ស ៖ ធី > ស៊ី, ធ្មិង > ស្មឹង ។

យ > ញ ៖ (ក្នុរ) យេ > (គោ) ញី ។

*ការប្រែ យ ជា ញ ជាការចំឡែក, ឃើញមានតែក្នុងករណីមួយនេះ ។*

—≡ចប់ភាគទី ១≡—